ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា

# សៀវភៅមគ្គុទេសក៍
# ចំណុចសំខាន់នៃការរៀន និងការបង្រៀន

## សុខភាពសិក្សាសម្រាប់ទាំងអស់គ្នា
## «ជំហានទៅកាន់ពិភពលោកដែលកាន់តែប្រសើរ»



### សម្រាប់គ្រូឧទ្ទេសសុខភាពសិក្សាកម្រិតបឋមសិក្សា

២០២៣

# អារម្ភកថា

សៀវភៅមគ្គុទេសក៍សម្រាប់គ្រូឧទ្ទេសនេះ ត្រូវបានបង្កើតឡើងក្នុងគោលបំណងដើម្បីជាឧបករណ៍ណែនាំសម្រាប់គ្រូឧទ្ទេសដែលបង្រៀនមុខវិជ្ជាសុខភាពសិក្សានៅវិទ្យាស្ថានគរុកោសល្យនៅក្នុងប្រទេសកម្ពុជា ក៏ដូចសម្រាប់ជាឯកសារជំនួយក្នុងការរៀបចំផែនការមេរៀននៅពេលប្រើប្រាស់សៀវភៅសិក្សាគោល **«សុខភាពសិក្សាសម្រាប់ទាំងអស់គ្នា - ជំហានទៅកាន់ពិភពលោកដែលកាន់តែប្រសើរ»**។

កាលពីខែមេសា ឆ្នាំ២០២២ កន្លងទៅ គរុនិស្សិតកម្រិតបឋមសិក្សាដែលសិក្សានៅវិទ្យាស្ថានគរុកោសល្យរាជធានីភ្នំពេញនិងបាត់ដំបងបានចាប់ផ្តើមរៀនមុខវិជ្ជាសុខភាពសិក្សាដោយបានប្រើប្រាស់សៀវភៅសិក្សាគោលសុខភាពសិក្សា។ ដើម្បីអាចបង្រៀនមុខវិជ្ជាសុខភាពសិក្សាដោយប្រើប្រាស់សៀវភៅសិក្សាគោលនេះបាន គ្រូឧទ្ទេសទាំងអស់បានទទួលការបណ្តុះបណ្តាលអំពីខ្លឹមសារមេរៀន និងវិធីសាស្ត្រនៃការបង្រៀនអស់រយៈពេលប្រហែល ១ឆ្នាំ។ ទោះជាយ៉ាងណាក៏ដោយ ខ្ញុំគិតថា ការបង្រៀនមុខវិជ្ជាដែលខុសពីជំនាញរបស់បុគ្គលម្នាក់ៗទាមទារឱ្យមានការខិតខំប្រឹងប្រែងយ៉ាងខ្លាំងពីគ្រូឧទ្ទេសគ្រប់រូប។ លើសពីនេះទៅទៀត ដោយសារតែនេះជាសៀវភៅសិក្សាគោលដំបូងបង្អស់របស់ប្រទេសកម្ពុជាដែលបង្រៀនអំពីមុខវិជ្ជាសុខភាពសិក្សាលក្ខណៈជាប្រព័ន្ធ យើងបានរៀបចំដោយដាក់បញ្ចូលនូវខ្លឹមសារមេរៀនសំខាន់ៗនៅក្នុងសៀវភៅនេះផងដែរ។ ដូច្នេះហើយ យើងមានទំនុកចិត្តយ៉ាងខ្លាំងថា សៀវភៅសិក្សាគោលនេះនឹងទទួលបាននូវការចាប់អារម្មណ៍មិនត្រឹមតែពីសំណាក់និស្សិតប៉ុណ្ណោះទេ ថែមទាំងពីសំណាក់អ្នកជំនាញផ្នែកសុខភាព វេជ្ជសាស្ត្រ និងគិលានុបដ្ឋាកដែលមានចំណាប់អារម្មណ៍ទៅលើមុខវិជ្ជាសុខភាពសិក្សានេះផងដែរ។ ម្យ៉ាងវិញទៀត ក្នុងសៀវភៅសិក្សាគោលនេះមានមាតិកាមេរៀនជាច្រើន ដូច្នេះចាំបាច់ត្រូវបង្រួមចំណុចសំខាន់ៗបំផុតដើម្បីយកទៅបង្រៀនឱ្យសមស្របទៅតាមពេលវេលានិងចំនួនថ្នាក់រៀនដែលវិទ្យាស្ថានបានកំណត់នាពេលបច្ចុប្បន្ន។ ខ្ញុំអាចនិយាយបានថា នេះជាបន្ទុកមួយដ៏ធំសម្រាប់គ្រូឧទ្ទេសដែលកំពុងបង្រៀនមុខវិជ្ជានេះលើកដំបូង។

ដូច្នេះដោយផ្អែកលើការអនុវត្តជាក់ស្តែងក្នុងការបង្រៀនអស់រយៈពេល ៦ខែ យើងបានសម្រេចផ្តោតលើចំណុចសំខាន់ៗក្នុងជំពូកនីមួយៗនៃសៀវភៅគោលសិក្សានេះដោយពន្យល់ពីវិធីសាស្ត្របង្រៀន ការរៀបចំកិច្ចតែងការ សម្ភារៈដែលត្រូវប្រើសម្រាប់បង្រៀន និងសកម្មភាពផ្សេងៗដែលត្រូវរួមបញ្ចូល បូករួមជាមួយនឹងឧទាហរណ៍ជាក់លាក់ និងច្បាស់លាស់នៃសៀវភៅមគ្គុទេសក៍នេះផងដែរ។

សៀវភៅមគ្គុទេសក៍នេះក៏បានពន្យល់អំពីលក្ខណៈជាមូលដ្ឋាននៃការអប់រំដែលស្របទៅនឹងចក្ខុវិស័យរបស់គ្រឹះស្ថានបណ្តុះបណ្តាលគ្រូបង្រៀនដោយផ្តោតទៅលើ គុណភាព សមត្ថភាព អាកប្បកិរិយា គុណតម្លៃ និងអត្តកម្មផ្សេងៗដែលទទួលបានពីការសិក្សាអប់រំតាមរយៈការប្រើប្រាស់សៀវភៅសិក្សាគោលនេះដោយគ្មានកំណត់ដែនចំណេះដឹង និងជំនាញនៃមុខវិជ្ជាសុខភាពសិក្សាឡើយ។

តាមរយៈការអានសៀវភៅមគ្គុទេសក៍សម្រាប់គ្រូបង្រៀននេះដោយយកចិត្តទុកដាក់ វាមិនត្រឹមតែផ្តល់ការយល់ដឹងពីចំណុចសំខាន់នៅក្នុងការបង្រៀន និងវិធីសាស្ត្រសម្រាប់រៀបចំក្នុងការបង្រៀនតែប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងអាចឱ្យអ្នកអានយល់ពីការឆ្លើយតបរបស់មុខវិជ្ជាសុខភាពសិក្សាស្របតាមវត្ថុបំណងនៃការអប់រំដែលជាគោលបំណងពិតប្រាកដរបស់គ្រឹះស្ថានបណ្តុះបណ្តាលគ្រូបង្រៀនផងដែរ។

សៀវភៅសិក្សាគោល «សុខភាពសិក្សាសម្រាប់ទាំងអស់គ្នា - ជំហានទៅកាន់ពិភពលោកដែលកាន់តែប្រសើរ» នឹងត្រូវកែសម្រួលស្របពេលដែលការបង្រៀនមុខវិជ្ជាសុខភាពសិក្សាពង្រីកវិសាលភាពនិងបង្កើតប្រវត្តិសាស្ត្រនៅក្នុងគ្រឹះស្ថានបណ្តុះបណ្តាលគ្រូបង្រៀន និងវិទ្យាស្ថានគរុកោសល្យនៅប្រទេសកម្ពុជាផងដែរ។

ខ្ញុំមានសេចក្តីសោមនស្សរីករាយយ៉ាងខ្លាំងដែលសមាជិកគម្រោងទាំងអស់បានចូលរួមចំណែកក្នុងការបង្កើតសៀវភៅសិក្សាគោល និងសៀវភៅមគ្គុទេសក៍សម្រាប់គ្រូបង្រៀននេះ។ ខ្ញុំសង្ឃឹមថា យើងនឹងមានឱកាសសហការជាមួយគ្រូឧទ្ទេសដែលនឹងត្រូវបង្រៀនមុខវិជ្ជាសុខភាពសិក្សានៅតាមបណ្តាគ្រឹះស្ថានបណ្តុះបណ្តាលគ្រូបង្រៀន និងវិទ្យាស្ថានគរុកោសល្យបន្តទៀត ដើម្បីបង្កើតយុគសម័យថ្មីនៃមុខវិជ្ជាសុខភាពសិក្សាកម្រិតឧត្តមសិក្សានៅប្រទេសកម្ពុជា។

**អារម្ភកថាអ្នកនិពន្ធ**

សាស្ត្រាចារ្យបណ្ឌិត **អាសាគីវ៉ា តាកាស៊ី**

ប្រធានគម្រោងអភិវឌ្ឍន៍សុខភាពសិក្សាសម្រាប់កុមារកម្ពុជា (SHCC)

សាកលវិទ្យាល័យ តូក្យូ ហ្គាគឺហ្គេ

“

*ដើម្បីបង្រៀន ឬរៀនពីសារៈសំខាន់នៃសុខភាពសិក្សា គឺត្រូវទាមទារពេលវេលា។*

*វាមានសារៈសំខាន់ណាស់ក្នុងការបន្តការសិក្សាពេញមួយជីវិត។*

*អ្វីដែលងាយចេះគឺងាយភ្លេច។*

*គ្រូបង្រៀនល្អគឺជាគ្រូដែលនៅតែបន្តរៀនសូត្រជាប្រចាំ។”*

- អាសាគីរ៉ា តាកាស៊ី

# មាតិកា


**អារម្ភកថា** ........ i

**សេចក្តីផ្តើមសៀវភៅមគ្គុទ្ទេសក៍សម្រាប់គ្រូឧទ្ទេស** ........ vi

ការពន្យល់បន្ថែម៖ តើមនុស្សជាតិគឺជាអ្វី? ........ vii

តម្លៃស្នូលរបស់វិទ្យាស្ថានគរុកោសល្យ (TEC) និងសុខភាពសិក្សា ........ ix

សុខភាពសិក្សានឹងធ្វើឱ្យអក្ខរកម្មរបស់គរុនិស្សិតកាន់តែប្រសើរឡើង ........ x

**អ្វីដែលគ្រូចរៀន** ........ xi

**១. ស្វែងយល់អំពីរចនាសម្ព័ន្ធមូលដ្ឋាននៃសៀវភៅសិក្សាគោលនេះ និងផ្លាស់ប្តូរគំនិត ព័ត៌មានជាមួយគរុនិស្សិតរបស់អ្នក** ........ xi

១.១. ផ្តល់ជូនគរុនិស្សិតនូវទស្សនៈ និងជំរុញការចង់ដឹងឃើញរបស់ពួកគេ ........ xi

១.២. រចនាសម្ព័ន្ធនៃអត្ថបទនិងរបៀបប្រើប្រាស់សៀវភៅសិក្សាគោល ........ xi

១.៣. ការស្វែងមតិលើសុខភាព និងរបៀបរស់នៅរបស់គរុនិស្សិតវិទ្យាស្ថានគរុកោសល្យ (TEC) ........ xiii

**២. ទិដ្ឋភាពទូទៅនៃជំពូកនីមួយៗ និងការភ្ជាប់ទំនាក់ទំនង/ចំណុចគន្លឹះនៃជំពូកនីមួយៗ** ........ xiv

**ធ្វើឱ្យប្រសើរឡើងនូវដំណើរការសិក្សា (ការបង្រៀន)** ........ xx

**១. ចំណុចគន្លឹះនៃការបង្រៀនសុខភាពសិក្សា** ........ xx

១.១. អភិវឌ្ឍអាកប្បកិរិយារបស់គរុនិស្សិតក្នុងការរៀន និងបង្រៀនសុខភាពសិក្សាជាមុខវិជ្ជាសិក្សា ........ xx

១.២. កត្តាដែលត្រូវរៀបចំនៅក្នុងសេចក្តីផ្តើមនៃថ្នាក់សិក្សា ........ xxi

១.៣. អ្វីដែលគ្រូឧទ្ទេសគួរធ្វើ ........ xxi

**ចំណុចដែលគ្រូចបង្រៀនស្របតាមគោលបំណងសិក្សានៃជំពូកនីមួយៗ** ........ 1

**មេរៀនទី ១៖ សេចក្តីផ្តើម៖** លក្ខណៈនៃសុខភាពសិក្សា និងជំពូកទី១៖ សុខភាព ........ 1

**មេរៀនទី ២៖ ជំពូកទី ១៦៖** ពិការភាព និងតម្រូវការការអប់រំពិសេស ........ 5

**មេរៀនទី ៣-៤៖ ជំពូកទី ២៖** របៀបរាងការរបស់អ្នកធ្វើការ ........ 11

**មេរៀនទី ៥-៦៖ ជំពូកទី ៣៖** ការលូតលាស់ និងការអភិវឌ្ឍរបស់កុមារ ........ 15

**មេរៀនទី ៧៖ ជំពូកទី ៤៖** ភាពស្អាត អនាម័យ និងសុខភាព ........ 19

**មេរៀនទី ៨-៩៖ ជំពូកទី ៥៖** របៀបរស់នៅ និងសុខភាព ........ 23

**មេរៀនទី ១០-១១៖ ជំពូកទី ៦៖** ការបង្ការជំងឺបណ្តាលមកពីរបៀបរស់នៅ ........ 27

**មេរៀនទី ១២-១៣៖ ជំពូកទី ៧៖** ជំងឺឆ្លង វិធីបង្ការ និងការពារ ........ 33

**មេរៀនទី ១៤៖ ជំពូកទី ៨៖** សុខភាពមាត់ធ្មេញ ........ 39

**មេរៀនទី ១៥-១៩៖ ជំពូកទី ៩៖** សារៈសំខាន់ និងវិធីសាស្ត្រនៃការពិនិត្យសុខភាព ........ 43

**មេរៀនទី ២០-២១៖ ជំពូកទី ១៥៖** ការសង្គ្រោះបឋមនៅសាលារៀន ........ 49

**មេរៀនទី ២២-២៣៖ ជំពូកទី ១០៖** ផលប៉ះពាល់សុខភាពនៃការប្រើប្រាស់ថ្នាំជក់ គ្រឿងស្រវឹង និងគ្រឿងញៀន.. 53
**មេរៀនទី ២៤-២៥៖ ជំពូកទី ១១៖** ការប្រែប្រួលផ្លូវចិត្ត និងរាងកាយអំឡុងពេលយុវវ័យ (ការអប់រំផ្លូវភេទលក្ខណៈទូលំទូលាយ) ..... 57
**មេរៀនទី ២៦-២៧៖ ជំពូកទី ១២៖** សុខភាពផ្លូវចិត្ត ..... 61
**មេរៀនទី ២៨-២៩៖ ជំពូកទី ១៣៖** បរិស្ថាន និងសុខភាព/អេកូសុខភាព ..... 65
**មេរៀនទី ៣០៖ ជំពូកទី ១៤៖** សុវត្ថិភាពសាលារៀន និងការគ្រប់គ្រងវិបត្តិ (ការអប់រំអំពីសុវត្ថិភាពសាលារៀន) ... 71
**វិធីសាស្ត្របង្រៀនការអប់រំសុខភាព** ..... 82
**១. ការបង្កើតមេរៀនការអប់រំសុខភាព** ..... 82
១.១. ការកំណត់ និងវាយតម្លៃគោលបំណងសិក្សាក្នុងមេរៀន ..... 82
១.២. លំហូរនៃថ្នាក់សិក្សា ..... 82
១.៣. សម្ភារៈឧបទេស ..... 83
១.៤. វិធីសាស្ត្រសិក្សាផ្សេងៗ..... 83
១.៤.១. Problem-Based Learning (PBL) ..... 86
១.៤.២. Project-Based Learning ..... 88

## បញ្ជីតារាង

**តារាងទី ១៖** កាលវិភាគមេរៀន (ឧទាហរណ៍)..... xxiii
**តារាងទី ២៖** តារាងស្ដីពីទំនាក់ទំនងនៃសៀវភៅសិក្សាគោល «សុខភាពសិក្សាសម្រាប់ទាំងអស់គ្នា» នៃកម្មវិធីសិក្សារបស់វិទ្យាស្ថានគរុកោសល្យកម្រិតបឋមសិក្សាទៅនឹងកម្មវិធីសិក្សាអប់រំសុខភាពនៅតាមសាលាបឋមសិក្សា ..... 75
**តារាងទី ៣៖** ឧទាហរណ៍នៃវិធីសាស្ត្របង្រៀនដែលប្រើប្រាស់នៅក្នុងថ្នាក់អប់រំសុខភាព..... 84

# សេចក្ដីផ្ដើម
# សៀវភៅមគ្គុទេសក៍សម្រាប់គ្រូឧទ្ទេស

ប្រទេសកម្ពុជាមានការអភិវឌ្ឍសេដ្ឋកិច្ចយ៉ាងឆាប់រហ័ស ហើយឥឡូវនេះត្រូវបានចាត់ថ្នាក់ចេញពីប្រទេសដែលមានចំណូលទាបទៅជាប្រទេសដែលមានចំណូលមធ្យមកម្រិតទាប។ នាថ្ងៃអនាគត តើប្រទេសកម្ពុជាមានគោលបំណងចង់ក្លាយទៅជាសង្គមបែបណា? ហើយតើយុវជនបែបណាដែលប្រទេសកម្ពុជាខិតខំបណ្ដុះដើម្បីទទួលខុសត្រូវចំពោះសង្គមនោះ? តើចំណេះដឹង និងគុណតម្លៃអ្វីខ្លះដែលពួកគេត្រូវបានគេរំពឹងថានឹងរៀន? តើពួកគេត្រូវបានរំពឹងថានឹងអភិវឌ្ឍជំនាញនៃការគិតវិភាគ និងជំនាញជីវិតបែបណាដែលអាចយកមកអនុវត្តក្នុងជីវិតជាក់ស្ដែងបាន?

ការអប់រំគឺជាវិស័យសិក្សាដែលបង្កើតអនាគតសង្គម និងយុវជនដែលប្រទេសកម្ពុជាស្រមៃចង់បាន។ ការអប់រំសុខភាពសិក្សាអាចរួមចំណែកយ៉ាងសំខាន់ដល់ការធ្វើឱ្យមានចីរភាព និងភាពប្រសើរជាងមុននៅក្នុងពិភពលោកនោះក្នុងនោះរួមមាន បរិស្ថាន ឋានប្រព័ន្ធ ការអភិវឌ្ឍសង្គម និងសកម្មភាពរបស់មនុស្សមានភាពសុខដុមរមនា ហើយមនុស្សកាន់តែច្រើនអាចរីករាយនឹងសុខុមាលភាពជីវិតរបស់ពួកគេ។ ពោលម្យ៉ាងទៀតគឺការអប់រំជាវិស័យសិក្សាដែលបង្កើតសុខុមាលភាពសម្រាប់មនុស្ស និងសង្គមឆ្ពោះទៅកាន់ **«អនាគតប្រកបដោយសុខភាពល្អ និងសន្តិភាព»** របស់ប្រទេសកម្ពុជា។

សៀវភៅសិក្សាគោលនេះគ្របដណ្ដប់យ៉ាងគ្រប់គ្រាន់នូវខ្លឹមសារដែលត្រូវបង្រៀននៅកម្រិតបឋមសិក្សា បន្ទាប់ពីបានពិនិត្យមើលកម្មវិធីសិក្សាសម្រាប់ការអប់រំសុខភាពនៅកម្រិតបឋមសិក្សារួចមក។ វាក៏បំពេញបានយ៉ាងពេញលេញផងដែរនូវខ្លឹមសារជាមូលដ្ឋានដែលគរុនិស្សិតនៅមហាវិទ្យាល័យគួររៀនអំពីសុខភាពដែលជាផ្នែកមួយនៃការអប់រំសិល្បៈចម្រុះរបស់ពួកគេ។ ខ្លឹមសារក្នុងសៀវភៅសិក្សាគោលនេះមានភាពប្រហាក់ប្រហែល និងរៀបរៀងយ៉ាងល្អធៀបនឹងការអប់រំសុខភាពនៅតាមសាកលវិទ្យាល័យនានានៅជុំវិញពិភពលោក។ ដោយឡែក សៀវភៅសិក្សាគោលនេះមានការយកចិត្តទុកដាក់ទៅលើបរិបទសង្គម-វប្បធម៌នៃប្រទេសកម្ពុជា។

ជាពិសេស វាក្ដោបលើប្រធានបទសុខភាពសិក្សាចំនួនប្រាំបួនដូចខាងក្រោម៖

(១) **សុខភាព ជំងឺ និងពិការភាព៖** សេចក្ដីផ្ដើម ជំពូកទី ១ និង ១៦

(២) **ប្រព័ន្ធរាងកាយ ភាពស៊ាំ និងជំងឺឆ្លង៖** ជំពូកទី ២ និង ៧

(៣) **ការលូតលាស់ និងការអភិវឌ្ឍ៖** ជំពូកទី ៣ និង ១១

(៤) **របៀបរស់នៅ និងសុខភាព៖** ជំពូកទី ៤, ៥ និង ៦

(៥) **ការពិនិត្យសុខភាព សុខភាពភ្នែក និងសុខភាពមាត់ធ្មេញ៖** ជំពូកទី៨ និង ៩

(៦) **ការប្រើប្រាស់គ្រឿងញៀន សុខភាពផ្លូវចិត្ត៖** ជំពូកទី១០ និង ១២

(៧) **បរិស្ថាន និងសុខភាព៖** ជំពូកទី ១៣

(៨) **ការអប់រំអំពីសុវត្ថិភាព៖** ជំពូកទី ១៤

(៩) **ការសង្គ្រោះបឋមនៅតាមសាលារៀន៖** ជំពូកទី ១៥

ទោះជាយ៉ាងណាក៏ដោយ ការធ្វើបច្ចុប្បន្នភាពទិន្នន័យ និងការកែលម្អការពិពណ៌នាគួរតែត្រូវបានអនុវត្តជាបន្តបន្ទាប់។

សូមជ្រាបថា **គោលការណ៍ណែនាំកម្មវិធីសិក្សាថ្នាក់ជាតិរបស់ប្រទេសជប៉ុន** ផ្អែកលើមាត្រាទី ៣០ កថាខណ្ឌទី ២ នៃច្បាប់សិក្សាអប់រំ (School Education Law) ព្យាយាមអភិវឌ្ឍ គុណភាព និងសមត្ថភាពរបស់កុមារតាមរយៈសសរស្តម្ភចំនួនបី៖

- **អាកប្បកិរិយាសិក្សាពេញមួយជីវិតនិងមនុស្សជាតិ** (តើសិស្សមានទំនាក់ទំនងដូចម្តេចជាមួយពិភពលោកនិងសង្គមយ៉ាង? តើសិស្សបង្កើតជីវិតដ៏ប្រសើរមួយដោយរបៀបណា? តើសិស្សបន្តរៀនសូត្រដើម្បីសម្រេចគោលដៅទាំងនេះដោយរបៀបណា?)
- **ចំណេះដឹងនិងជំនាញជីវិត** (តើអ្វីដែលពួកគេគួរយល់ ហើយអ្វីដែលពួកគេអាចនឹងធ្វើបាន?)
- **សមត្ថភាពក្នុងការគិត វិនិច្ឆ័យ និងបញ្ចេញមតិ** (របៀបដែលពួកគេប្រើប្រាស់នូវអ្វីដែលពួកគេយល់ និងអាចធ្វើបាននៅក្នុងជីវិតនិងសង្គមជាក់ស្តែង)

**ទស្សនវិស័យទាំងបីនេះនឹងក្លាយជាសសរស្តម្ភនៃការវាយតម្លៃលទ្ធផលសិក្សា។**

ដើម្បីអភិវឌ្ឍគុណភាពនិងសមត្ថភាពទាំងបីនេះ តម្រូវឱ្យគ្រូឧទ្ទេសជ្រើសរើសគោលបំណងនិងខ្លឹមសារនៃការរៀនដោយផ្អែកលើលក្ខណៈនៃសង្គមសហសម័យ **«អ្វីដែលត្រូវរៀន»** និងដើម្បីកែលម្អវិធីសាស្ត្រអប់រំ និងរបៀបសិក្សាដើម្បីដឹកនាំកុមារឱ្យរៀន និងយល់ពីចំណុចគន្លឹះដោយឯករាជ្យ **«ការកែលម្អនីតិវិធីសិក្សា»**។

ទស្សនៈទាំងពីរនេះនឹងក្លាយជាបញ្ហាប្រឈមក្នុងការបណ្តុះបណ្តាលគ្រូឧទ្ទេស ថ្នាក់និទស្សន៍ និងការគ្រប់គ្រងកម្មវិធីសិក្សា។

## ការពន្យល់បន្ថែម៖ តើមនុស្សជាតិគឺជាអ្វី?

វាគ្មានភាពជាក់លាក់ទេថា មនុស្សជាតិ (HUMANITY) សំដៅលើអ្វីជាប្រាកដនៅក្នុងគោលការណ៍ណែនាំកម្មវិធីសិក្សាថ្នាក់ជាតិរបស់ប្រទេសជប៉ុន។ ដូច្នេះហើយ យើងសូមណែនាំអំពីបញ្ញត្តិនៃការអភិវឌ្ឍមនុស្សពេញលេញ (Whole Person Development (WPD)) ដែលហុងកុងមានបំណងកំណត់យកការអភិវឌ្ឍមនុស្សទាំងស្រុងតាមរយៈការអប់រំនេះសម្រាប់ជាគោលការណ៍ណែនាំក្នុងការកំណត់ប្រភេទគរុនិស្សិតដែលត្រូវអប់រំនៅវិទ្យាស្ថានគរុកោសល្យ (TEC)។

«ការអភិវឌ្ឍមនុស្សពេញលេញ(WPD)» គឺជាគោលបំណងសម្រាប់ការអប់រំប្រកបដោយគុណភាព ហើយបានផ្សព្វផ្សាយដោយរដ្ឋាភិបាលហុងកុងចាប់តាំងពីអំឡុងឆ្នាំ ២០០០ មកម្ល៉េះ។

តំណភ្ជាប់ ០.១៖ https://mwyo.org/en/education_research_details.php?id=45

តំណភ្ជាប់ ០.២៖ https://sa.hkbu.edu.hk/cdc/f/page/1288/8004/WPD_introduction_Eng.pdf

តំណភ្ជាប់ ០.៣៖ https://eduhk.hk/sao/info/wpdi/

តំណភ្ជាប់ ០.១ តំណភ្ជាប់ ០.២ តំណភ្ជាប់ ០.៣

WPD មានធាតុផ្សំចំនួន ៦ ដូចខាងក្រោម៖

- សង្គម (Social) (**ទំនួលខុសត្រូវរបស់ពលរដ្ឋ៖** ឧទាហរណ៍ ការព្រួយបារម្ភអំពីបញ្ហាសង្គមបច្ចុប្បន្ន។ **ការគាំពារសហគមន៍៖** ឧទាហរណ៍ សេវាកម្មស្ម័គ្រចិត្តក្នុងសហគមន៍។ **ការចូលរួមផ្នែកវប្បធម៌៖** ឧទាហរណ៍ ការទទួលស្គាល់ ភាពចម្រុះនៃវប្បធម៌ និងការធ្វើអន្តរកម្មយ៉ាងសកម្មជាមួយប្រជាជនដែលមានសាវតារជនជាតិចម្រុះ។ **ទំនាក់ទំនងគ្រួសារ៖** ឧទាហរណ៍ ការកសាងទំនាក់ទំនងវិជ្ជមានជាមួយសមាជិកគ្រួសារ។ **ទំនាក់ទំនងមិត្តភក្តិ៖** ឧទាហរណ៍ ការកសាង និងរក្សាមិត្តភាពដោយក្ដីស្រឡាញ់ ការយកចិត្តទុកដាក់ និងការយល់ចិត្ត)។
- ខាងស្មារតី (Spiritual) (**ការទទួលស្គាល់សិល្បៈ៖** ឧទាហរណ៍ ការតាំងពិពណ៌សិល្បៈ ការសម្ដែងល្ខោន/តន្ត្រី/របាំ។ **ការប្ដេជ្ញាចិត្តប្រកបដោយសីលធម៌៖** ឧទាហរណ៍ ការឈរយ៉ាងរឹងមាំដោយតម្លៃសីលធម៌(moral values) សីលធម៌សង្គម (social ethics) និងក្រមសីលធម៌វិជ្ជាជីវៈ (professional codes of conduct)។ **ការស្វែងរកខាងស្មារតី (spiritual quest)៖** ឧទាហរណ៍ ការយល់អំពីអត្ថន័យនៃជីវិតនិងការបង្ហាញពីការដឹងគុណ។)
- ផ្លូវចិត្ត (Psychological) (**សុខភាពផ្លូវចិត្ត៖** ឧទាហរណ៍ ការទទួលស្គាល់ ការគ្រប់គ្រង និងការត្រួតត្រាអារម្មណ៍ខ្លួនឯង។ **ការទទួលស្គាល់ខ្លួនឯង៖** ឧទាហរណ៍ ការយល់ដឹង ការទទួលស្គាល់ និងការប្រាកដប្រជាលើខ្លួនឯង។ )
- បញ្ញា (Intellectual) (**សមត្ថភាពបញ្ញា៖** ឧទាហរណ៍ ការពង្រីកចំនេះដឹងទូលំទូលាយនិងការគិតដោយវិភាគរិះគន់ និងច្នៃប្រឌិត។ )
- វិជ្ជាជីវៈ (Professional) (**ការរៀបចំអាជីព៖** ឧទាហរណ៍ ការសម្រេចបាននូវការយល់ដឹងច្បាស់លាស់អំពីចំណាប់អារម្មណ៍ក្នុងអាជីពរបស់បុគ្គល។ **ភាពជាអ្នកដឹកនាំ៖** ឧទាហរណ៍ ការកសាងក្រុម ការលើកទឹកចិត្តមនុស្ស ការរៀបចំសកម្មភាព និងការរួមចំណែកដោយស្មារតីទទួលខុសត្រូវ។ )
- កាយសម្បទា (Physical) (**ការថែទាំសុខភាព៖** ឧទាហរណ៍ សិក្ខាសាលាស្ដីពីការថែទាំសុខភាពការពិនិត្យសុខភាពជាប្រចាំ។ **ភាពរឹងមាំផ្នែកកាយសម្បទា៖** ឧទាហរណ៍ ហាត់ប្រាណជាប្រចាំ និងចូលរួមក្នុងសកម្មភាពរាងកាយផ្សេងៗ។)

សសរស្តម្ភទាំងប្រាំមួយនេះត្រូវបានដាក់បញ្ចូលទៅក្នុងប្រធានបទដែលមាននៅក្នុងសៀវភៅសិក្សាគោលមុខវិជ្ជាសុខភាពសិក្សា ហើយអាចលើកយកមកបង្ហាញក្នុងការអភិវឌ្ឍមនុស្សពេញលេញនៃបរិបទសុខភាពបាន។ លើសពីសសរស្តម្ភទាំងប្រាំមួយនេះ យើងអាចបន្ថែមសសរស្តម្ភនៃការបង្ហាញអំពីការអភិរក្សនិងការថែរក្សាបរិស្ថាននិងអេកូឡូស៊ីក្នុងគ្រាដែលបរិស្ថានពិភពលោកកំពុងជួបវិបត្តិដោយសារសកម្មភាពរបស់មនុស្ស។

## តម្លៃស្នូលរបស់វិទ្យាស្ថានគរុកោសល្យ (TEC) និងសុខភាពសិក្សា

តម្លៃស្នូលទាំងប្រាំរបស់វិទ្យាស្ថានគរុកោសល្យ (TEC)៖ ការគោរព សុចរិតភាព នវានុវត្តន៍ ការប្តេជ្ញាចិត្ត និង ប្រសិទ្ធភាព។ ចូរពិចារណាអំពីរបៀបដែលការអប់រំសុខភាពសិក្សាមានទំនាក់ទំនងទៅនឹងតម្លៃមូលដ្ឋានរបស់វិទ្យាស្ថាន គរុកោសល្យ (TEC)។ តើតម្លៃទាំងនេះត្រូវបង្កប់ដោយរបៀបណាទៅក្នុង គ្រូឧទ្ទេស គរុសិស្ស គរុនិស្សិត និងវិទ្យាស្ថាន គរុកោសល្យទាំងមូលតាមរយៈការបង្រៀន និងការរៀនពីសុខភាពសិក្សានេះ?

- **ការគោរព (Respect)៖** នេះជាតម្លៃទូទៅនៅគ្រប់កម្រិតសិក្សា ប៉ុន្តែនៅក្នុងមេរៀន គ្រូឧទ្ទេសសុខភាពសិក្សា រៀនគោរពគរុនិស្សិត ហើយគរុនិស្សិតរៀនគោរពគរុនិស្សិតដទៃទៀតដែលមានគំនិត ទស្សនៈ និងតម្លៃផ្សេងៗ គ្នាជុំវិញប្រធានបទសុខភាព។ ពេលម្យ៉ាងទៀតគឺគ្រូឧទ្ទេស និងគរុនិស្សិតគោរពភាពចម្រុះរបស់មនុស្ស។ អាកប្បកិរិយា របៀបរស់នៅ និងវប្បធម៌ទាក់ទងនឹងសុខភាពមួយចំនួនមិនចាំបាច់សុទ្ធតែដូចគ្នាជាសាកលនោះ ទេ ពីព្រោះវាបានចាក់ឫសនៅក្នុងសហគមន៍កម្ពុជារួចទៅហើយ។ នៅក្នុងមុខវិជ្ជាសុខភាពសិក្សា គរុនិស្សិត រៀនគោរពជាជាងបដិសេធអ្នកដទៃ ហើយស្វែងរកផ្លូវជីវិតកាន់តែប្រសើរតាមរយៈការប្រាស្រ័យទាក់ទងដែល ស្មើភាពគ្នា។
- **សុចរិតភាព (Integrity)៖** ដំបូង សុខភាពគឺជាបញ្ញត្តិពិពណ៌នាអំពីស្ថានភាពសុខុមាលភាពដែលរួមបញ្ចូល ទាំងទិដ្ឋភាពរាងកាយ ផ្លូវចិត្ត និងសង្គម។ ដូច្នេះការសិក្សាអំពីសុខភាពនាំទៅកាន់ការអភិវឌ្ឍនៃសមត្ថភាព ដើម្បីមើលឃើញមនុស្សថាជាការរួមបញ្ចូលគ្នា (integrated) និងរូបភាពទាំងមូល (holistic) នៃការរួបមួយ។
- **នវានុវត្តន៍ (Innovation)៖** មុខវិជ្ជាសុខភាពសិក្សាគ្មានវត្តមាននៅក្នុងប្រទេសកម្ពុជាទេពីមុនមក វាគឺជាមុខវិជ្ជា ដែលទើបតែបានណែនាំថ្មី។ ដូច្នេះហើយ ការរៀននិងការបង្រៀនអំពីមុខវិជ្ជាសុខភាពសិក្សាគឺជា គម្រោង ប្រកបដោយនវានុវត្តន៍ក្នុងការអប់រំនៅតាមសាលារៀន និងវគ្គគរុកោសល្យនៅប្រទេសកម្ពុជា ពោលគឺជា នវានុវត្តន៍មួយនៅក្នុងប្រព័ន្ធអប់រំនៅតាមសាលារៀន។ ជាងនេះទៅទៀត ចំណេះដឹងផ្នែកវិទ្យាសាស្ត្រអំពី សុខភាពមនុស្សកំពុងតែវិវឌ្ឍឥតឈប់ឈរដែលជាដំណើរការបន្តបន្ទាប់នៃការបង្កើតថ្មី។ ដូច្នេះមុខវិជ្ជាសុខភាព សិក្សាគឺជាមុខវិជ្ជាមួយដែលស្វែងរកនូវការអប់រំដោយផ្អែកលើភស្តុតាងចុងក្រោយបង្អស់ ទាំងវិធីសាស្ត្របង្រៀន និងចំណេះដឹងដែលបានផ្តល់។
- **ការប្តេជ្ញាចិត្ត (Commitment)៖** ប្រសិនបើគ្រូដែលបង្រៀន និងគរុនិស្សិតដែលរៀនមុខវិជ្ជាថ្មីនៃសុខភាពសិក្សា ចូលរួមយ៉ាងសកម្មក្នុងថ្នាក់រៀននោះ សុខភាពសិក្សានឹងទទួលបានជោគជ័យក្លាយជាមុខវិជ្ជាដែលនាំទៅកាន់ សុខភាពរបស់មនុស្ស សង្គម និងបរិស្ថាននៅប្រទេសកម្ពុជាជាមិនខាន។ ដូច្នេះហើយ ការប្តេជ្ញាចិត្តរបស់ គ្រូឧទ្ទេស និងគរុនិស្សិតចំពោះថ្នាក់រៀននេះគឺជាគន្លឹះមួយសម្រាប់ភាពជោគជ័យនៃថ្នាក់សុខភាពសិក្សា។
- **ប្រសិទ្ធភាព (Efficacy)៖** ចំពោះមុខវិជ្ជាសុខភាពសិក្សាមិនគួររៀនត្រឹមតែចំណេះដឹងប៉ុណ្ណោះទេ ប៉ុន្តែត្រូវយក វាមកប្រើប្រាស់ដើម្បីធ្វើឱ្យអាកប្បកិរិយា ជីវិត និងសង្គមកាន់តែមានសុខភាពប្រសើរឡើង។ គោលបំណងនៃ ថ្នាក់សុខភាពសិក្សាគឺដើម្បីអភិវឌ្ឍសមត្ថភាពដើម្បីសម្រេចបាននូវលក្ខខណ្ឌសុខភាពដែលចង់បាននៅកម្រិត

បុគ្គល និងកម្រិតសង្គម។ ថ្នាក់សុខភាពសិក្សារួមចំណែកបង្កើនប្រសិទ្ធភាព និងទំនុកចិត្តរបស់គ្រូឧទ្ទេស និងកុមារក្នុងការសម្រេចបាននូវសុខភាពល្អ។

តាមរយៈការអនុវត្តនេះ មុខវិជ្ជាសុខភាពសិក្សាអាចរួមចំណែកដល់ការអភិវឌ្ឍតម្លៃស្នូលនៃវិទ្យាស្ថានគរុកោសល្យ (TEC) បាន។

## សុខភាពសិក្សានឹងធ្វើឱ្យអក្ខរកម្មរបស់គរុនិស្សិតកាន់តែប្រសើរឡើង

តាមរយៈថ្នាក់សុខភាពសិក្សារបស់វិទ្យាស្ថានគរុកោសល្យ(TEC) គ្រូឧទ្ទេស និងគរុនិស្សិតអាចបង្កើនអក្ខរកម្មដូចខាងក្រោម។ ជាក់ស្តែង អក្ខរកម្មទាំងនេះគួរតែត្រូវបានអភិវឌ្ឍដល់កម្រិតជាក់លាក់មួយរួចទៅហើយគិតមកត្រឹមឆ្នាំទី ៤ នៅពេលដែលគរុនិស្សិតចូលរៀនថ្នាក់សុខភាពសិក្សា។

- **អក្ខរកម្មអក្សរសាស្ត្រ (អាននិងសរសេរ)** (Literary literacy)៖ ពង្រឹងជំនាញអាន និងសរសេរជាភាសាខ្មែរ។
- **អក្ខរកម្មអារម្មណ៍/កាយសម្បទា** (Emotional/Physical literacy)៖ អក្ខរកម្មកាយសម្បទាគឺជាការយល់ដឹងរួមនៃចលនា និងសកម្មភាពរាងកាយ។ អក្ខរកម្មអារម្មណ៍គឺជាសមត្ថភាពក្នុងការយល់ពីអារម្មណ៍របស់បុគ្គលម្នាក់ ហើយបង្ហាញវាទាំងតាមរយៈពាក្យសម្តី និងមិនមែនពាក្យសម្តី។ វាក៏ជាសមត្ថភាពក្នុងការគ្រប់គ្រងអារម្មណ៍របស់មនុស្សម្នាក់ៗផងដែរ។
- **អក្ខរកម្មសុខភាព** (Health literacy)៖ អក្ខរកម្មសុខភាពគឺជាសមត្ថភាពរបស់បុគ្គលម្នាក់ក្នុងការប្រើប្រាស់ព័ត៌មានសុខភាពប្រសើរជាងគ្រាន់តែយល់អំពីវា។ វាក៏ជាសមត្ថភាពក្នុងការធ្វើការសម្រេចចិត្តដោយ«យល់ដឹងព័ត៌មានបានប្រសើរ» ផងដែរ។

តំណភ្ជាប់ ០.៤

(CDC: តំណភ្ជាប់ ០.៤៖ https://www.cdc.gov/healthliteracy/learn/index.html)

- **អក្ខរកម្មស្ថិតិ/អក្ខរកម្មលេខ** (Statisticliteracy/Numericliteracy)៖ អក្ខរកម្មស្ថិតិគឺជាការគិតយ៉ាងសំខាន់ស៊ីជម្រៅអំពីលេខ ស្ថិតិដែលបានប្រើប្រាស់ជាភស្តុតាងក្នុងការជជែកវែកញែក។ វាក៏សំដៅលើសមត្ថភាពក្នុងការអាន និងបកស្រាយលេខនៅក្នុងសេចក្តីថ្លែងការណ៍ ការស្ទង់មតិតារាង និងក្រាហ្វផងដែរ។

តំណភ្ជាប់ ០.៥

(តំណភ្ជាប់ ០.៥៖ http://www.statlit.org/pdf/2010Schield-StatLit-Intro4p.pdf)

- **អក្ខរកម្មអេកូសុខភាព** (Ecological health literacy)៖ វាគឺជាសមត្ថភាពក្នុងការគិតជាប្រព័ន្ធ និងវិភាគអំពីបញ្ហាសុខភាពសហសម័យតាមរយៈទស្សនៈស្របតាមការអភិវឌ្ឍសេដ្ឋកិច្ចសង្គម អេកូឡូស៊ី និងបរិស្ថានជីវភាពរស់នៅរបស់មនុស្ស និងសុខភាព។

# អ្វីដែលត្រូវរៀន

## ១. ស្វែងយល់អំពីរចនាសម្ព័ន្ធមូលដ្ឋាននៃសៀវភៅសិក្សាគោល ផ្លាស់ប្តូរគំនិត ព័ត៌មាន ជាមួយគរុនិស្សិតរបស់អ្នក

### ១.១. ផ្តល់ជូនគរុនិស្សិតនូវទស្សនៈ និងជំរុញការចង់ដឹងចង់ឃើញរបស់ពួកគេ

សៀវភៅសិក្សាគោល «សុខភាពសិក្សាសម្រាប់ទាំងអស់គ្នា» រួមបញ្ចូលដោយ សេចក្តីផ្តើម និង ១៦ ជំពូក។ សូមស្វែងយល់ពីរបៀបដែលជំពូកនីមួយៗត្រូវបានរៀបចំ និងចំណុចគន្លឹះៗរបស់វា ព្រមទាំងរបៀបដែលជំពូកនីមួយៗមានទំនាក់ទំនងគ្នាទៅវិញទៅមក។ គ្រូឧទ្ទេសគួរពន្យល់ពីរចនាសម្ព័ន្ធមូលដ្ឋានដល់គរុនិស្សិតនិងផ្តល់ទស្សនៈដល់ពួកគេអំពីអ្វីដែលពួកគេនឹងត្រូវរៀន។ ត្រឹមតែទិដ្ឋភាពទូទៅនៃប្រធានបទទាំងនេះក៏នឹងនាំឱ្យគរុនិស្សិតមានការរំពឹងទុកខ្ពស់សម្រាប់មុខវិជ្ជាថ្មីដែលពួកគេនឹងរៀននេះដែរ។

ការជំរុញចំណាប់អារម្មណ៍និងការចង់ដឹងចង់ឃើញរបស់គរុនិស្សិតអាស្រ័យទៅលើការធ្វើឱ្យពួកគេដឹងថា ប្រធានបទដែលមាននៅក្នុងអត្ថបទនេះមានទំនាក់ទំនងយ៉ាងជិតស្និទ្ធទៅនឹងជីវិតជាក់ស្តែងរបស់ពួកគេ ទាំងរបៀបរស់នៅ សុខុមាលភាព ក៏ដូចជាការអភិវឌ្ឍសាលារៀន និងសង្គមនាពេលអនាគត។

### ១.២. រចនាសម្ព័ន្ធនៃអត្ថបទ និងរបៀបប្រើប្រាស់សៀវភៅសិក្សាគោល

សូមស្វែងយល់អំពីរចនាសម្ព័ន្ធនៃសៀវភៅសិក្សាគោលនេះដោយប្រុងប្រយ័ត្ន ហើយប្រើវាដើម្បីបង្កើនការយល់ដឹងរបស់អ្នកអំពីប្រធានបទនីមួយៗ។ នៅក្រោមចំណងជើងនៃជំពូកនីមួយៗមានបង្ហាញអំពីគោលបំណងសិក្សា។ សូមអ្នកប្រាកដថាបានពិនិត្យមើលគោលបំណងសិក្សាសម្រាប់ជំពូកនីមួយៗ។

**[ឧទាហរណ៍] ជំពូកទី ១៖ សុខភាព**

**■ គោលបំណងមេរៀន**

អ្នកសិក្សានឹងអាចយល់ និងពន្យល់អំពី៖
- និយមន័យ និងទិដ្ឋភាពផ្សេងៗនៃសុខភាព
- សារៈសំខាន់ និងអត្ថប្រយោជន៍នៃកម្មវិធីអប់រំសុខភាពនៅតាមសាលា
- សារៈសំខាន់នៃការអនុវត្តសកម្មភាពសុខភាពសិក្សា
- គោលនយោបាយស្តីពីសុខភាពសិក្សា និងគំនិតផ្តួចផ្តើមនានាដែលបានដាក់ឱ្យប្រើប្រាស់នៅក្នុងប្រទេសកម្ពុជា

នៅខាងក្រោមគោលបំណងសិក្សាមានសេចក្តីសង្ខេបខ្លឹមសារសម្រាប់ជំពូកនីមួយៗ។ សូមរៀបចំសម្រាប់ការសិក្សាដោយអាន និងស្វែងយល់អំពីសេចក្តីសង្ខេបខ្លឹមសារនូវអ្វីដែលអ្នកនឹងរៀននៅក្នុងជំពូកនេះ។

ជំពូកនេះផ្ដល់នូវចំណេះដឹងមូលដ្ឋានចាំបាច់ដើម្បីស្វែងយល់ពីសុខភាពមនុស្ស និងគំនិតផ្ដួចផ្ដើមអំពីសុខភាពសិក្សា។ ដំបូង យើងណែនាំពីទស្សនៈសុខភាពមូលដ្ឋាន និងគំនិតថ្មីៗមួយចំនួន ហើយគូសបញ្ជាក់ថា សុខភាពគឺជាសិទ្ធិមូលដ្ឋានរបស់មនុស្ស។ បន្ទាប់មកយើងពន្យល់ពីទស្សនៈសុខភាពរបស់កុមារដោយផ្អែកលើលក្ខណៈនៃការវិវឌ្ឍរបស់កុមារ។ យើងក៏បង្ហាញផងដែរនូវនិន្នាការសកលឆ្ពោះទៅរកការលើកកម្ពស់សុខភាព និងការកសាងសង្គមដែលមានសុខភាពល្អ និងពណ៌នាអំពីសារៈសំខាន់នៃគំនិតផ្ដួចផ្ដើមសុខភាពសិក្សា សរសរស្ដម្ភទាំងបួន និងគោលនយោបាយសុខភាពសិក្សានៅក្នុងប្រទេសកម្ពុជា។

សេចក្ដីសង្ខេបខ្លឹមសារត្រូវបានបន្តដោយអត្ថបទចម្បង។ ពេលវេលាគឺមិនគ្រប់គ្រាន់ដើម្បីបង្រៀនខ្លឹមសារទាំងអស់នៃជំពូកនីមួយៗនោះទេ។ ដូច្នេះសេចក្ដីថ្លែងការសង្ខេបត្រូវបានបង្ហាញជាបន្ទាប់ដោយផ្ដោតលើខ្លឹមសារដែលត្រូវបង្រៀនក្នុងជំពូកនីមួយៗ និងពន្យល់ពីទំនាក់ទំនងរបស់វាទៅនឹងជំពូកផ្សេងៗទៀត។ សេចក្ដីព្រាងផែនការមេរៀនសម្រាប់ជំពូកនីមួយៗត្រូវបានលើកយកមកបង្ហាញជាបន្តបន្ទាប់។

ពាក្យសំខាន់ៗនៅក្នុងសៀវភៅសិក្សាត្រូវបានបង្ហាញជា «អក្សរដិត»។ ទាំងនេះគឺជាពាក្យគន្លឹះនិងឃ្លាសំខាន់ៗ។ លើសពីនេះទៅទៀត សេចក្ដីថ្លែងការសំខាន់ៗត្រូវបាន «គូសបន្ទាត់ពីក្រោម» ពីព្រោះវាគឺជាចំណុចដែលយើងចង់ឱ្យអ្នកអានយល់។

គ្រប់ជំពូកទាំងអស់ លើកលែងតែជំពូកទី ៣ មាន «អត្ថបទដកស្រង់» សរសេរក្នុងអត្ថបទ។ អត្ថបទដកស្រង់មានគោលបំណងអភិវឌ្ឍខ្លឹមសារនៃអត្ថបទ ផ្ដល់ព័ត៌មានបន្ថែម ឬពង្រីកចំណាប់អារម្មណ៍របស់អ្នកអានឱ្យកាន់តែទូលំទូលាយ។ ប្រសិនបើចាំបាច់ វាអាចត្រូវបានណែនាំនៅក្នុងការបង្រៀន ប៉ុន្តែគរុនិស្សិតត្រូវបានលើកទឹកចិត្តឱ្យអានវារួមជាមួយនឹងអត្ថបទនៅពេលរៀបចំនិងពិនិត្យមើលកម្មវិធីសិក្សា។ អត្ថបទត្រូវបានបន្តដោយ «លំហាត់សម្រាប់ការគិត និងការស្រាវជ្រាវបន្ថែម»។ កិច្ចការទាំងនេះ ខ្លះអាចត្រូវបានប្រើជាកិច្ចការដើម្បីដឹកនាំគរុនិស្សិតឱ្យអាននិងគិតអំពីអត្ថបទអំឡុងពេលរៀបចំមុនពេលសិក្សា(វគ្គ ៥០នាទី ទាំងពីរ)។ វាក៏អាចត្រូវបានប្រើជាប្រធានបទសម្រាប់ការងារជាក្រុម ឬការឆ្លើយសំណួរឆ្លើយឆ្លងរវាងគ្រូឧទ្ទេស និងគរុនិស្សិត។ ដោយផ្អែកលើកម្រិតនៃការយល់ដឹងជាក់ស្ដែងរបស់គរុនិស្សិត ខ្លឹមសារអាចធ្វើឱ្យសាមញ្ញ ហើយការពន្យល់អាចបន្ថែមបានតាមការចាំបាច់។

## លំហាត់សម្រាប់ការគិត និងការស្រាវជ្រាវបន្ថែម

[១-១] ចូរគិតថា តើអ្វីទៅជាសុខភាព ហើយតើលក្ខខណ្ឌបែបណាដែលបង្ហាញពីសុខភាពល្អ ហើយសម្រាប់អ្នកផ្ទាល់។

[១-២] ចូរពិចារណាតើមូលហេតុអ្វីបានជាសាលារៀនចាំបាច់ត្រូវមានកម្មវិធីបង្រៀនកុមារអំពីសុខភាព និងជំងឺ។

[១-៣] ចូរពិនិត្យមើលថា តើសង្គមកម្ពុជាមានទស្សនៈយ៉ាងណាចំពោះជំងឺ។

[១-៤] ចូរពិភាក្សាជាក្រុមដើម្បីរិះរកថា តើសាលារៀននៅប្រទេសកម្ពុជាអាចធ្វើអ្វីបានខ្លះដើម្បីលើកកម្ពស់សុខភាពកុមារដោយឆ្លុះបញ្ចាំងពីបទពិសោធន៍ផ្ទាល់ខ្លួនរបស់អ្នក។

ចុងក្រោយ មានផ្ដល់ជូននៅខាងចុងជំពូកនីមួយៗនូវបញ្ជី «ឯកសារយោង» ដែលមានលើកឡើងនៅក្នុងអត្ថបទ។ កង្វះអត្ថបទអក្សរសិល្ប៍ជាភាសាខ្មែរគឺជាបញ្ហាប្រឈមមួយ។ បញ្ហាប្រឈមមួយទៀតគឺអក្សរសិល្ប៍ជាភាសាជប៉ុនរួមចំណែកយ៉ាងធំនៅក្នុងជំពូកខ្លះ។ ដូច្នេះហើយ ក្នុងការរៀបចំមេរៀន យើងរំពឹងថា លោកគ្រូអ្នកគ្រូទទួលបន្ទុកបង្រៀននីមួយៗនឹងខិតខំស្វែងរកបន្ថែមនូវអក្សរសិល្ប៍ខ្មែរ រូបភាព និងវីដេអូដែលងាយយល់។ ដើម្បីឱ្យលោកគ្រូអ្នកគ្រូស្រាវជ្រាវរកឯកសារបានដោយខ្លួនឯង គាត់ត្រូវមានកម្រិតអក្ខរកម្មខ្ពស់អំពីសុខភាពខ្លួនឯងផ្ទាល់ ក៏ដូចជាអំពីសុខភាពសិក្សាផងដែរ។ វាចាំបាច់ណាស់ក្នុងការយល់ច្បាស់អំពីខ្លឹមសារនៃអត្ថបទនេះ។


References

1 World Health Organization Constitution. https://www.who.int/about/who-we-are/constitution
2 Asakura T, Mallee H, Tomokawa S, Moji K, and Kobayashi J. The ecosystem approach to health is a promising strategy in international development: lessons from Japan and Laos. Global Health. 2015; 11: 3. doi: 10.1186/s12992-015-0093-0.
3 Huber M, Knottnerus J A, Green L, et al. How should we define health? BMJ 2011;343:d4163. doi: 10.1136/bmj.d4163.
4 World Health Organization 101st Session Agenda item 7.3. Review of the Constitution of the World Health Organization: report of the Executive Board special group. EB101.R2, 1998. https://apps.who.int/gb/archive/pdf_files/EB101/pdfangl/angr2.pdf
5 Australian Medical Association. Developmental Health and Wellbeing of Australia's Children and Young People - revised 2010. https://ama.com.au/position-statement/developmental-health-and-wellbeing-australia%E2%80%99s-children-and-young-people-revised
6 Lalonde M. A New Perspective on the Health of Canadians -a working document. Minister of Supply and Services Canada, 1981. https://www.phac-aspc.gc.ca/ph-sp/pdf/perspect-eng.pdf
7 Lalonde report. https://en.wikipedia.org/wiki/Lalonde_report.
8 World Health Organization. Health Promotion: The Ottawa Charter for Health Promotion. https://www.who.int/healthpromotion/conferences/previous/ottawa/en/
9 World Health Organization. Health Promotion: The Bangkok Charter for Health Promotion in a Globalized World (11 August 2005). https://www.who.int/healthpromotion/conferences/6gchp/bangkok_charter/en/


## ១.៣. ការស្ទង់មតិលើសុខភាព និងរបៀបរស់នៅរបស់គរុនិស្សិតវិទ្យាស្ថានគរុកោសល្យ (TEC)

ការស្ទង់មតិអំពីសុខភាព និងរបៀបរស់នៅរបស់គរុនិស្សិតវិទ្យាស្ថានគរុកោសល្យ (TEC) បានធ្វើឡើងជាមួយគរុនិស្សិតឆ្នាំទី ៤ នៃវិទ្យាស្ថានគរុកោសល្យរាជធានីភ្នំពេញ(PTEC)និងវិទ្យាស្ថានគរុកោសល្យបាត់ដំបង(BTEC) នៅអំឡុងខែឧសភា និងមិថុនា ឆ្នាំ២០២២។ ការស្ទង់មតិបានអង្កេតអំពីអាកប្បកិរិយាបែបវេជ្ជសាស្ត្ររបស់គរុនិស្សិតវិទ្យាស្ថានគរុកោសល្យ(TEC) ក៏ដូចជាអាកប្បកិរិយាចំពោះការផឹកគ្រឿងស្រវឹង អាកប្បកិរិយាចំពោះអាហារូបត្ថម្ភ ការជក់បារី ការធ្វើលំហាត់ប្រាណ អាកប្បកិរិយាចំពោះការស្វែងរកព័ត៌មានសុខភាពដោយប្រើប្រាស់អ៊ីនធឺណែត អាកប្បកិរិយាចំពោះសុវត្ថិភាព សុខភាពផ្លូវចិត្ត ការគាំទ្រសង្គម រោគសញ្ញាផ្លូវចិត្ត និងការវាយតម្លៃសុខភាពខ្លួនឯង។ ការវិភាគទិន្នន័យនេះនឹងផ្តល់នូវការយល់ដឹងខ្លះៗអំពីសុខភាព និងអាកប្បកិរិយាជាក់ស្ដែងរបស់គរុនិស្សិតនៅវិទ្យាស្ថានគរុកោសល្យនៅប្រទេសកម្ពុជា។ យើងក៏ផ្ដល់ការបណ្ដុះបណ្ដាលក្នុងការប្រើប្រាស់កម្មវិធីវិភាគទិន្នន័យស្ថិតិដើម្បីការវិភាគទិន្នន័យប្រភេទនេះផងដែរ។ នាពេលអនាគត វានឹងចាំបាច់ក្នុងការប្រមូលទិន្នន័យរបស់គរុនិស្សិតវិទ្យាស្ថានគរុកោសល្យ(TEC) ទាំងអស់ព្រមទាំងទិន្នន័យអំពីសិស្សកម្រិតបឋមសិក្សា អនុវិទ្យាល័យ និងវិទ្យាល័យផងដែរ។

## ២. ទិដ្ឋភាពទូទៅនៃជំពូកនីមួយៗនិងការភ្ជាប់ទំនាក់ទំនង/ចំណុចគន្លឹះនៃជំពូកនីមួយៗ

- សេចក្តីផ្តើម និងជំពូកទី ១

**នៅក្នុងសេចក្តីផ្តើម និងជំពូកទី ១** អ្នកនឹងរៀនពីនិយមន័យនៃសុខភាពមនុស្ស អត្ថន័យនៃការរស់នៅប្រកបដោយសុខភាពល្អ និងលើសពីនេះទៀតគឺគំនិតផ្តួចផ្តើមសុខភាពនៅក្នុងសាលារៀន និងសង្គមដើម្បីជួយមនុស្សឱ្យរស់នៅប្រកបដោយសុខភាពល្អ។ បញ្ញត្តិនៃសុខភាព ជាពិសេសក្នុងអំឡុងឆ្នាំនៃការអភិវឌ្ឍលូតលាស់ គឺជាចំណុចគន្លឹះសម្រាប់គ្រូកម្រិតបឋមសិក្សាស្វែងយល់។

នៅក្នុងជំពូកទាំងពីរនេះ ចាំបាច់ត្រូវយល់អំពីលក្ខណៈនៃសុខភាពសិក្សាថាជាមុខវិជ្ជាមួយ (លក្ខណៈសុខភាពជាមុខវិជ្ជាសិក្សា) ដែលសុខភាព គឺជាសិទ្ធិជាមូលដ្ឋានរបស់មនុស្ស ហើយនិយមន័យសុខភាពរបស់អង្គការសុខភាពពិភពលោក និងការលើកកម្ពស់សុខភាព (កាតិកាសញ្ញាអូតាវ៉ាសម្រាប់ការលើកកម្ពស់សុខភាព) គួរតែត្រូវបានយល់ថាជាចំណេះដឹងចាំបាច់។

ទស្សនវិស័យអេកូឡូស៊ីលើសុខភាពត្រូវបានសិក្សានៅក្នុងជំពូកទី ១៣ បរិស្ថាននិងសុខភាព/អេកូសុខភាព ដូច្នេះហើយចំណុចនេះអាចត្រូវបានលុបចោលពីការពន្យល់លម្អិតនៅក្នុងជំពូកទី ១។

- ជំពូកទី២

យើងនឹងរៀននៅក្នុងជំពូកទី១ ថាសុខភាពមនុស្សមានទិដ្ឋភាពជីវសាស្ត្រ ផ្លូវចិត្ត សង្គម និងខាងស្មារតី ខណៈដែលជំពូកទី២នឹងសិក្សាពីមូលដ្ឋានជីវសាស្ត្រនៃសុខភាពមនុស្ស។ ជំពូកនេះគ្របដណ្តប់លើរចនាសម្ព័ន្ធជាមូលដ្ឋាននៃរាងកាយរបស់មនុស្សនិងមុខងាររបស់វាដែលគាំទ្រសកម្មភាពជីវិតរបស់មនុស្ស។ គរុនិស្សិតនឹងសិក្សាអំពីសកម្មភាពរាងកាយប្រចាំថ្ងៃដែលត្រូវបានគាំទ្រដោយមុខងារនៃប្រព័ន្ធសរីរាង្គចំនួន ១០ រួមទាំងប្រព័ន្ធម៉ូទ័រនិងប្រព័ន្ធសរសៃឈាមបេះដូង ដែលសរីរាង្គទាំងនោះមានមុខងារសម្របសម្រួល និងធ្វើកិច្ចសហប្រតិបត្តិការដើម្បីធ្វើឱ្យរាងកាយមនុស្សមានមុខងារចុះសម្រុងគ្នា។ រចនាសម្ព័ន្ធ និងមុខងារជាមូលដ្ឋាននៃរាងកាយរបស់មនុស្សដែលបានសិក្សានៅទីនេះនឹងក្លាយជាមូលដ្ឋានគ្រឹះសម្រាប់ការយល់ដឹងពីជំងឺឆ្លង ជំងឺទាក់ទងនឹងរបៀបរស់នៅនិងជំងឺផ្សេងៗទៀត (ជំពូកទី ៦ និងទី ៧) និងការសង្គ្រោះបឋមនៅតាមសាលារៀន (ជំពូកទី ១៥) ដែលនឹងត្រូវបានគ្របដណ្តប់ក្នុងជំពូកជាបន្តបន្ទាប់។

- ជំពូកទី ៣

គោលដៅចម្បងនៃសុខភាពសិក្សាគឺសិស្សកម្រិតបឋមសិក្សារហូតដល់សិស្សកម្រិតវិទ្យាល័យ។ លើសពីនេះទៅទៀតសម្រាប់កុមារតូចៗដែលជាកម្មវត្ថុនៃការអប់រំមត្តេយ្យសិក្សាក៏គួរមានការពិចារណាលើការដាក់បញ្ចូលមុខវិជ្ជាសុខភាពសិក្សានេះផងដែរ។ កុមារនៅក្នុងក្រុមអាយុទាំងនេះគឺជាមនុស្សនៅក្នុងដំណើរការអភិវឌ្ឍលូតលាស់រហូតដល់ពេញវ័យ។ មូលដ្ឋានជីវសាស្ត្រនៃសុខភាពមនុស្សដែលបានសិក្សានៅក្នុងជំពូកទី ២ ត្រូវបានសន្មតជាចម្បងនៅដំណាក់កាលពេញវ័យផងដែរ។ ទោះជាយ៉ាងណាក៏ដោយ ទិដ្ឋភាពជីវសាស្ត្រ ផ្លូវចិត្ត សង្គម និងខាងស្មារតីដែលបង្កើតឱ្យមានសុខភាពរបស់មនុស្សនឹងផ្លាស់ប្តូរពេញមួយជីវិត។ នៅក្នុងជំពូកទី ៣ យើងនឹងសិក្សាពីការផ្លាស់ប្តូរនេះក្នុងន័យទាក់ទងនឹងបញ្ញត្តិនៃការលូតលាស់ និងការអភិវឌ្ឍ។ ជំពូកនេះផ្តោតលើការលូតលាស់ និងការអភិវឌ្ឍតាំងពីតូចរហូតបញ្ចប់កម្រិតបឋមសិក្សានៅអំឡុងអាយុប្រហែល ១២ឆ្នាំ ពោលគឺការផ្លាស់ប្តូរផ្នែករាងកាយ ម៉ូទ័រ ការយល់ដឹង សមត្ថភាពផ្លូវចិត្ត និងសង្គម។ សុខភាពក្នុង

ការលូតលាស់និងការអភិវឌ្ឍរបស់មនុស្សគឺជាដំណើរការដ៏ស្វាហាប់ ហើយសុខភាពរបស់កុមារគួរតែត្រូវបានតាមរយៈទស្សនៈថា តើពួកគេកំពុងដើរតាមគន្លងនៃការលូតលាស់និងការអភិវឌ្ឍសមស្របដែរឬទេ ? ។ ដើម្បីវាយតម្លៃការលូតលាស់និងកាអភិវឌ្ឍចាំបាច់ត្រូវរៀនអំពីគោលការណ៍របស់វាដែលត្រូវបានពន្យល់នៅក្នុងជំពូកនេះ ។

លើសពីនេះទៅទៀត ការអភិវឌ្ឍរបស់ភ្នែកនិងធ្មេញដើម្បីយល់ដឹងអំពីសុខភាពភ្នែក និងសុខភាពមាត់ធ្មេញដែលនឹងលើកមកនៅជំពូកទី ៨ ។

- **ជំពូកទី ៤**

ដើម្បីទប់ស្កាត់ការឆ្លងជំងឺ ការពុលចំណីអាហារ ការរងរបួស និងគ្រោះថ្នាក់ វាមានសារៈសំខាន់ណាស់ក្នុងការថែរក្សារាងកាយ អាហារ និងបរិស្ថាននៅជិតឱ្យបានស្អាត មានអនាម័យ និងសុវត្ថិភាព។ ជំពូកទី ៤ ផ្តោតលើមូលដ្ឋាននៃការរស់នៅដើម្បីតម្រូវគោលបំណងខាងលើនេះ។ ជាដំបូង គរុនិស្សិតនឹងលើកកម្ពស់ការយល់ដឹងជាមូលដ្ឋានរបស់ពួកគេអំពីភាពស្អាត និងអនាម័យ ហើយបន្ទាប់មករៀនពីការអនុវត្តជាក់លាក់ដើម្បីជួយកុមាររៀបចំខ្លួនប្រាណ អាហារ និងជុំវិញផ្ទះ ថ្នាក់រៀន និងសហគមន៍មូលដ្ឋានឱ្យបានស្អាត មានអនាម័យ និងសុវត្ថិភាព។

- **ជំពូកទី ៥**

ម៉្យាងវិញទៀត អាយុរបស់សិស្សកម្រិតបឋមសិក្សាគឺជាពេលវេលាដ៏សំខាន់សម្រាប់ពួកគេក្នុងការទទួលបានទម្លាប់របៀបរស់នៅជាមូលដ្ឋាន។ សំខាន់ជាងនេះទៅទៀត យើងត្រូវយល់ពីរបៀបដែលទម្លាប់របៀបរស់នៅជាមូលដ្ឋានប៉ះពាល់ដល់ការអភិវឌ្ឍសុខភាពរបស់កុមារដែលយើងបានសិក្សានៅជំពូកទី ៣។ ដូច្នេះហើយ នៅក្នុងជំពូកទី ៥ យើងនឹងសិក្សាពីទំនាក់ទំនងរវាងការលូតលាស់ និង ការអភិវឌ្ឍ និង ទម្លាប់របៀបរស់នៅទាក់ទងនឹងចង្វាក់នៃជីវិតប្រចាំថ្ងៃ ការហាត់ប្រាណ អាហារ/អាហារូបត្ថម្ភ និងការទទួលទានដំណេក។ គួរកត់សម្គាល់ថា ស្ថានភាពជាក់ស្តែងរបស់កុមារកម្ពុជាមានបញ្ហាមួយចំនួនទាក់ទងនឹងការអនុវត្តសកម្មភាពរាងកាយដែលមានសុខភាពល្អ របបអាហារ និងអាហារូបត្ថម្ភដែលមានសុខភាពល្អ ហើយចំណុចទាំងនេះគួរតែត្រូវយល់ច្បាស់តាមរយៈខ្លឹមសារនៃជំពូកនេះ។

- **ជំពូកទី ៦**

បញ្ហាប្រឈមក្នុងអំឡុងឆ្នាំនៃការអភិវឌ្ឍគឺការស្វែងយល់និងទទួលបានទម្លាប់របៀបរស់នៅដែលមានសុខភាពល្អដូចដែលយើងបានរៀននៅក្នុងជំពូកទី៥។ ទោះជាយ៉ាងណាក៏ដោយ វាមិនមែនងាយស្រួលទេក្នុងការថែរក្សារបៀបរស់នៅដែលមានសុខភាពល្អ។ នៅពេលដែលមនុស្សចាប់ផ្តើមជីវិតរបស់ពួកគេនៅក្នុងសង្គមមនុស្សពេញវ័យ ពួកគេច្រើនតែបង្កើតទម្លាប់របៀបរស់នៅដែលមានផលប៉ះពាល់ដែលមិនចង់បានដល់សុខភាពរបស់ពួកគេទាក់ទងនឹងការជក់បារី ការផឹកគ្រឿងស្រវឹង និងទម្លាប់ទទួលទានអាហារ។ រហូតមកដល់ពេលថ្មីៗនេះ ជំងឺឆ្លងនៅប្រទេសកម្ពុជាដូចជា ជំងឺគ្រុនចាញ់ ជំងឺគ្រុនឈាម និងជំងឺរាកគឺជាមូលហេតុចម្បងនៃការស្លាប់ ខណៈជំងឺទាក់ទងនឹងរបៀបរស់នៅដូចជា ជំងឺសរសៃឈាមខួរក្បាលនិងជំងឺក្រិនថ្លើមបានបណ្តាលឱ្យមានអ្នកស្លាប់យ៉ាងច្រើន។ ដូច្នេះហើយ នៅក្នុងជំពូកទី៦នេះ យើងនឹងពន្យល់ពីការផ្លាស់ប្តូរនៃមូលហេតុនៃការស្លាប់នៅប្រទេសកម្ពុជា និងលក្ខណៈនៃជំងឺសំខាន់ៗទាក់ទងនឹងរបៀបរស់នៅ។ ជាពិសេស ទំនាក់ទំនងរវាងសន្ទស្សន៍ម៉ាសរាងកាយ(BMI)និងអត្រាមរណៈបង្ហាញពីសារៈសំខាន់នៃការគ្រប់គ្រងទម្ងន់រាងកាយឱ្យបានត្រឹមត្រូវ។

ភាពធាត់ក៏កំពុងកើនឡើងដែរប៉ុន្តែការយល់ដឹង និងដំណោះស្រាយសម្រាប់បញ្ហាអាហារនិងអាហារូបត្ថម្ភកង្វះអាហារូបត្ថម្ភ និងជំងឺកង្វះឈាមក្រហមនៅតែជាបញ្ហាសុខភាពសិក្សាដ៏សំខាន់ដែលត្រូវយល់ផងដែរ។ BMI ត្រូវបានគណនា ហើយវាយតម្លៃដោយការរៀនពីរបៀបវាស់កម្ពស់ និងថ្លឹងទម្ងន់នៅក្នុងជំពូកទី ៩ ក្នុងសារៈសំខាន់ និងវិធីសាស្ត្រនៃការពិនិត្យរាងកាយផងដែរ។

ជំងឺអញ្ចាញធ្មេញគឺជាជំងឺទាក់ទងនឹងរបៀបរស់នៅដែលអាចលើកយកមកបង្រៀននៅក្នុងជំពូកទី ៨ ដោយសាររចនាសម្ព័ន្ធនៃធ្មេញត្រូវបានសិក្សាលម្អិតនៅក្នុងជំពូកទី ៨ សុខភាពភ្នែកនិងសុខភាពមាត់ធ្មេញ។

- **ជំពូកទី ៧**

ជំពូកទី ៧ គ្របដណ្តប់លើការបង្ការជំងឺឆ្លង។ ដើម្បីស្វែងយល់ពីជំងឺឆ្លង និងការបង្ការជំងឺ ដំបូងត្រូវសិក្សាពីយន្តការមូលដ្ឋានពីការបង្ករោគរហូតដល់ការចាប់ផ្តើមនៃជំងឺ ហើយសិក្សាអំពីយន្តការនៃរបាំងការពាររាងកាយរបស់មនុស្សប្រឆាំងនឹងមេរោគ។ គរុនិស្សិតនឹងរៀនពីអ្វីដែលពួកគេអាចធ្វើបានជាបុគ្គល ជាសាលារៀន និងជាសហគមន៍ដើម្បីបង្ការជំងឺឆ្លង។ ដើម្បីទប់ស្កាត់ការឆ្លងនីមួយៗ ជំងឺឆ្លងសំខាន់ៗនៅប្រទេសកម្ពុជាត្រូវបានលើកយកមកពិពណ៌នាដើម្បីឱ្យគរុនិស្សិតមានចំណេះដឹងអំពីមូលហេតុ រោគសញ្ញា និងការឆ្លើយតបទៅនឹងជំងឺទាំងនេះ។

- **ជំពូកទី ៨**

ជំពូកទី ៨ ផ្តោតលើសុខភាពភ្នែក និងសុខភាពធ្មេញដែលមានសារៈសំខាន់ក្នុងវ័យកុមារភាព។ នៅក្នុងសុខភាពភ្នែក បន្ទាប់ពីស្វែងយល់ពីរចនាសម្ព័ន្ធមូលដ្ឋាននៃភ្នែក និងរបៀបដែលយើងមើលឃើញ យើងរៀនអំពីជំងឺភ្នែក និងជំងឺផ្សេងៗ។ ទោះបីជាជំពូកនេះបានពិភាក្សាអំពីជំងឺភ្នែកពេញវ័យដែលអាចប៉ះពាល់ដល់គរុនិស្សិត និងក្រុមគ្រួសាររបស់ពួកគេក៏ដោយ ប៉ុន្តែបញ្ហាសុខភាពភ្នែកសំខាន់ៗក្នុងមុខវិជ្ជាសុខភាពសិក្សាគឺផ្តោតលើ ជំងឺភ្នែកឡើងបាយ និងកំហុសកំណុំ។ ពួកគេគួរតែយល់ឱ្យបានច្បាស់អំពី ការប្រើប្រាស់វ៉ែនតា និង កែវភ្នែកសិប្បនិម្មិតដើម្បីកែតម្រូវចំពោះកំហុសកំណុំនិងឥរិយាបថនៃការមើល កម្រិតពន្លឺ និងទម្លាប់សម្រាកភ្នែកដើម្បីការពារភ្នែក។ ការធ្វើតេស្តភាពច្បាស់នៃគំហើញដើម្បីកំណត់កំហុសកំណុំត្រូវបានរៀនអនុវត្តនៅក្នុងជំពូកទី៩ ក្នុងសារៈសំខាន់ និងវិធីសាស្ត្រនៃការពិនិត្យរាងកាយផងដែរ។

- **ជំពូកទី ៩**

នៅក្នុងជំពូកទី ៩ អ្នកនឹងរៀនពីរបៀបធ្វើការពិនិត្យសុខភាពដែលអាចអនុវត្តបានយ៉ាងងាយស្រួលនៅតាមសាលារៀននៅប្រទេសកម្ពុជាដែលគ្មានឧបករណ៍គ្រប់គ្រាន់។ ការពិនិត្យសុខភាពក្នុងជំពូកនេះរួមមាន ការវាស់កម្ពស់ ថ្លឹងទម្ងន់ វាស់គំហើញ និងវាស់ការឮ។ គរុនិស្សិតនឹងរៀនអំពីឧបករណ៍ និងការប្រើប្រាស់របស់វា ការរៀបចំ និងលំហូរនៃការពិនិត្យសុខភាព វិធីសាស្ត្រកត់ត្រា និងរបៀបប្រើប្រាស់កំណត់ត្រា ដើម្បីឱ្យពួកគេអាចធ្វើការពិនិត្យសុខភាពនៅសាលាដែលពួកគេចេញធ្វើការបន្ទាប់ពីបញ្ចប់ការសិក្សា។ លើសពីនេះទៅទៀត គរុនិស្សិតនឹងរៀនពីរបៀបប្រើប្រាស់ផ្ទាំងរូបភាពនិងសម្ភារៈផ្សេងៗទៀតដែលពន្យល់ពីសារៈសំខាន់នៃការពិនិត្យសុខភាពដើម្បីជូនដំណឹងដល់សិស្សានុសិស្ស លោកគ្រូអ្នកគ្រូ ឪពុកម្តាយ និងសហគមន៍។

វាជាការចាំបាច់ក្នុងការពិនិត្យឡើងវិញនូវជំពូកទី ៣, ៦ និង ៨ ដើម្បីឱ្យគរុនិស្សិតកំណត់ថាតើកុមារធ្វើតាមការលូតលាស់ និងការអភិវឌ្ឍប្រកបដោយសុខភាពល្អដោយផ្អែកលើការយល់ដឹងអំពីការលូតលាស់ និងការអភិវឌ្ឍរាងកាយ។

- **ជំពូកទី ១០**

ដូចនៅក្នុងជំពូកទី ៥ ដែរ យើងបានរៀនអំពីសារៈសំខាន់នៃការបង្កើតទម្លាប់របៀបរស់នៅប្រកបដោយសុខភាពល្អ។ ម្យ៉ាងវិញទៀត នៅក្នុងជំពូកទី ៦ យើងបានរៀនអំពី «ជំងឺបណ្ដាលមកពីរបៀបរស់នៅ» វាមានការពិបាកក្នុងការរក្សារបៀបរស់នៅប្រកបដោយសុខភាពល្អចាប់ពីវ័យជំទង់រហូតដល់ពេញវ័យ ហើយទម្លាប់របៀបរស់នៅជាកត្តារួមចំណែកបណ្ដាលឱ្យមានជំងឺបែបនេះ។

នៅក្នុងជំពូកទី១០ គរុនិស្សិតនឹងរៀនអំពីការប្រើប្រាស់គ្រឿងស្រវឹង ការជក់បារី និងការពឹងផ្អែកលើគ្រឿងញៀនផ្សេងៗទៀត។ ទម្លាប់ទាំងអស់នេះគឺជាទម្លាប់ដែលចាប់ផ្ដើមនៅក្នុងវ័យជំទង់ ហើយមានឥទ្ធិពលមិនគួរឱ្យចង់បានដល់សុខភាព។ គរុនិស្សិតនឹងរៀនពីរបៀបបង្កឱ្យមានការញៀនដោយគ្រឿងស្រវឹង ថ្នាំជក់ គ្រឿងញៀនសំយោគ និងគ្រឿងញៀនដទៃទៀត។ គរុនិស្សិតក៏នឹងសិក្សាអំពីឥទ្ធិពលរបស់វាទៅលើសុខភាពផ្លូវចិត្ត និងសង្គមព្រមទាំងរាងកាយផងដែរ។ ភាពមានកម្រិតនៃការយល់ដឹងអំពីការញៀនស្រា ថ្នាំជក់ និងគ្រឿងញៀនសំយោគផ្សេងៗ កំពុងតែជាបញ្ហាសុខភាពដ៏សំខាន់មួយដែលអាចជះឥទ្ធិពលអវិជ្ជមានមិនត្រឹមតែលើបុគ្គលប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងប៉ះពាល់ដល់មិត្តភ័ក្តិ គ្រួសារនិងសង្គមថែមទៀតផង។ វាចាំបាច់ត្រូវការសមត្ថភាពគ្រូឧទ្ទេសដើម្បីអនុវត្តការអប់រំសុខភាពសម្រាប់កុមារ ក៏ដូចជាសម្រាប់មនុស្សធំនៅជុំវិញខ្លួនផងដែរ។

- **ជំពូកទី ១១**

នៅក្នុងជំពូកទី ៣ យើងបានសិក្សាពីការលូតលាស់ និងការអភិវឌ្ឍចាប់ពីទារករហូតដល់អាយុចូលរៀនបឋមសិក្សា។ ជំពូកទី ១១ ផ្ដោតលើការផ្លាស់ប្ដូររាងកាយ ផ្លូវចិត្ត និងសង្គមក្នុងវ័យជំទង់។ ជាពិសេស គរុនិស្សិតនឹងសិក្សាពីការផ្លាស់ប្ដូរដែលកើតឡើងក្នុងអំឡុងពេលដំណើរការលូតលាស់ផ្លូវភេទ ចាប់ពីការចាប់ផ្ដើមនៃលក្ខណៈផ្លូវភេទបន្ទាប់បន្សំរហូតដល់ភាពចាស់ទុំនៃផ្លូវភេទ។

ទោះបីជាមិនរាប់បញ្ចូលទាំងអស់ក៏ដោយក៏ជំពូកនេះគ្របដណ្ដប់នូវអ្វីដែលត្រូវបានរួមបញ្ចូលនៅក្នុងការអប់រំផ្លូវភេទដ៏ទូលំទូលាយដូចដែលបានណែនាំដោយអង្គការអន្តរជាតិដូចជា UNESCO ជាដើម។ ក្នុងនោះរួមមាន ការវិវឌ្ឍផ្លាស់ប្ដូរនៃរាងកាយដែលទាក់ទងនឹងភាពចាស់ទុំនៃផ្លូវភេទ ការបន្តពូជ និងសុខភាពពីការបញ្ចេញពងអូវុលរហូតដល់មានផ្ទៃពោះ ការសម្រាលកូន ជំងឺកាមរោគ អាកប្បកិរិយាផ្លូវភេទ បទដ្ឋានផ្លូវភេទនៅប្រទេសកម្ពុជា ភាពចម្រុះនៃផ្លូវភេទ និងអំពើហិង្សាផ្លូវភេទ។ លើសពីនេះទៅទៀត ការអប់រំពេលមករដូវនៅសាលារៀន និងនៅផ្ទះគឺជាបញ្ហាបន្ទាន់មួយក្នុងសុខភាពសិក្សា។

- **ជំពូកទី ១២**

នៅក្នុងជំពូកទី ៣ និងទី ១១ ការអភិវឌ្ឍនៃចិត្តពីទារករហូតដល់វ័យជំទង់ត្រូវបានលើកមកនិយាយ។ នៅក្នុងជំពូកទី ១២ ដោយផ្ដោតជាពិសេសលើចិត្តគំនិតមនុស្ស គរុនិស្សិតនឹងរៀនអំពីទ្រឹស្ដីនៃការអភិវឌ្ឍ ការតានតឹងក្នុងជីវិតប្រចាំថ្ងៃដែលប៉ះពាល់ដល់សុខភាពផ្លូវចិត្ត និងវិធីដោះស្រាយជាមួយជំងឺនោះ បញ្ហាសុខភាពផ្លូវចិត្តនៅប្រទេសកម្ពុជា ជំងឺផ្លូវចិត្តទូទៅ និងវិធីស្វែងរកជំនួយ និងរបៀបគាំទ្រ។

ទ្រឹស្តីនៃការអភិវឌ្ឍផ្លូវចិត្តគឺជាទ្រឹស្តីដ៏សំខាន់មួយសម្រាប់ការយល់ដឹងអំពីចិត្តគំនិតរបស់កុមារ ហើយគ្រូបង្រៀនគួរយល់ដឹង។ ក្នុងការពិនិត្យមើលសុខភាពផ្លូវចិត្តក៏សំខាន់ផងដែរក្នុងការដឹងថា ចិត្តក៏មានមូលដ្ឋានជីវសាស្ត្រ ផ្លូវចិត្តបែបស៊ីជម្រៅ និងមូលដ្ឋានសង្គមផងដែរ។ វាមានសារៈសំខាន់ណាស់ក្នុងការយល់ដឹងអំពីភាពតានតឹងចិត្តក្នុងជីវិតប្រចាំថ្ងៃទាក់ទងនឹងបទពិសោធន៍ជីវិតផ្ទាល់ខ្លួនរបស់មនុស្សម្នាក់ៗ។ វាក៏សំខាន់ផងដែរក្នុងការពិភាក្សាអំពីបញ្ហានៃចិត្តគំនិតរបស់ប្រជាជនកម្ពុជាដូចជា បញ្ហាដែលស្គាល់ច្បាស់ដោយប្រើបទពិសោធន៍ផ្ទាល់ខ្លួន ករណីសិក្សា និងព័ត៌មានពីប្រព័ន្ធផ្សព្វផ្សាយពីព្រោះវាជាបញ្ហាលេចចេញម្តងបន្តិចៗនៅក្នុងបរិបទសង្គម-វប្បធម៌របស់យើង។ ការរៀបចំខ្លួនជាគ្រូឧទ្ទេសដើម្បីប្រឹក្សាដល់កុមារ និងឪពុកម្តាយរបស់ពួកគេគឺជាផ្នែកនៃការសិក្សាដែលអាចរៀនបានតាមរយៈការដើរតួសម្តែងរឿង។

- ជំពូកទី ១៣

ជំពូកទី ១៣ បរិស្ថាន និងសុខភាព គ្របដណ្តប់ទិដ្ឋភាពពីរ៖ ការយល់ដឹងអំពីទំនាក់ទំនងផលប៉ះពាល់បរិស្ថានសុខភាពពោលគឺរបៀបដែលសារធាតុនៅក្នុងបរិស្ថានប៉ះពាល់ដល់សុខភាពមនុស្ស និងទស្សនវិស័យអេកូសុខភាព (Ecohealth) សំដៅលើរបៀបដែលធាតុផ្សំទាំងបួន៖ ការអភិវឌ្ឍសេដ្ឋកិច្ចសង្គម ឋានប្រព័ន្ធនិងបរិស្ថាន ជីវិតមនុស្សនិងសកម្មភាពចិញ្ចឹមជីវិត ព្រមទាំងសុខភាពមនុស្សអាចរក្សាបានដោយសុខដុមរមនា។ គរុនិស្សិតនឹងសិក្សាអំពីសុខភាពបរិស្ថានតាមទស្សនៈទាំងពីរនេះ។

ការប៉ះពាល់បរិស្ថាន-សុខភាព គរុនិស្សិតនឹងរៀនពីរបៀបចាត់ថ្នាក់បរិស្ថានជាបួនប្រភេទ៖ រូបសាស្ត្រ គីមីសាស្ត្រ ជីវសាស្ត្រ និងផ្លូវចិត្ត-សង្គម-វប្បធម៌ ព្រមទាំងអ្វីដែលជាធាតុផ្សំបរិស្ថានត្រូវបានរួមបញ្ចូលនៅក្នុងប្រភេទនីមួយៗ។ ចូរស្វែងយល់ពីធាតុផ្សំនៃបរិស្ថានជុំវិញអ្នកដែលអាចប៉ះពាល់ដល់សុខភាពរបស់អ្នក។ វាមានសារៈសំខាន់សម្រាប់គរុនិស្សិតក្នុងការយល់ដឹងថា ការបំពុលបរិស្ថានដូចជា ការបំពុលខ្យល់ និងទឹកមានផលប៉ះពាល់យ៉ាងខ្លាំងដល់សុខភាពមនុស្សក៏ដូចជាក្នុងការឆ្លុះបញ្ចាំងអំពីការយល់ដឹងនេះ ដូច្នេះពួកគេអាចភ្ជាប់ទំនាក់ទំនងវាទៅនឹងសារៈសំខាន់នៃបរិស្ថានជុំវិញពួកគេដែលមានអនាម័យ ស្អាត និងសុវត្ថិភាពដែលចំណុចនេះបានលើកយកមកពិភាក្សានៅក្នុងជំពូកទី ៤ ហើយ។ ជំពូកទី ៧ «ការបង្ការជំងឺឆ្លង» ក៏អាចត្រូវបានគេចាត់ចូលក្នុងបញ្ហាបរិស្ថាននៃការលូតលាស់ និងទំនាក់ទំនងរបស់ភ្នាក់ងារបង្កពេគផងដែរ ហើយតាមរបៀបនេះ ការរៀនសូត្រអាចកាន់តែស៊ីជម្រៅដោយការភ្ជាប់ទំនាក់ទំនងយ៉ាងសកម្មជាមួយជំពូកផ្សេងៗទៀត។

ទស្សនវិស័យអេកូសុខភាពចាំបាច់ត្រូវយល់ដោយធ្វើការពិភាក្សាអំពីបញ្ហាជាក់លាក់នៅក្នុងប្រទេសកម្ពុជាដូចជាការកាប់បំផ្លាញព្រៃឈើ ការកាប់ព្រៃកោងកាង គ្រាប់មីន និងយុទ្ធភណ្ឌមិនទាន់ផ្ទុះ។ លើសពីនេះទៅទៀត ផែនទីទំនាក់ទំនងរវាងកត្តានីមួយៗនឹងត្រូវបង្កើតឡើងដើម្បីយល់កាន់តែច្បាស់អំពីរបៀបដែលការអភិវឌ្ឍសេដ្ឋកិច្ចសង្គម ឋានប្រព័ន្ធនិងបរិស្ថាន ជីវិតមនុស្សនិងសកម្មភាពចិញ្ចឹមជីវិត និងសុខភាពមនុស្សមានទំនាក់ទំនងគ្នាទៅវិញទៅមកក្នុងបញ្ហាទាំងនេះ។

- ជំពូកទី ១៤

ជំពូកទី ១៤ និយាយអំពីសុវត្ថិភាពសាលារៀន ការគ្រប់គ្រងហានិភ័យ និងការអប់រំបង្ការគ្រោះមហន្តរាយដែលមិនទាន់មានការរីករាលដាលនៅក្នុងប្រទេសកម្ពុជានៅឡើយ។ ជំពូកនេះក៏ពណ៌នាអំពីលក្ខណៈអភិវឌ្ឍរបស់កុមារដើម្បីជួយ

គរុនិស្សិតឱ្យយល់អំពីលក្ខណៈរបស់កុមារដែលអាចនាំទៅកាន់គ្រោះថ្នាក់ និងរបួស។ ជំពូកទី ៣, ១១ និង ១២ គ្របដណ្ដប់លើលក្ខណៈនៃការអភិវឌ្ឍ ពីព្រោះការយល់ដឹងអំពីលក្ខណៈអភិវឌ្ឍ ឬការអភិវឌ្ឍសមត្ថភាពមានសារៈសំខាន់ក្នុងការយល់ដឹងអំពីសុខភាពរបស់កុមារ ព្រមទាំងការអភិវឌ្ឍសុខភាពសិក្សាដើម្បីការពារសុខភាពនិងសុវត្ថិភាពរបស់ពួកគេ។ ការផ្ដល់អនុសាសន៍ឱ្យផ្ដល់ឧទាហរណ៍ឱ្យបានច្រើនតាមដែលអាចធ្វើទៅបានដូចជា គ្រោះថ្នាក់ចរាចរណ៍ ទឹកជំនន់ អគ្គីភ័យ ករណីគ្រោះថ្នាក់ផ្សេងៗ និងការរងរបួសរបស់កុមារនៅតាមសាលារៀន ក៏ដូចជាការខូចខាតដោយសារគ្រាប់មីននិងយុទ្ធភណ្ឌមិនទាន់ផ្ទុះដែលជារឿងជួបទូទៅនៅប្រទេសកម្ពុជា ហើយគួរមានការពិភាក្សាអំពីមូលហេតុនិងការអប់រំព្រមទាំងវិធានការដាក់លាក់ដែលអាចអនុវត្តបានដើម្បីបង្ការគ្រោះថ្នាក់បែបនេះ។ ឧបទ្ទវហេតុ គ្រោះមហន្តរាយ និងវិបត្តិមានលក្ខណៈខុសៗគ្នាទៅតាមតំបន់ និងភូមិសាស្ត្រនៃប្រទេសនីមួយៗ។ ដូច្នេះនៅពេលរាយការណ៍និងពិភាក្សាករណីសិក្សាចាំបាច់ត្រូវពិចារណាថា តើការអប់រំសុវត្ថិភាពនិងវិធានការសុវត្ថិភាពអ្វីខ្លះដែលគួរត្រូវលើកឡើងដោយផ្អែកលើលក្ខណៈសេដ្ឋកិច្ចសង្គម និងភូមិសាស្ត្រនៃតំបន់ ព្រមទាំងព័ត៌មានអំពី ទីតាំង ពេលវេលា រដូវកាល និងស្ថានភាពផងដែរ។

ការស្ទង់មតិនៅសាលារៀននិងទីកន្លែងជិតៗជុំវិញ ព្រមទាំងការបង្កើតផែនទីគ្រោះថ្នាក់គឺជាសកម្មភាពសំខាន់មួយក្នុងការវាយតម្លៃបរិស្ថានជុំវិញអំពីទិដ្ឋភាពសុវត្ថិភាព និងគ្រោះមហន្តរាយ។ ការធានាសុវត្ថិភាពនៅតាមផ្លូវទៅនិងមកសាលារៀនក៏ជាបញ្ហាសំខាន់ក្នុងសុខភាពសិក្សាផងដែរ។

- **ជំពូកទី ១៥**

ជំពូកទី ១៥ និយាយអំពីការសង្គ្រោះបឋមនៅតាមសាលារៀន។ ដោយសន្មតថា សមាជិកវិទ្យាស្ថានគរុកោសល្យមិនមែនជាអ្នកជំនាញផ្នែកវេជ្ជសាស្ត្រ ហើយនឹងមិនអនុវត្តនីតិវិធីវេជ្ជសាស្ត្រទេ គរុនិស្សិតនឹងរៀនអំពីរបៀបយកសញ្ញាជីវិត រៀនអំពីមូលដ្ឋានគ្រឹះនៃការសង្គ្រោះបឋម និងរៀនអំពីការព្យាបាលស្នាមរបួស និងការត្អូញត្អែរបែបវេជ្ជសាស្ត្រដែលអាចនឹងក្លាយជារឿងទូទៅនៅប្រទេសកម្ពុជា។ ជាពិសេស ក្នុងការដោះស្រាយការរងរបួស គរុនិស្សិតគួរមានការយល់ដឹងឱ្យបានល្អអំពីកាយវិភាគវិទ្យានៃប្រភេទរបួស ព្រមទាំងការយល់ដឹងឱ្យបានល្អអំពីវិធីសាស្ត្រ RICE ផងដែរ។

ការវាស់ភាពមានស្មារតី ការដកដង្ហើម ជីពចរ សម្ពាធឈាម និងសីតុណ្ហភាពរាងកាយនឹងត្រូវអនុវត្តវាស់ជាក់ស្ដែង។

- **ជំពូកទី ១៦**

នៅក្នុងជំពូកទី ១ យើងបានសិក្សាពីបញ្ញត្តិនៃសុខភាព ចំណែកឯជំពូកទី ១៦ យើងនឹងសិក្សាពីបញ្ញត្តិនៃជំងឺ និងពិការភាព។ បញ្ញត្តិនៃសុខភាពរួមបញ្ចូលទាំងការឈឺ និងពិការ ប៉ុន្តែដើម្បីចៀសវាងការភ័ន្តច្រឡំ យើងបានផ្ដាច់ជាជំពូកផ្សេងៗគ្នា។ នៅទីនេះ ពិការភាពត្រូវបានពិពណ៌នានៅក្នុងលក្ខខណ្ឌនៃគំរូចំនួនបីគឺ៖ គំរូវេជ្ជសាស្ត្រ គំរូសង្គម និង ICF ដែលជាគំរូរួមបញ្ចូលគ្នា។ ជាពិសេស ត្រូវយល់ពីគំរូវេជ្ជសាស្ត្រ និងគំរូសង្គមឱ្យបានល្អ។

ជនពិការ អ្នកជំងឺអេដស៍អាចទទួលរងការបដិសេធពីសង្គមដោយសារតែការរើសអើង និងការមាក់ងាយដោយសារជំងឺ ឬពិការភាពរបស់ពួកគេ។ ដោយគិតអំពីបរិយាបន្នអប់រំ និងបរិយាបន្នសង្គមចាំបាច់ត្រូវពង្រឹងការយល់ដឹងរបស់គរុនិស្សិតអំពីបច្ចុប្បន្នភាពនៃការរើសអើង និងការបដិសេធពីសង្គមប្រឆាំងនឹងមនុស្សដែលមានជំងឺ និងពិការភាពនៅក្នុងប្រទេសកម្ពុជាតាមរយៈការស្ដាប់រឿងរ៉ាវពីមនុស្សជិតស្និទ្ធ និងពិភាក្សាជាមួយគរុនិស្សិតដទៃទៀត។

# ធ្វើឱ្យប្រសើរឡើងនូវដំណើរការសិក្សា
# (ការបង្រៀន)

## ១. ចំណុចគន្លឹះនៃការបង្រៀនសុខភាពសិក្សា

### ១.១. អភិវឌ្ឍអាកប្បកិរិយារបស់គរុនិស្សិតក្នុងការរៀន និងបង្រៀនសុខភាពសិក្សាជាមុខវិជ្ជាសិក្សា

អ្វីដែលមនុស្សដឹងអំពីអាថ៌កំបាំងនៃសុខភាព និងជីវិតនៅមានកម្រិត។ ខណៈពេលដែលយើងដឹងអំពីភាពមានកម្រិតយល់ដឹងរបស់យើងបែបនេះ យើងអាចបង្រៀនអំពីគតិបណ្ឌិតនៃសុខភាពដែលមានឫសគល់នៅក្នុងសង្គមកម្ពុជា និងចំណេះដឹងផ្នែកវិទ្យាសាស្ត្រនៃសុខភាព ដែលទទួលបានដោយវិទ្យាសាស្ត្រសម័យទំនើបស្របនឹងការធ្វើវិនិច្ឆ័យយ៉ាងល្អិតល្អន់។ ទោះបីជាត្រឹមត្រូវតាមបែបវិទ្យាសាស្ត្រក៏ដោយ វាប្រហែលជាមិនអាចដំណើរការបាន ឬមិនអាចទទួលយកបានសម្រាប់ហេតុផលសង្គម-វប្បធម៌ ឬសាសនានោះទេ។ ចូរចងចាំចំណុចទាំងនេះជានិច្ចនៅពេលបង្រៀន។

ទោះជាយ៉ាងណា ការបង្រៀននៅវិទ្យាស្ថានគរុកោសល្យក្នុងនាមជាគ្រូឧទ្ទេសជំនាញសុខភាពសិក្សាមិនអាចបង្រៀនដោយសុទ្ធតែរំពឹងលើការបង្កើត និងបង្កើនក្រុមចំណេះដឹងតាមបែបវិទ្យាសាស្ត្របានទាំងអស់នោះទេ។ ពោលគឺយើងមិនអាចសន្មតថា ការព្យាបាលតាមបែបបុរាណនិងការព្យាបាលតាមបែបប្រពៃណីគឺជាអបិយជំនឿនោះទេ ប៉ុន្តែយើងត្រូវតែប្រើភាពវៃឆ្លាតរបស់យើងដើម្បីធ្វើការវិនិច្ឆ័យយ៉ាងទូលំទូលាយ ខណៈគោរពវប្បធម៌ប្រពៃណីដើម្បីផលប្រយោជន៍ដ៏ប្រសើរបំផុតសម្រាប់សុខភាពរបស់កុមារ។

ដោយសារសុខភាពសិក្សាគឺជាមុខវិជ្ជាដែលមានលក្ខណៈទូលំទូលាយ និងអន្តរវត្តច្រើន វានឹងភ្ជាប់ទំនាក់ទំនងទៅមុខវិជ្ជាផ្សេងៗទៀតដែលបង្រៀននៅក្នុង TEC ដូចជា ចិត្តវិទ្យា ជីវវិទ្យា និងមុខវិជ្ជានៅក្នុងផ្នែកវិទ្យាសាស្ត្រសង្គម។ នេះគឺជាការគ្រប់គ្រងឆ្លងកម្មវិធីសិក្សា (cross-curriculum management)។

លើសពីការបង្រៀនដោយផ្ទាល់ពីសៀវភៅសិក្សាគោល គ្រូឧទ្ទេសម្នាក់ៗនឹងប្រើប្រាស់សៀវភៅសិក្សាគោលនេះដើម្បីកំណត់ខ្លឹមសារដែលត្រូវបង្រៀនដោយសំយោគនូវអ្វីដែលគ្រូឧទ្ទេសម្នាក់ៗចាត់ទុកថាមានសារៈសំខាន់ជាលក្ខណៈសុខភាពសិក្សាទៅតាមជំពូកនីមួយៗ និងតាមស្ថានភាពជាក់ស្តែងរបស់គរុនិស្សិតដែលនៅចំពោះមុខគាត់។

សារៈសំខាន់នៃការបង្រៀនសុខភាពសិក្សានៅវិទ្យាស្ថានគរុកោសល្យមានពីរ។ ទីមួយគឺ ដើម្បីសុខភាពគរុនិស្សិតខ្លួនឯងដែលកំពុងរៀន ម្យ៉ាងទៀតគឺដើម្បីឱ្យពួកគេអាចបង្រៀនសុខភាពសិក្សាដល់សិស្សនៅពេលក្លាយជាគ្រូឧទ្ទេស។

## ១.២. កត្តាដែលត្រូវរៀបចំនៅក្នុងសេចក្ដីផ្ដើមនៃថ្នាក់សិក្សា

ប្រធានបទនីមួយៗគួរតែត្រូវបានណែនាំតាមរបៀបមួយដែលមានភាពជិតស្និទ្ធទៅនឹងបទពិសោធន៍របស់គរុនិស្សិត។

(១) ប្រើប្រាស់ស្ថិតិប្រទេសកម្ពុជា។

Analyze data from the Global School-based Student Health Survey ( GSHS ) 2013 of Cambodia.

( **តំណភ្ជាប់ ០.៦៖** https://extranet.who.int/ncdsmicrodata/index.php/catalog/220/related_materials )

Cambodia Demographic and Health Survey 2014

**តំណភ្ជាប់ ០.៧៖** https://dhsprogram.com/pubs/pdf/fr312/fr312.pdf

GSHSpdf

(២) ប្រើប្រាស់ករណី និងយកអ្វីដែលមាននៅក្នុងសារព័ត៌មាន។

e.g. Phnom Penh Post https://www.phnompenhpost.com/

Khmer Times https://www.khmertimeskh.com/

(៣) ឱ្យគរុនិស្សិតចែករំលែកបទពិសោធន៍របស់ពួកគេ និងសង្ខេបការពិភាក្សាជាក្រុមនៅក្នុងបទបង្ហាញមួយ។ ឧទាហរណ៍ យើងសុំឱ្យគរុនិស្សិតដាក់របាយការណ៍ដោយមិនបញ្ចេញឈ្មោះអំពីបទពិសោធន៍ផ្ទាល់ខ្លួនរបស់ពួកគេលើប្រធានបទមួយជាក់លាក់ជាមុន ហើយជ្រើសរើសម្នាក់ក្នុងចំណោមពួកគេដើម្បីណែនាំ។

(៤) ណែនាំអំពីបទពិសោធន៍របស់គ្រូឧទ្ទេស។

(៥) ចែករំលែកវគ្គនោះ។

## ១.៣. អ្វីដែលគ្រូឧទ្ទេសគួរធ្វើ

### (១) បង្រៀនគរុនិស្សិតអំពីអាកប្បកិរិយាពេលសិក្សាសុខភាពសិក្សា

គ្រូឧទ្ទេសនឹងប្រាប់គរុនិស្សិតថា សុខភាពសិក្សាគឺជាមុខវិជ្ជាដែលមានលក្ខណៈទូលំទូលាយ និងអនុវត្តច្រើន ដូច្នេះពួកគេគួរតែត្រៀមខ្លួនដើម្បីភ្ជាប់ទំនាក់ទំនងវាទៅនឹងមុខវិជ្ជាផ្សេងទៀតដែលបង្រៀននៅវិទ្យាស្ថានគរុកោសល្យ (TEC) ដូចជាប្រធានបទដែលទាក់ទងយ៉ាងជិតស្និទ្ធនៅនឹង ចិត្តវិទ្យា ជីវវិទ្យា និងវិទ្យាសាស្ត្រសង្គម។

លោកគ្រូអ្នកគ្រូគួរប្រាប់គរុនិស្សិតថា ការរៀននៅវិទ្យាស្ថានគរុកោសល្យមិនមែនរៀនតែពីសៀវភៅសិក្សាគោលដូចគេទេ ប៉ុន្តែត្រូវរៀនប្រើសៀវភៅសិក្សាគោលដើម្បីគិតដោយឯករាជ្យអំពីបញ្ហាសុខភាពដែលមានលក្ខណៈជាក់ស្ដែង និងពាក់ព័ន្ធទៅនឹងការពិតដែលមាននៅក្នុងដៃ។

### (២) ការរៀបចំសម្រាប់ថ្នាក់សិក្សា

- ពិនិត្យ និងស្វែងយល់ពីគោលបំណងសិក្សានៃជំពូកនីមួយៗ។
- គួររៀបចំផែនការមេរៀនស្របតាមគោលបំណងសិក្សានៃជំពូកនីមួយៗ។

- ផ្តល់ទិដ្ឋភាពទូទៅនូវអ្វីដែលនឹងត្រូវបានគ្របដណ្តប់នៅក្នុងថ្នាក់នៅពេលចាប់ផ្តើមបង្រៀន។
- ខ្លឹមសារដែលត្រូវបង្រៀនត្រូវសមស្របទៅនឹងគោលបំណងសិក្សា។
- មិនចាំបាច់គ្របដណ្តប់គ្រប់មាតិកាទាំងអស់នៃជំពូកនោះទេ។
- អានជំពូកនីមួយៗដោយយកចិត្តទុកដាក់ដើម្បីបង្កើនការយល់ដឹងរបស់អ្នកអំពីខ្លឹមសាររបស់មេរៀន។
- រាល់ចម្ងល់ទាំងឡាយត្រូវសួរនិងដោះស្រាយតាមរយៈការិយាល័យគម្រោងនៅប្រទេសកម្ពុជា។
- បន្ទាប់ពីបង្រៀនហើយ ប្រសិនបើនៅមានអ្វីដែលត្រូវបំពេញបន្ថែមនៅក្នុងសៀវភៅសិក្សាគោល មតិយោបល់ទាំងនេះនឹងត្រូវបានប្រមូលផ្តុំ ហើយសៀវភៅសិក្សាគោលដែលមានការពន្យល់បន្ថែមនឹងត្រូវបានរៀបចំសម្រាប់គ្រូឧទ្ទេស។

**កំណត់សម្គាល់៖** សញ្ញា (❖) និង (➢) សំដៅលើចំណងជើងមាតិកានៅក្នុងសៀវភៅសិក្សាគោល។

ខ្លឹមសារមួយចំនួនរបស់សៀវភៅសិក្សាគោលដែលមិនអាចក្តោបបាននៅក្នុងថ្នាក់រៀនបាននឹងត្រូវលើកមកបង្រៀនបន្ថែមទៅតាមពេលវេលាសមគួរណាមួយផ្សេងទៀត និងទៅតាមតម្រូវការក្នុងការយល់ដឹងអំពីខ្លឹមសារក៏ដូចជាដើម្បីពង្រីកខ្លឹមសារពេលបង្រៀននៅក្នុងថ្នាក់រៀន។

ប្រមូលផែនការមេរៀននិងឯកសារបង្រៀនសម្រាប់ថ្នាក់ដែលបង្រៀនដោយគ្រូឧទ្ទេសវិទ្យាស្ថានគរុកោសល្យរាជធានីភ្នំពេញ(PTEC) និងវិទ្យាស្ថានគរុកោសល្យបាត់ដំបង(BTEC) ហើយចែករំលែកវានៅក្នុងមូលដ្ឋានទិន្នន័យ។

**(៣) កិច្ចការសម្រាប់ការសិក្សាជាមុន និងការងារជាក្រុម**

ប្រើប្រាស់ «លំហាត់សម្រាប់ការគិតនិងស្រាវជ្រាវបន្ថែម» នៅចុងបញ្ចប់នៃជំពូកនីមួយៗសម្រាប់កិច្ចការក្រុម កិច្ចការសិក្សាជាមុន ឬតាមរយៈសំណួរចម្លើយ។

**(៤) រៀបចំរចនាសម្ព័ន្ធមេរៀន**

១ក្រេឌីត សម្រាប់មួយឆមាសនីមួយៗ (ឬ ២ក្រេឌីត ក្នុងឆមាសទី ២)

**សមាសភាពពេលវេលា៖ ១ក្រេឌីត សម្រាប់ឆមាសនីមួយៗ**

៥០នាទី x ២ = ១០០នាទី សម្រាប់មុននិងក្រោយការសិក្សាដោយគរុនិស្សិត។

តម្រូវឱ្យគរុនិស្សិតអានសៀវភៅសិក្សាជាមុន និងផ្តល់កិច្ចការដែលឈានទៅពិភាក្សាជាក្រុម។

រចនាសម្ព័ន្ធពេលវេលានៃមេរៀន ៥០នាទី (៣០នាទីសម្រាប់ការបង្រៀន ២០នាទីសម្រាប់សកម្មភាពដូចជា ការងារជាក្រុមនិងការពិភាក្សា បង្កើតផ្ទាំងរូបភាព សំណួរឆ្លើយឆ្លង បង្កើតផែនទី។ល។

**សមាសភាពពេលវេលា៖ ២ក្រេឌីត សម្រាប់ឆមាសទី ២ (មួយថ្នាក់មានរយៈពេល ២ម៉ោងជាប់គ្នា)**

១០០នាទី x ១៥ដង រៀនដោយខ្លួនឯង និងធ្វើកិច្ចការផ្ទះ ៥០នាទី x ៤ដង/សប្តាហ៍

**ផែនការ A៖** បង្រៀន ៦០នាទី ការងារជាក្រុម ២០នាទី បទបង្ហាញ ២០នាទី (សកម្មភាពសរុប ៤០នាទី)

**ផែនការ B៖** បង្រៀន ៧០នាទី ការពិភាក្សានិងការឆ្លើយឆ្លង សំណួរនិងចម្លើយ ៣០នាទី

### តារាងទី ១៖ កាលវិភាគមេរៀន (ឧទាហរណ៍)

| មេរៀន | កាលបរិច្ឆេទ | ជំពូក |
|---|---|---|
| ទី ១-២ | | សេចក្តីផ្តើម៖ ចរិតលក្ខណៈនៃកម្មវិធីសុខភាពសិក្សា<br>ជំពូកទី ១៖ សុខភាព<br>ជំពូកទី ១៦៖ ពិការភាព និងតម្រូវការការអប់រំពិសេស |
| ទី ៣-៤ | | ជំពូកទី ២៖ របៀបរាងកាយរបស់អ្នកធ្វើការ |
| ទី ៥-៦ | | ជំពូកទី ៣៖ ការលូតលាស់ និងការអភិវឌ្ឍរបស់កុមារ |
| ទី ៧ | | ជំពូកទី ៤៖ ភាពស្អាត អនាម័យ និងសុខភាព |
| ទី ៨-៩ | | ជំពូកទី ៥៖ របៀបរស់នៅ និងសុខភាព |
| ទី ១០-១១ | | ជំពូកទី ៦៖ ការបង្ការជំងឺបណ្តាលមកពីរបៀបរស់នៅ |
| ទី ១២-១៣ | | ជំពូកទី ៧៖ ជំងឺឆ្លង វិធីបង្ការ និងការពារ |
| ទី ១៤ | | ជំពូកទី ៨៖ សុខភាពមាត់ធ្មេញ<br>ជំពូកទី ៦៖ ជំងឺអញ្ចាញធ្មេញ |
| ទី ១៥ | | ជំពូកទី ៩៖ សារៈសំខាន់ និងវិធីសាស្រ្តនៃការពិនិត្យសុខភាព (ឧទ្ទេស) |
| ទី ១៦-១៧ | | ជំពូកទី ៩៖ សារៈសំខាន់ និងវិធីសាស្រ្តនៃការពិនិត្យសុខភាព (ឧទ្ទេស និង អនុវត្ត) វាស់កម្ពស់ និងថ្លឹងទម្ងន់ គណនា BMI |
| ទី ១៨-១៩ | | ជំពូកទី ៩៖ សារៈសំខាន់ និងវិធីសាស្រ្តនៃការពិនិត្យសុខភាព (ឧទ្ទេស និង អនុវត្ត) ការធ្វើតេស្តគំហើញ និងការធ្វើតេស្តសមត្ថភាពស្តាប់ឮ<br>ជំពូកទី ៨៖ សុខភាពភ្នែក |
| ទី ២០-២១ | | ជំពូកទី ១៥៖ ការសង្គ្រោះបឋមនៅសាលារៀន (ឧទ្ទេស និងអនុវត្ត) |
| ទី ២២-២៣ | | ជំពូកទី ១០៖ ផលប៉ះពាល់សុខភាពនៃការប្រើប្រាស់ថ្នាំជក់ គ្រឿងស្រវឹង និង គ្រឿងញៀន |
| ទី ២៤-២៥ | | ជំពូកទី ១១ ៖ ការប្រែប្រួលផ្លូវចិត្ត និងរាងកាយអំឡុងពេលយុវវ័យ (ការអប់រំទូលំទូលាយអំពីផ្លូវភេទ) |
| ទី ២៦-២៧ | | ជំពូកទី ១២៖ សុខភាពផ្លូវចិត្ត |
| ទី ២៨-២៩ | | ជំពូកទី ១៣៖ បរិស្ថាន និងសុខភាព/អេកូសុខភាព |
| ទី ៣០ | | ជំពូកទី ១៤៖ សុវត្ថិភាពសាលារៀន និងការគ្រប់គ្រងវិបត្តិ (ការអប់រំអំពី សុវត្ថិភាពសាលារៀន) |

គ្រូឧទ្ទេសមិនចាំបាច់បង្រៀនគ្រប់ជំពូកនោះទេ។ គ្រូឧទ្ទេសអាចកំណត់លំដាប់នៃមេរៀន ជំពូក និងខ្លឹមសារដែលត្រូវបង្រៀនដោយអនុលោមតាមស្ថានភាពជាក់ស្តែងនៃការយល់ដឹងរបស់គរុនិស្សិត កម្រិតនៃចំណេះដឹង និងសមត្ថភាពនៃការគិត ផែនកំណត់ពេលវេលានៃថ្នាក់រៀន ព្រមទាំងបញ្ហាសុខភាពនិងតម្រូវការផ្នែកសុខភាពរបស់គរុនិស្សិត។

# ចំណុចដែលគ្រូបង្រៀនស្របតាមគោលបំណងសិក្សានៃជំពូកនីមួយៗ

# មេរៀនទី ១

## សេចក្តីផ្តើម៖ លក្ខណៈនៃសុខភាពសិក្សា និងជំពូកទី ១៖ សុខភាព

### ១. ទិដ្ឋភាពទូទៅ

នៅក្នុងសេចក្តីផ្តើមនិងជំពូកទី ១ អ្នកនឹងរៀនពីនិយមន័យនៃសុខភាពមនុស្ស អត្ថន័យនៃការរស់នៅប្រកបដោយសុខភាពល្អ លើសពីនេះទៀតគឺគំនិតផ្តួចផ្តើមសុខភាពនៅក្នុងសាលារៀននិងសង្គមដើម្បីជួយមនុស្សឱ្យរស់នៅប្រកបដោយសុខភាពល្អ។ បញ្ញត្តិនៃសុខភាពជាពិសេសក្នុងអំឡុងឆ្នាំនៃការអភិវឌ្ឍលូតលាស់គឺជាចំណុចគន្លឹះសម្រាប់គ្រូបង្រៀនកម្រិតបឋមសិក្សាស្វែងយល់។

នៅក្នុងជំពូកទាំងពីរនេះ ចាំបាច់ត្រូវយល់អំពីលក្ខណៈនៃសុខភាពសិក្សាថាជាមុខវិជ្ជាមួយ(លក្ខណៈសុខភាពជាមុខវិជ្ជាសិក្សា) ដែលសុខភាពគឺជាសិទ្ធិជាមូលដ្ឋានរបស់មនុស្ស ហើយនិយមន័យសុខភាពរបស់អង្គការសុខភាពពិភពលោក និងការលើកកម្ពស់សុខភាព (កាតិកាសញ្ញាអូតាវ៉ា សម្រាប់ការលើកកម្ពស់សុខភាព) គួរតែត្រូវបានយល់ថាជាចំណេះដឹងចាំបាច់។

ទស្សនវិស័យអេកូឡូស៊ីលើសុខភាពត្រូវបានសិក្សានៅក្នុងជំពូកទី១៣៖ បរិស្ថាន និងសុខភាព/អេកូសុខភាព ដូច្នេះហើយ ចំណុចនេះអាចត្រូវបានលុបចោលពីការពន្យល់លម្អិតនៅក្នុងជំពូកទី ១។

### ២. សេចក្តីផ្តើម

រយៈពេល ៖ ៥នាទី

(១) ប្រើប្រាស់ស្ថិតិប្រទេសកម្ពុជា។

(២) ប្រើករណី និងយកអ្វីដែលមាននៅក្នុងសារព័ត៌មាន។

(៣) សុំឱ្យគរុនិស្សិតចែករំលែកបទពិសោធន៍របស់ពួកគេ និងសង្ខេបការពិភាក្សាជាក្រុមនៅក្នុងបទបង្ហាញមួយ។ (**សំណួរចាប់ផ្តើមគំរូ៖** តើសុខភាពមានន័យដូចម្តេចចំពោះអ្នក? តើសុខភាពសំខាន់ចំពោះអ្នកដែរឬទេ? ចូរប្រាប់ពីមូលហេតុ។)

(៤) ណែនាំអំពីបទពិសោធន៍របស់គ្រូឧទ្ទេស។

## ៣. បញ្ជាក់បំភ្លឺ កំណត់គោលបំណងសិក្សា និងបង្រៀន

រយៈពេល ៖ ២៥នាទី

ជាដំបូង សេចក្តីសង្ខេបខ្លឹមសារនូវអ្វីដែលអ្នកនឹងរៀនមានការផ្តល់ឱ្យនៅក្នុងជំពូកនេះ។

ការបង្រៀននៅក្នុងសេចក្តីផ្តើមជំពូកនឹងផ្តោតលើរឿងពីរដូចខាងក្រោម៖

- តើមានអត្ថន័យយ៉ាងណាសម្រាប់មនុស្សក្នុងការរស់នៅប្រកបដោយសុខភាពល្អទាក់ទងនឹងវដ្តជីវិតរបស់ពួកគេ?
  - ❖ ១. តើមនុស្សរស់នៅប្រកបដោយសុខភាពល្អពេញមួយជីវិតមានន័យដូចម្តេច?
- លក្ខណៈនិងសារៈសំខាន់នៃសុខភាពសិក្សាជាមុខវិជ្ជាសិក្សា។
  - ❖ ៣. លក្ខណៈនៃសុខភាពជាមុខវិជ្ជាសិក្សា

នៅក្នុងជំពូកទី ១ ចំណុចទាំងពីរខាងក្រោមនឹងត្រូវបានបង្រៀន៖

- និយមន័យនិងទិដ្ឋភាពនៃសុខភាព។
  - ❖ ១. ទិដ្ឋភាពនៃសុខភាព (**រូបទី ១.២៖** ទិដ្ឋភាពផ្សេងៗនៃសុខភាព)
  - ❖ ២. សុខភាពគឺជាសិទ្ធិរបស់មនុស្ស
  - ❖ ៣. សុខភាពក្នុងអំឡុងពេលអភិវឌ្ឍ
  - ❖ ៤. ការលើកកម្ពស់សុខភាព
    - ➢ ៤.២. កតិកាសញ្ញាអូតាវ៉ាសម្រាប់ការលើកកម្ពស់សុខភាព
- គោលនយោបាយនិងគំនិតផ្តួចផ្តើមស្តីពីសុខភាពសិក្សាដែលត្រូវបានអនុម័តក្នុងប្រទេសកម្ពុជា។
  - ❖ ៧. អនាគតនៃសុខភាពសិក្សានៅប្រទេសកម្ពុជា

**អត្ថបទដកស្រង់ ១.២៖** គោលនយោបាយជាតិស្តីពីសុខភាពសិក្សាឆ្នាំ ២០១៩ ត្រូវបានប្រកាសឱ្យប្រើជាផ្លូវការ។

## ៤. ឧទាហរណ៍នៃកិច្ចការពិភាក្សាជាក្រុមនិងសំណួរឆ្លើយឆ្លង

រយៈពេល ៖ ២០នាទី

- សារៈសំខាន់ដែលគរុនិស្សិតប្រាថ្នាចង់ក្លាយជាគ្រូឧទ្ទេសត្រូវសិក្សាមុខវិជ្ជាសុខភាពសិក្សា ហើយបង្រៀនវាទៅកុមារ និងបង្កើនចំណាប់អារម្មណ៍របស់គរុនិស្សិតចំពោះខ្លឹមសារនៃសៀវភៅសិក្សានេះ រួមមាន ១៦ ជំពូកនេះ។
- សារៈសំខាន់ និងអត្ថប្រយោជន៍នៃកម្មវិធីអប់រំសុខភាពនៅក្នុងសាលារៀន។
- សារៈសំខាន់នៃការអនុវត្តសកម្មភាពសុខភាពសិក្សា។
- តើសាលារៀនកម្ពុជាអាចធ្វើអ្វីបានដើម្បីលើកកម្ពស់សុខភាពកុមារដោយឆ្លុះបញ្ចាំងតាមរយៈបទពិសោធន៍របស់អ្នក?

កិច្ចការដែលគរុនិស្សិតគួរអាននិងស្វែងយល់អំពីសៀវភៅសិក្សាគោល

- សុខភាពជាបញ្ហាផ្ទាល់ខ្លួន។
- ទំនាក់ទំនងរវាងគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព (SDGs) ទាំង ១៧ និងសុខភាពសិក្សា។

## ៥. ធនធាន

**ការស្ទង់មតិលើសុខភាពនិងរបៀបរស់នៅរបស់គរុនិស្សិត TEC ឆ្នាំ ២០២២**

**ជាទូទៅ តើអ្នកនឹងវាយតម្លៃសុខភាពរបស់អ្នកយ៉ាងដូចម្ដេច?**






## ៦. ការវាយតម្លៃ

- **ចំណេះដឹងនិងជំនាញ៖** ឧទាហរណ៍ ចំណេះដឹងអំពីបញ្ញត្តិជាមូលដ្ឋាននៃសុខភាពនិងការលើកកម្ពស់សុខភាព (ការធ្វើតេស្តចំណេះដឹង) ពន្យល់ពីរបៀបដែលសុខភាពសិក្សាត្រូវបានផ្សារភ្ជាប់ទៅនឹងគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពទាំង ១៧ (SDGs) (វាយការណ៍កិច្ចការដែលបានដាក់ឱ្យធ្វើ) ។
- **ឥរិយាបថសិក្សានិងការចូលរួម៖** ឧទាហរណ៍ សង្កេតមើលអាកប្បកិរិយារបស់គរុនិស្សិតនិងការចូលរួមក្នុងការងារជាក្រុម។ ផ្តល់របាយការណ៍អំពីអ្វីដែលអ្នកបានរៀនពីការធ្វើការងារជាក្រុម អ្វីដែលអ្នកបានរៀនពីការស្តាប់បទបង្ហាញរបស់ក្រុមផ្សេងៗ និងបញ្ហាប្រឈមដែលអ្នកមានអារម្មណ៍តាមរយៈការងារជាក្រុម។ វាយតម្លៃសំណួរនិងចម្លើយបែបសន្ទនា។
- **សមត្ថភាពក្នុងការគិត វិនិច្ឆ័យ និងបញ្ចេញមតិ៖** ឧទាហរណ៍ កំណត់របាយការណ៍អំពីអ្វីដែលអ្នកបានរៀនពីការធ្វើការងារជាក្រុម អ្វីដែលអ្នកបានរៀនពីការស្តាប់បទបង្ហាញរបស់ក្រុមផ្សេងៗ និងបញ្ហាប្រឈមដែលអ្នកមានតាមរយៈការងារជាក្រុម។ វាយតម្លៃសមត្ថភាពក្នុងការពន្យល់កិច្ចការមួយយ៉ាងត្រឹមត្រូវនិងមានលក្ខណៈគួរឱ្យទុកចិត្តក្នុងការធ្វើបទបង្ហាញការងារជាក្រុម។ វាយតម្លៃសំណួរនិងចម្លើយបែបសន្ទនា។ វាយតម្លៃសមត្ថភាពក្នុងការបង្កើតផ្ទាំងរូបភាពដើម្បីផ្តល់ព័ត៌មានសុខភាព។

# មេរៀនទី ២

# ជំពូកទី ១៦៖ ពិការភាព និងតម្រូវការការអប់រំពិសេស

## ១. ទិដ្ឋភាពទូទៅ

នៅក្នុងជំពូកទី ១ យើងបានសិក្សាពីបញ្ញត្តិនៃសុខភាព។ នៅក្នុងជំពូកទី ១៦ យើងនឹងសិក្សាពីបញ្ញត្តិនៃជំងឺនិងពិការភាព។ បញ្ញត្តិនៃសុខភាពរួមបញ្ចូលទាំងការឈឺនិងពិការភាព ប៉ុន្តែដើម្បីចៀសវាងការភាន់ច្រឡំ យើងបានបញ្ចូលចំណុចទាំងនេះទៅក្នុងជំពូកដាច់ដោយឡែកៗពីគ្នា។ នៅទីនេះ ពិការភាពត្រូវបានពិពណ៌នានៅក្នុងលក្ខខណ្ឌនៃគំរូបី៖ គំរូវេជ្ជសាស្ត្រ គំរូសង្គម និងចំណាត់ថ្នាក់ជាអន្តរជាតិលើការបំពេញមុខងារ ពិការភាព និងសុខភាព (ICF) ដែលជាគំរូរួមបញ្ចូលគ្នា។ ជាពិសេស ត្រូវយល់ពីគំរូវេជ្ជសាស្ត្រ និងគំរូសង្គមឱ្យបានល្អ។

ជនពិការ អ្នកជំងឺអេដស៍អាចទទួលរងការបដិសេធពីសង្គមដោយសារតែការរើសអើងនិងការមាក់ងាយដែលបណ្ដាលមកពីជំងឺ ឬពិការភាពរបស់ពួកគេ។ ក្នុងការគិតអំពីបរិយាបន្នអប់រំនិងបរិយាបន្នសង្គម ចាំបាច់ត្រូវពង្រឹងការយល់ដឹងរបស់គរុនិស្សិតអំពីស្ថានភាពបច្ចុប្បន្ននៃការរើសអើង ការមិនរាប់បញ្ចូលសង្គមប្រឆាំងនឹងមនុស្សដែលមានជំងឺ និងពិការភាពក្នុងប្រទេសកម្ពុជាដោយស្ដាប់រឿងរ៉ាវពីមនុស្សជិតស្និទ្ធនិងពិភាក្សាជាមួយគរុនិស្សិតដទៃទៀត។

## ២. សេចក្ដីផ្ដើម

**រយៈពេល៖ ១០នាទី**

(១) ប្រើប្រាស់ស្ថិតិប្រទេសកម្ពុជា។

- Chapter 3 Disabled Population-Size and Distribution

  **តំណភ្ជាប់ ២.១៖** https://www.stat.go.jp/info/meetings/cambodia/pdf/rp5_ch30.pdf

(២) ប្រើប្រាស់ករណី និងយកអ្វីដែលមាននៅក្នុងសារព័ត៌មាន។

- Australia-Cambodia Cooperation for Equitable Sustainable Services

  **តំណភ្ជាប់ ២.២៖** https://accesscambodia.org/meet-miss-chanreaksmey-a-champion-supporting-persons-with-disabilities/

- UNICEF for every child Cambodia. Opening up a world of learning for children with disabilities

  **តំណភ្ជាប់ ២.៣៖** https://www.unicef.org/cambodia/stories/opening-world-learning-children-disabilities

(៣) សុំឱ្យគរុនិស្សិតចែករំលែកបទពិសោធន៍របស់ពួកគេ និងសង្ខេបការពិភាក្សាជាក្រុមនៅក្នុងបទបង្ហាញមួយ។ (**សំណួរចាប់ផ្ដើមគំរូ៖** តើអ្នកធ្លាប់ជួបកុមារ យុវជន ឬមនុស្សពេញវ័យដែលមានពិការភាពដែរឬទេ? តើពិការភាពរបស់ពួកគេមានអ្វីខ្លះ?តើជនពិការបានទទួលការអប់រំដែរឬទេ?តើមនុស្សជុំវិញពួកគេបានប្រព្រឹត្តដូចម្ដេចចំពោះពួកគេ? តើអ្នកមានអារម្មណ៍បែបណាចំពោះពួកគេ?)

(៤) ណែនាំអំពីបទពិសោធន៍របស់គ្រូឧទ្ទេស។

## ៣. បញ្ជាក់ចំណី កំណត់គោលបំណងសិក្សា និងបង្រៀន

**រយៈពេល៖ ២០នាទី**

ជាដំបូង ការសង្ខេបខ្លីៗនៃអ្វីដែលអ្នកនឹងរៀនត្រូវបានផ្ដល់ឱ្យនៅក្នុងជំពូកនេះ។

បទឧទ្ទេសនេះនឹងគ្របដណ្ដប់បីចំណុចដូចខាងក្រោម៖

- និយមន័យនៃជំងឺ ពិការភាពដោយបាត់បង់មុខងារ ពិការភាព និងពិការដោយប្រើឧទាហរណ៍ជាក់លាក់។
  - ❖ ១. ទិដ្ឋភាពនៃជំងឺ ភាពពិការដោយបាត់បង់មុខងារ ពិការភាព និងពិការភាពដោយបាត់បង់សរីរាង្គ។
- គំរូវេជ្ជសាស្ត្រនៃពិការភាព គំរូសង្គមនៃពិការភាព
  - ❖ ២. គំរូនៃពិការភាព៖
    - ➢ ២.១. គំរូវេជ្ជសាស្ត្រនៃពិការភាព (**រូបទី ១៦.១**)
    - ➢ ២.២. គំរូសង្គមនៃពិការភាព
- បញ្ហាប្រឈមក្នុងការអប់រំកុមារពិការនៅប្រទេសកម្ពុជា
  - ❖ ៤. តម្រូវការអប់រំពិសេសសម្រាប់កុមារពិការនៅប្រទេសកម្ពុជា (**អត្ថបទដកស្រង់ ១៦.១ ៖** បរិយាបន្នអប់រំសម្រាប់កុមារ)។

## ៤. ឧទាហរណ៍នៃកិច្ចការពិភាក្សាជាក្រុមនិងសំណួរសន្ទនា

រយៈពេល៖ ២០នាទី

- មានជនពិការនៅក្នុងរទេះរុញប្រឈមមុខនឹងជណ្ដើរ (**រូបទី ១៦.២**)។ តើពិការភាពក្នុងស្ថានភាពនេះគាត់ប្រឈមមុខនៅឯណា? ចង្អុលបង្ហាញឱ្យបានច្រើនតាមដែលអ្នកអាចធ្វើបានដោយប្រើការស្រមើលស្រមៃរបស់អ្នក។
- តើជនពិការគួរទទួលបានការអប់រំដែរឬទេ? តើកុមារពិការនឹងអាចទទួលបានការអប់រំនៅកម្ពុជាដោយរបៀបណា?

កិច្ចការដែលគរុនិស្សិតគួរអាននិងស្វែងយល់ពីសៀវភៅសិក្សាគោល

- ចំណាត់ថ្នាក់អន្តរជាតិនៃមុខងារ ពិការភាព និងសុខភាព (ICF) ជាគំរូរួមបញ្ចូលគ្នានៃពិការភាព។
- តើសង្គមខ្មែរមានទស្សនៈយ៉ាងណាចំពោះជំងឺនិងភាពពិការ?

## ៥. ធនធាន

ប្រើប្រាស់ករណី និងយកអ្វីដែលមាននៅក្នុងសារព័ត៌មាន៖


- Nerrolyn Ramstrand et al., បទពិសោធន៍រស់នៅរបស់មនុស្សដែលត្រូវការឧបករណ៍សិប្បនិម្មិត ឬ orthoses នៅក្នុងព្រះរាជាណាចក្រកម្ពុជា៖ ការសិក្សាគុណភាព ទិន្នន័យប្បត្តិពិការភាព និងសុខភាព, ១៤(៣), ២០២១
  **តំណភ្ជាប់ ២.៤៖** https://doi.org/10.1016/j.dhjo.2021.101071
- Australia-Cambodia Cooperation for Equitable Sustainable Services
  **តំណភ្ជាប់ ២.៥៖** https://accesscambodia.org/meet-miss-chanreaksmey-a-champion-supporting-persons-with-disabilities/
- Australia-Cambodia Cooperation for Equitable Sustainable Services, INCLUSIVE DISABILITY SERVICES IN CAMBODIA,
  **តំណភ្ជាប់ ២.៦៖** https://accesscambodia.org/inclusive-disability-services-in-cambodia-2/
- UNICEF for every child Cambodia. Opening up a world of learning for children with disabilities
  **តំណភ្ជាប់ ២.៧៖** https://www.unicef.org/cambodia/stories/opening-world-learning-children-disabilities
- Betsy VanLeit *, Samol Channa, Prum Rithy, CHILDREN WITH DISABILITIES IN RURAL CAMBODIA: AN EXAMINATION OF FUNCTIONAL STATUS AND IMPLICATIONS FOR SERVICE DELIVERY
  **តំណភ្ជាប់ ២.៨៖** https://www.dinf.ne.jp/doc/english/asia/resource/apdrj/vol18_2007/cambodia_disabled_children.html

## ស្ថិតិប្រទេសកម្ពុជា៖

- Chapter 3 Disabled Population-Size and Distribution

  តំណភ្ជាប់ ២.៩៖ https://www.stat.go.jp/info/meetings/cambodia/pdf/rp5_ch30.pdf




- Cambodia Demographics and Health Survey 2014, Chapter 4 Disability. 41-45

  តំណភ្ជាប់ ២.១០៖ https://microdata.worldbank.org/index.php/catalog/2519

## វីដេអូ៖

- AL JAZEERA. Cambodians with disabilities: Advocating to help them find jobs

  តំណភ្ជាប់ ២.១១៖ https://www.msn.com/en-in/news/world/cambodians-with-disabilities-advocat-ing-to-help-them-find-jobs/vi-AAU២០១y

## ៦. ការវាយតម្លៃ

- **ចំណេះដឹងនិងជំនាញ៖** ឧទាហរណ៍ ចំណេះដឹងអំពីបញ្ញត្តិជាមូលដ្ឋាននៃជំងឺ ភាពពិការដោយបាត់បង់មុខងារពិការភាព និងពិការភាពដោយបាត់បង់សរីរាង្គ(ការធ្វើតេស្តចំណេះដឹង)។ ពន្យល់ពីគំរូវេជ្ជសាស្ត្រនៃពិការភាព និងគំរូសង្គមនៃពិការភាព(ការធ្វើតេស្តចំណេះដឹង)។
- **ឥរិយាបថសិក្សានិងការចូលរួម៖** ឧទាហរណ៍ សង្កេតមើលអាកប្បកិរិយារបស់គរុនិស្សិត និងការចូលរួមក្នុងការងារជាក្រុម។ ចាត់ឱ្យធ្វើរបាយការណ៍អំពីអ្វីដែលអ្នកបានរៀនពីការធ្វើការងារជាក្រុម អ្វីដែលអ្នកបានរៀនពីការស្តាប់បទបង្ហាញរបស់ក្រុមផ្សេងៗ និងបញ្ហាប្រឈមដែលអ្នកមានតាមរយៈការងារជាក្រុម។ វាយតម្លៃលើសំណួរ និងចម្លើយឆ្លើយឆ្លង។
- **សមត្ថភាពក្នុងការគិត វិនិច្ឆ័យ និងបញ្ចេញមតិ៖** ឧទាហរណ៍ ផ្តល់របាយការណ៍អំពីអ្វីដែលអ្នកបានរៀនពីការធ្វើការងារជាក្រុម អ្វីដែលអ្នកបានរៀនពីការស្តាប់បទបង្ហាញរបស់ក្រុមផ្សេងៗ និងបញ្ហាប្រឈមដែលអ្នកមានតាមរយៈការងារជាក្រុម។ វាយតម្លៃសមត្ថភាពក្នុងការពន្យល់កិច្ចការមួយយ៉ាងត្រឹមត្រូវ និងបញ្ចុះបញ្ចូលក្នុងបទបង្ហាញការងារជាក្រុម។ វាយតម្លៃសំណួរ និងចម្លើយឆ្លើយឆ្លង។ វាយតម្លៃសមត្ថភាពក្នុងការបង្កើតផ្ទាំងរូបភាពដើម្បីផ្តល់ព័ត៌មានសុខភាព។

ពិពណ៌នាអំពីគំនិតរបស់អ្នកអំពីអ្វីដែលសុខភាពសិក្សាអាចធ្វើបានដើម្បីកាត់បន្ថយការរើសអើង ការប្រកាន់ និងការមាក់ងាយចំពោះកុមារ ជនពិការ អ្នកដែលឆ្លងមេរោគអេដស៍ និងជំងឺឆ្លងផ្សេងទៀត(រាយការណ៍របាយការណ៍ចាត់ឱ្យធ្វើ)។

ហេតុអ្វីបានជាមានការរើសអើង ការប្រកាន់ ការមាក់ងាយចំពោះកុមារ ជនពិការ អ្នកដែលឆ្លងមេរោគអេដស៍ និងការឆ្លងមេរោគផ្សេងៗ? សរសេរគំនិតរបស់អ្នកលើកត្តាទាំងនេះ (រាយការណ៍របាយការណ៍ចាត់ឱ្យធ្វើ)។

## ៧. តំណភ្ជាប់

Chap. 3pdf
២.១, ២.៩

ACESS
២.២

unicef
២.៣

Jornal
២.៤

MeetMiss
២.៥

inclusive
២.៦

unicef
២.៧

DINF
២.៨

2014
២.១០

AL JAZEERA
២.១១

# មេរៀនទី ៣ ៤

# ជំពូកទី ២៖ រៀបរាងកាយរបស់អ្នកធ្វើការ

## ១. ទិដ្ឋភាពទូទៅ

យើងនឹងរៀននៅក្នុងជំពូកទី ១ ថាសុខភាពមនុស្សមានទិដ្ឋភាពជីវសាស្ត្រ ផ្លូវចិត្ត សង្គម និងស្មារតី ដែលជំពូកទី ២ នឹងសិក្សាពីមូលដ្ឋានជីវសាស្ត្រនៃសុខភាពមនុស្ស។ ជំពូកនេះគ្របដណ្តប់លើរចនាសម្ព័ន្ធជាមូលដ្ឋាននៃរាងកាយរបស់មនុស្សនិងមុខងាររបស់វាដែលគាំទ្រសកម្មភាពជីវិតរបស់មនុស្ស។ គរុនិស្សិតនឹងយល់ថា សកម្មភាពរាងកាយប្រចាំថ្ងៃត្រូវបានគាំទ្រដោយមុខងារនៃប្រព័ន្ធសរីរាង្គចំនួន ១០ រួមទាំងប្រព័ន្ធម៉ូទ័រនិងប្រព័ន្ធសរសៃឈាមបេះដូង ហើយពួកគេធ្វើការនៅក្នុងការសម្របសម្រួល និងកិច្ចសហប្រតិបត្តិការដើម្បីធ្វើឱ្យរាងកាយមនុស្សមានមុខងារចុះសម្រុងគ្នា។ រចនាសម្ព័ន្ធ និងមុខងារជាមូលដ្ឋាននៃរាងកាយរបស់មនុស្ស ដែលបានសិក្សានៅទីនេះនឹងក្លាយជាមូលដ្ឋានគ្រឹះសម្រាប់ការយល់ដឹងពីជំងឺឆ្លង ជំងឺទាក់ទងនឹងរបៀបរស់នៅ និងជំងឺផ្សេងៗទៀត (ជំពូកទី ៦ និងទី ៧) និងការសង្គ្រោះបឋមនៅសាលារៀន (ជំពូកទី ១៥) ដែលនឹងត្រូវបានគ្របដណ្តប់នៅជំពូកជាបន្តបន្ទាប់។

## ២. សេចក្តីផ្តើម

រយៈពេល៖ ៥នាទី

(១) ប្រើប្រាស់ស្ថិតិប្រទេសកម្ពុជា។

(២) ប្រើប្រាស់ករណី និងយកអ្វីដែលមាននៅក្នុងសារព័ត៌មាន។

(៣) សុំឱ្យគរុនិស្សិតចែករំលែកបទពិសោធន៍របស់ពួកគេ និងសង្ខេបការពិភាក្សាជាក្រុមនៅក្នុងបទបង្ហាញមួយ។ ជាឧទាហរណ៍ សួរអំពីបទពិសោធន៍នៃការរងរបួស ឬជំងឺ និងកំណត់ទីតាំងនៃសរីរាង្គ។ កម្រងសំណួរអំពីសរីរវិទ្យាសរីរាង្គ (ឧទាហរណ៍ បង្ហាញរូបភាព និងសុំឱ្យគរុនិស្សិតដាក់ឈ្មោះសរីរាង្គ)។

(៤) ណែនាំបទពិសោធន៍របស់គ្រូឧទ្ទេស។
គ្រូឧទ្ទេសនិយាយអំពីបទពិសោធន៍របស់ពួកគេជាមួយនឹងការរងរបួសនិងជំងឺ។

## ៣. បំភ្លឺបញ្ជាក់ និងកំណត់គោលបំណងសិក្សា និងបង្រៀន

រយៈពេល៖ ៦០នាទី

ការបង្រៀននៅក្នុងជំពូកទី ២ នឹងគ្របដណ្តប់លើចំណុចដូចខាងក្រោម៖

- ១. ទម្រង់រូបផ្តុំ និងមុខងារនៃសារពាង្គកាយរបស់មនុស្ស
  - ១.១ ទម្រង់រូបផ្តុំនៃរាងកាយមនុស្ស

មុខងារ និងប្រភេទសំខាន់ៗនៃសរីរាង្គនីមួយៗ (ប្រព័ន្ធ) ត្រូវពិនិត្យដោយប្រើតារាងទី ២.១ ។

- ២. ទម្រង់រូបផ្តុំ និងមុខងាររបស់សរីរាង្គ

មុខងាររបស់សរីរាង្គនីមួយៗ (ប្រព័ន្ធ) ត្រូវបានពន្យល់។

ទោះជាយ៉ាងណាក៏ដោយ ការពន្យល់អំពីសរីរាង្គ (ប្រព័ន្ធ) ក្រៅពីអ្វីដែលបានសិក្សានៅក្នុងជំពូកមួយទៀតនឹងត្រូវបានផ្តល់អាទិភាព (កែតម្រូវទៅតាមពេលវេលាបង្រៀន)។

ឧទាហរណ៍ ប្រព័ន្ធប្រសាទ (ជំពូកទី ៨) ប្រព័ន្ធបន្តពូជ (ជំពូកទី ១១) ប្រព័ន្ធភាពស៊ាំ (ជំពូកទី ៧)

- ៣. យន្តការដែលគាំទ្រសកម្មភាពរបស់មនុស្សក្នុងជីវិតប្រចាំថ្ងៃ
  - ៣.១. ថេរលំនឹងនៃផ្ទៃកខាងក្នុង និងយន្តការតម្រូវ
  - ៣.២. ការតម្រូវកម្តៅ

## ៤. ឧទាហរណ៍នៃកិច្ចការពិភាក្សាជាក្រុម និងសំណួរឆ្លើយឆ្លង

រយៈពេល៖ ៣៥នាទី

- ដោយប្រើគំរូរាងកាយមនុស្ស អត្ថបទ គេហទំព័រ។ល។ ពិនិត្យជាមួយក្រុមរចនាសម្ព័ន្ធនៃរាងកាយមនុស្ស (ទម្រង់ ទំនាក់ទំនងទីតាំង។ល។)។ គំនូរព្រាងខ្លីៗក៏ត្រូវបានណែនាំផងដែរ។
- គរុនិស្សិតនឹងធ្វើការជាក្រុមដើម្បីឆ្លើយសំណួរ «លំហាត់សម្រាប់ការគិតនិងការស្រាវជ្រាវបន្ថែម៖ [២-១] ប្រើព័ត៌មានអំពីសារពាង្គកាយ៖ សាកល្បងឆ្លើយសំណួរ!» នៅទំព័រទី ៣២ ហើយបង្ហាញវាដោយប្រើ PowerPoint ។

កិច្ចការដែលគរុនិស្សិតគួរអាន និងស្វែងយល់ពីសៀវភៅសិក្សាគោល៖

- ១. ទម្រង់រូបផ្តុំ និងមុខងារនៃសារពាង្គកាយរបស់មនុស្ស
- ២. ទម្រង់រូបផ្តុំ និងមុខងាររបស់សរីរាង្គ
  - ២.៨. ប្រព័ន្ធវិញ្ញាណ
  - ២.៩. ប្រដាប់បន្តពូជ
  - ២.១០. ប្រព័ន្ធភាពស៊ាំ

## ៥. ធនធាន

- The Human Body in Health and Illness ( 7th Edition )

  <E-Book>តំណភ្ជាប់ ៣-៤.១ ៖ https://www.amazon.co.jp/Human-Body-Health-Illness-Book-ebook/dp/B0943WB9Z6/ref=tmm_kin_swatch_0?_encoding=UTF8&qid=&sr=

- The BioDigital Human

  តំណភ្ជាប់ ៣-៤.២ ៖ https://www.biodigital.com/

  តំណភ្ជាប់ ៣-៤.៣ ៖ https://www.visiblebody.com/learn/

- A model of the human body
- Internal Organs | Human Body | Science Video Lecture

  តំណភ្ជាប់ ៣-៤.៤ ៖ https://www.youtube.com/watch?v=Yv0YKjgNKaA

- Human Body 101 | National Geographic

  តំណភ្ជាប់ ៣-៤.៥ ៖ https://www.youtube.com/watch?v=Ae4MadKPJC0

## ៦. ការវាយតម្លៃ

- **ចំណេះដឹងនិងជំនាញ៖** ឧទាហរណ៍ ពន្យល់ពីប្រភេទ និងមុខងារនៃសរីរាង្គសំខាន់ៗ (ការធ្វើតេស្តចំណេះដឹង របាយការណ៍របាយការណ៍ចាត់ឱ្យធ្វើ)។ ចំណេះដឹងអំពីនិយមន័យនៃប្រព័ន្ធថេរលំនឹង (homeostasis) (ការធ្វើតេស្តចំណេះដឹង)។ ដោយប្រើគំរូនៃរាងកាយមនុស្ស ចង្អុលទៅសរីរាង្គ ហើយសុំឱ្យគរុនិស្សិតឆ្លើយឈ្មោះនិងមុខងាររបស់ពួកគេ (ការធ្វើតេស្តចំណេះដឹង)។
- **ឥរិយាបថសិក្សានិងការចូលរួម៖** ឧទាហរណ៍ សង្កេតមើលអាកប្បកិរិយារបស់គរុនិស្សិត និងការចូលរួមក្នុងការងារជាក្រុម។ ចាត់ឱ្យធ្វើរបាយការណ៍អំពីអ្វីដែលអ្នកបានរៀនពីការធ្វើការងារជាក្រុម អ្វីដែលអ្នកបានរៀនពីការស្តាប់បទបង្ហាញរបស់ក្រុមផ្សេងៗ និងបញ្ហាប្រឈមដែលអ្នកមានតាមរយៈការងារជាក្រុម។ វាយតម្លៃសំណួរនិងចម្លើយឆ្លើយឆ្លង។
- **សមត្ថភាពក្នុងការគិត វិនិច្ឆ័យ និងបញ្ចេញមតិ៖** ឧទាហរណ៍ គ្រូឧទ្ទេសផ្តល់ឱ្យគរុនិស្សិតនូវកិច្ចការផ្ទះដើម្បីបង្កើតកម្រងសំណួរ និងចម្លើយសម្រាប់កុមារ (របាយការណ៍របាយការណ៍ចាត់ឱ្យធ្វើ)។ គ្រូគួរតែផ្តល់ឧទាហរណ៍នៃសំណួរដូចជា «តើទឹកនោមត្រូវបានផលិតឡើងដោយរបៀបណា?» «ហេតុអ្វីបានជាយើងកណ្តាស់?»

## ៧. តំណភ្ជាប់

៣-៤.១

៣-៤.២

៣-៤.៣

៣-៤.៤

៣-៤.៥

# មេរៀនទី ៥ ៦

# ជំពូកទី ៣៖ ការលូតលាស់ និងការអភិវឌ្ឍរបស់កុមារ

## ១. ទិដ្ឋភាពទូទៅ

គោលដៅចម្បងនៃសុខភាពសិក្សាគឺសិស្សកម្រិតបឋមសិក្សារហូតដល់សិស្សកម្រិតវិទ្យាល័យ។

លើសពីនេះទៅទៀត កុមារតូចៗដែលជាកម្មវត្ថុនៃការអប់រំមត្តេយ្យសិក្សាក៏អាចត្រូវបានចាត់ទុកថាជាកម្មវត្ថុនៃសុខភាពសិក្សាផងដែរ។ កុមារនៅក្នុងក្រុមអាយុទាំងនេះគឺជាមនុស្សនៅក្នុងដំណើរការនៃការអភិវឌ្ឍរហូតដល់ពេញវ័យ។

មូលដ្ឋានជីវសាស្ត្រនៃសុខភាពមនុស្សដែលបានសិក្សានៅក្នុងជំពូកទី២ ត្រូវបានសន្មតជាចម្បងក្នុងពេលពេញវ័យ។ ទោះយ៉ាងណាក៏ដោយ ទិដ្ឋភាពជីវសាស្ត្រ ផ្លូវចិត្ត សង្គម និងស្មារតីដែលបង្កើតឱ្យមានសុខភាពមនុស្សមានផ្លាស់ប្តូរពេញមួយជីវិត។

នៅក្នុងជំពូកទី ៣ យើងនឹងសិក្សាពីការផ្លាស់ប្តូរនេះទាក់ទងនឹងបញ្ញត្តិនៃការ លូតលាស់ និងការអភិវឌ្ឍ។ ជំពូកនេះផ្តោតលើការរីកលូតលាស់ និងការអភិវឌ្ឍតាំងពីតូចរហូតដល់ចប់កម្រិតសាលាបឋមសិក្សា ក្នុងអំឡុងអាយុប្រហែល ១២ឆ្នាំ ពោលគឺ ការផ្លាស់ប្តូរផ្នែករាងកាយ ម៉ូទ័រ ការយល់ដឹង និងសមត្ថភាពផ្លូវចិត្ត និងសង្គម។ សុខភាពក្នុងការលូតលាស់ និងការអភិវឌ្ឍរបស់មនុស្សគឺជាដំណើរការដ៏ស្វាហាប់ ហើយសុខភាពរបស់កុមារគួរតែត្រូវបានមើលពីទស្សនៈថា តើពួកគេកំពុងដើរតាមគន្លងនៃការលូតលាស់ និងការអភិវឌ្ឍសមស្របដែរឬទេ។ ដើម្បីវាយតម្លៃការលូតលាស់និងការអភិវឌ្ឍ ចាំបាច់ត្រូវរៀនអំពីគោលការណ៍របស់វាដែលត្រូវបានពន្យល់នៅក្នុងជំពូកនេះ។

## ២. សេចក្តីផ្តើម

**រយៈពេល៖ ១០នាទី**

(១) ប្រើប្រាស់ស្ថិតិប្រទេសកម្ពុជា។

- Physical Growth of Primary School Children in Cambodia, Int. J. School Health, 2021:8(1)

  **តំណភ្ជាប់ ៥-៦.១៖** https://intjsh.sums.ac.ir/article_47290.html

(២) ប្រើប្រាស់ករណី និងយកអ្វីដែលមាននៅក្នុងព័ត៌មាន។

- Education on development of children still limited in communes, Khmer Times, 15 Jan 2022

  **តំណភ្ជាប់ ៥-៦.២៖** https://www.khmertimeskh.com/501007369/education-on-development-of-children-still-limited-in-communes/

- Stunting in children down, wasting remains an issue, The Phnom Penh Post, 23 June 2022

  តំណភ្ជាប់ ៥-៦.៣៖ https://www.phnompenhpost.com/national/stunting-children-down-wasting-remains-issue

(៣) ឱ្យគរុនិស្សិតចែករំលែកបទពិសោធន៍របស់ពួកគេនិងសង្ខេបការពិភាក្សាជាក្រុមនៅក្នុងបទបង្ហាញ។ (កិច្ចការសម្រាប់សេចក្តីផ្តើម៖ ចូរយើងគូររូបរាងកាយពេញលេញ(ឬតែមុខ) របស់កុមារ និងមនុស្សពេញវ័យ។ តើអ្វីជាភាពខុសគ្នារវាងកុមារនិងមនុស្សពេញវ័យនៅក្នុងគំនូរព្រាងទាំងនោះ?)

(៤) ណែនាំបទពិសោធន៍របស់គ្រូឧទ្ទេស។

## ៣. បញ្ជាក់បំភ្លឺ កំណត់គោលបំណងសិក្សា និងបង្រៀន

**រយៈពេល៖ ៥០នាទី**

ការបង្រៀននៅក្នុងជំពូកទី ៣ នឹងគ្របដណ្តប់លើប្រធានបទដូចខាងក្រោម៖

- ១. ការអភិវឌ្ឍរបស់មនុស្ស
- ២. គោលការណ៍នៃការលូតលាស់ និងការអភិវឌ្ឍរបស់កុមារ
- ៣. អំឡុងពេលនៃការលូតលាស់ និងការអភិវឌ្ឍទៅតាមវ័យ

## ៤. ឧទាហរណ៍នៃកិច្ចការពិភាក្សាជាក្រុម និងសំណួរឆ្លើយឆ្លង

**រយៈពេល៖ ៤០នាទី**

- តើកត្តាអ្វីខ្លះដែលរួមចំណែកដល់ការអភិវឌ្ឍសុខភាពរបស់កុមារនៅប្រទេសកម្ពុជា?
- ពិចារណាពីបញ្ហាដែលគំរាមកំហែងដល់ការលូតលាស់ និងការអភិវឌ្ឍរបស់កុមារនៅប្រទេសកម្ពុជានាពេលបច្ចុប្បន្ន (និងបញ្ហាដែលទំនងជាគំរាមកំហែងដល់អនាគត)។

កិច្ចការដែលគរុនិស្សិតគួរអាន និងស្វែងយល់ពីសៀវភៅសិក្សាគោល៖

- សេចក្តីសង្ខេបនៃសូចនាករអភិវឌ្ឍន៍សម្រាប់កុមារតូច និងវ័យសិក្សា (**តារាងទី ៣.១**)

## ៥. ធនធាន

**វីដេអូ៖**

- Factors That Influence the Growth and Development of a Child

  តំណភ្ជាប់ ៥-៦.៤៖ https://www.youtube.com/watch?v=FKvcXo3e78g
- Principles Of Growth and Development

  តំណភ្ជាប់ ៥-៦.៥៖ https://www.youtube.com/watch?v=2gEhDve9DpU
- Growth and Development of Infants, Toddlers, Preschoolers and School Aged Children

  តំណភ្ជាប់ ៥-៦.៦៖ https://www.youtube.com/watch?v=JEAR8PIDXXc

- Chapter 28 Growth & Development of the school age child

  តំណភ្ជាប់ ៥-៦.៧៖ https://www.youtube.com/watch?v=37m3jgroUu8

- FYI: Growth and Development of Adolescents, Young Adults, Middle Adults, and Mature Adults

  តំណភ្ជាប់ ៥-៦.៨៖ https://www.youtube.com/watch?v=zPpbzKoYZ4M

### អត្ថបទស្រាវជ្រាវ៖

- Physical Growth of Primary School Children in Cambodia, Int. J. School Health, 2021:8(1)

  តំណភ្ជាប់ ៥-៦.៩៖ https://intjsh.sums.ac.ir/article_47290_9a6b7e6c5255b7205e0e9c75d64c3a94.pdf

## ៦. ការវាយតម្លៃ

- **ចំណេះដឹងនិងជំនាញ៖** ឧទាហរណ៍ ចំណេះដឹងអំពីនិយមន័យនៃការលូតលាស់ និងការអភិវឌ្ឍ (ការធ្វើតេស្តចំណេះដឹង)។ ពន្យល់អំពីទិសដៅនៃការលូតលាស់និងការអភិវឌ្ឍរាងកាយ (ការធ្វើតេស្តចំណេះដឹង)។ ពន្យល់អំពីបញ្ញត្តិនៃរយៈពេលសំខាន់(critical period) និងរយៈពេលលូតលាស់ខ្លាំង(sensitive period)។ ពន្យល់ពីកត្តាដែលជះឥទ្ធិពលដល់ការលូតលាស់ និងការអភិវឌ្ឍរបស់កុមារ។
- **ឥរិយាបថសិក្សានិងការចូលរួម៖** ឧទាហរណ៍ សង្កេតមើលអាកប្បកិរិយារបស់គរុនិស្សិត និងការចូលរួមក្នុងការងារជាក្រុម។ ចាត់ឱ្យធ្វើរបាយការណ៍អំពីអ្វីដែលអ្នកបានរៀនពីការធ្វើការងារជាក្រុម អ្វីដែលអ្នកបានរៀនពីការស្តាប់បទបង្ហាញរបស់ក្រុមផ្សេងៗ និងបញ្ហាប្រឈមដែលអ្នកមានអារម្មណ៍តាមរយៈការងារជាក្រុម។ វាយតម្លៃសំណួរ និងចម្លើយបែបឆ្លើយឆ្លង។
- **សមត្ថភាពក្នុងការគិត វិនិច្ឆ័យ និងបញ្ចេញមតិ៖** ឧទាហរណ៍ ផ្តល់របាយការណ៍អំពីអ្វីដែលអ្នកបានរៀនពីការធ្វើការងារជាក្រុម អ្វីដែលអ្នកបានរៀនពីការស្តាប់បទបង្ហាញរបស់ក្រុមផ្សេងៗ និងបញ្ហាប្រឈមដែលអ្នកមានតាមរយៈការងារជាក្រុម។ វាយតម្លៃសមត្ថភាពក្នុងការពន្យល់កិច្ចការមួយយ៉ាងត្រឹមត្រូវនិងបញ្ចុះបញ្ចូលក្នុងបទបង្ហាញការងារជាក្រុម។ វាយតម្លៃសំណួរនិងចម្លើយឆ្លើយឆ្លង។

ពិពណ៌នាអំពីគំនិតរបស់អ្នកអំពីរបៀបដែលការរៀនអំពីការលូតលាស់ និងការអភិវឌ្ឍរបស់កុមារគឺមានប្រយោជន៍ និងមានសារៈសំខាន់ចំពោះគ្រូបង្រៀននៅសាលារៀន (រាយការណ៍របាយការណ៍ចាត់ឱ្យធ្វើ)។

## ៧. តំណភ្ជាប់

Growth

៥-៦.១

15, Jan.

៥-៦.២

23, June

៥-៦.៣

Factors

៥-៦.៤

Principles

៥-៦.៥

Infant

៥-៦.៦

Chap. 28

៥-៦.៧

Adolescents

៥-៦.៨

Int. J.

៥-៦.៩

# មេរៀនទី ៧

# ជំពូកទី៤៖ ភាពស្អាត អនាម័យ និងសុខភាព

## ១. ទិដ្ឋភាពទូទៅ

ដើម្បីទប់ស្កាត់ការឆ្លងជំងឺ ការពុលអាហារ ការរងរបួស និងគ្រោះថ្នាក់ វាមានសារៈសំខាន់ណាស់ក្នុងការថែរក្សារាងកាយ អាហារ និងបរិស្ថានភ្លាមៗឱ្យស្អាត អនាម័យ និងសុវត្ថិភាព។ ជំពូកទី៤ ផ្តោតលើមូលដ្ឋាននៃការរស់នៅសម្រាប់គោលបំណងនេះ។ ជាដំបូង គរុនិស្សិតនឹងលើកកម្ពស់ការយល់ដឹងជាមូលដ្ឋានរបស់ពួកគេអំពីភាពស្អាត និងអនាម័យ ហើយបន្ទាប់មករៀនពីការអនុវត្តជាក់លាក់ដើម្បីជួយកុមាររៀបចំខ្លួនប្រាណ អាហារ និងជុំវិញផ្ទះ ថ្នាក់រៀន និងសហគមន៍មូលដ្ឋានឱ្យបានស្អាត មានអនាម័យ និងសុវត្ថិភាព។

## ២. សេចក្តីផ្តើម

**រយៈពេល៖ ៥នាទី**

(១) ប្រើប្រាស់ស្ថិតិប្រទេសកម្ពុជា។

(២) ប្រើប្រាស់ករណី និងយកអ្វីដែលមាននៅក្នុងព័ត៌មាន។

- UNICEF: Scaling the School Sanitation and Hygiene Education Pilot in Vietnam,

  **តំណភ្ជាប់ ៧.១៖** https://gdc.unicef.org/resource/scaling-school-sanitation-and-hygiene-education-pilot-vietnam

- UNICEF: Better sanitation drives better education in Cambodia -How a school's sanitation situation was transformed by the staff and the local community working together.

  **តំណភ្ជាប់ ៧.២៖** https://www.unicef.org/cambodia/stories/better-sanitation-drives-better-education-cambodia

- WaterAid: Harnessing young people's skills to improve hygiene in Cambodian healthcare, 5 Mar 2020.

  **តំណភ្ជាប់ ៧.៣៖** https://washmatters.wateraid.org/blog/harnessing-young-peoples-skills-to-improve-hygiene-in-cambodian-healthcare

(៣) សុំឱ្យគរុនិស្សិតចែករំលែកបទពិសោធន៍របស់ពួកគេ និងសង្ខេបការពិភាក្សាជាក្រុមនៅក្នុងបទបង្ហាញមួយ។

សួរគរុនិស្សិតអំពីបរិស្ថានដែលគ្មានអនាម័យដែលពួកគេធ្លាប់ជួបជាមួយ និងអ្វីដែលគ្មានអនាម័យ ឬអាកប្បកិរិយាគ្មានអនាម័យដែលសង្កេតឃើញជុំវិញពួកគេ។

តើអ្នកធ្លាប់សម្អាតនៅសាលារៀនទេ? សួរថាតើវាធ្វើឱ្យអ្នកមានអារម្មណ៍យ៉ាងណា។

(៤) ណែនាំបទពិសោធន៍របស់គ្រូឧទ្ទេស។

## ៣. បញ្ជាក់បំភ្លឺ កំណត់គោលបំណងសិក្សា និងបង្រៀន

រយៈពេល៖ ២០នាទី

ការបង្រៀននៅក្នុងជំពូកទី ៤ នឹងគ្របដណ្តប់លើប្រធានបទដូចខាងក្រោម៖

- ❖ ១. ភាពស្អាត អនាម័យផ្ទាល់ខ្លួន និងបរិស្ថាន(ផ្ទះ សាលារៀន ទីក្រុង/សហគមន៍)
  - ➢ ១.៣. អនាម័យសាលារៀន
  - ➢ ១.៤. អនាម័យតាមទីក្រុងនិងសហគមន៍
- ❖ ២. គន្លឹះក្នុងការបង្កើតបរិយាកាសផ្ទាល់ខ្លួនស្អាតនិងអនាម័យ
  - ➢ ២.១. ការបង្ការការពុលចំណីអាហារ
  - ➢ ២.២. ការសម្អាត
- ❖ ៣. ការអនុវត្តអនាម័យល្អ
  - ➢ ៣.១. បច្ចេកទេសលាងដៃប្រកបដោយប្រសិទ្ធភាព (សូមមើល «**លំហាត់សម្រាប់ការគិតនិងការស្រាវជ្រាវបន្ថែម [៤-១]** »)។

## ៤. ឧទាហរណ៍នៃកិច្ចការពិភាក្សាជាក្រុមនិងសំណួរឆ្លើយឆ្លង

រយៈពេល៖ ២៥នាទី

ប្រមើលមើលកន្លែងដែលទំនងជាត្រូវបានទុកចោលដោយមិនបានសម្អាតក្នុងអំឡុងពេលលាងដៃ ហើយពិភាក្សា និងធ្វើការជាក្រុមលើវិធីសាស្ត្រលាងដៃដ៏មានប្រសិទ្ធភាព។ បន្ទាប់ពីការពិសោធន៍ការលាងដៃពិតប្រាកដ ក្រុមនឹងចែករំលែកផ្នែកនៃដៃរបស់ពួកគេដែលមិនបានលាង។ សូមមើល «លំហាត់សម្រាប់ការគិតនិងការស្រាវជ្រាវនាពេលអនាគត [៤-១]» ។

កិច្ចការដែលគរុនិស្សិតគួរអាននិងស្វែងយល់ពីសៀវភៅសិក្សា ៖

- ❖ ១. ភាពស្អាត អនាម័យផ្ទាល់ខ្លួន និងបរិស្ថាន
  - ➢ ១.១. ភាពស្អាតនិងអនាម័យផ្ទាល់ខ្លួន
  - ➢ ១.២. ភាពស្អាតនិងអនាម័យក្នុងផ្ទះ

## ៥. ធនធាន

- UNICEF: Water, Sanitation and Hygiene -For every child, a healthy environment.

  តំណភ្ជាប់ ៧.៤៖ https://www.unicef.org/cambodia/water-sanitation-and-hygiene

- The World Bank: Economic Impacts of Sanitation in Cambodia,

  តំណភ្ជាប់ ៧.៥៖ https://openknowledge.worldbank.org/bitstream/handle/10986/17262/442950v20WSP0B0C00ESI0Cambodia0full.pdf?sequence=1&isAllowed=y

### វីដេអូ៖

- Japanese Students Clean Classrooms to Learn Life Skills.

  តំណភ្ជាប់ ៧.៦៖ https://www.youtube.com/watch?v=jv4oNvxCY5k

- This Is How Japan Schools Teach Cleanliness.

  តំណភ្ជាប់ ៧.៧៖ https://www.youtube.com/watch?v=yE3GYkn5ngw

- Tidy up the classroom.

  តំណភ្ជាប់ ៧.៨៖ https://www.youtube.com/watch?v=TlColbk6Doc

- I Care to Clean - Schools.

  តំណភ្ជាប់ ៧.៩៖ https://www.youtube.com/watch?v=6N6NeZ3Rgv4

- Keeping food safe! - The basics of food safety.

  តំណភ្ជាប់ ៧.១០៖ https://www.youtube.com/watch?v=nGKv7I3saK4

- SNV Netherlands Development Organization: Rural Water Supply in Cambodia.

  តំណភ្ជាប់ ៧.១១៖ https://www.youtube.com/watch?v=ZDdHrfDtmi8&t=13s

## ៦. ការវាយតម្លៃ

- **ចំណេះដឹងនិងជំនាញ៖** ឧទាហរណ៍ ចំណេះដឹងអំពីនិយមន័យនៃភាពស្អាត និងអនាម័យ(ការធ្វើតេស្តចំណេះដឹង)។ ពន្យល់អំពីវិធានការបង្ការការពុលអាហារ(ការធ្វើតេស្តចំណេះដឹង)។ ពន្យល់អំពី «ប្រើប្រាស់ល្អបំផុតមុនកាលបរិច្ឆេទ (best-before)» និង «ប្រើប្រាស់ត្រឹមកាលបរិច្ឆេទ(use-by date)» (ការធ្វើតេស្តចំណេះដឹង)។ តើគរុនិស្សិតអាចបង្ហាញពីវិធីសាស្ត្រត្រឹមត្រូវនៃការលាងដៃដែលមានប្រសិទ្ធភាពដែរឬទេ?
- **អាកប្បកិរិយានិងការចូលរួមក្នុងការរៀនសូត្រ៖** ឧទាហរណ៍ សង្កេតមើលអាកប្បកិរិយារបស់គរុនិស្សិត និងការចូលរួមក្នុងការងារជាក្រុម។ ចាត់ឱ្យធ្វើរបាយការណ៍អំពីអ្វីដែលអ្នកបានរៀនពីការធ្វើការងារជាក្រុម អ្វីដែលអ្នកបានរៀនពីការស្តាប់បទបង្ហាញរបស់ក្រុមផ្សេងៗ និងបញ្ហាប្រឈមដែលអ្នកមានតាមរយៈការងារជាក្រុម។ វាយតម្លៃសំណួរនិងចម្លើយឆ្លើយឆ្លង។

- **សមត្ថភាពក្នុងការគិត វិនិច្ឆ័យ និងបញ្ចេញមតិ៖** ឧទាហរណ៍ ផ្តល់របាយការណ៍អំពីអ្វីដែលអ្នកបានរៀនពីការធ្វើការងារជាក្រុម អ្វីដែលអ្នកបានរៀនពីការស្តាប់បទបង្ហាញរបស់ក្រុមផ្សេងៗ និងបញ្ហាប្រឈមដែលអ្នកមានតាមរយៈការងារជាក្រុម។ វាយតម្លៃសមត្ថភាពក្នុងការពន្យល់កិច្ចការមួយយ៉ាងត្រឹមត្រូវនិងបញ្ចុះបញ្ចូលក្នុងបទបង្ហាញការងារជាក្រុម។ វាយតម្លៃសំណួរនិងចម្លើយឆ្លើយឆ្លង។

ស្រាវជ្រាវបញ្ហាការចោលសំរាមនៅក្នុងប្រទេសកំពុងអភិវឌ្ឍ ហើយរាយការណ៍សង្ខេបអំពីមូលហេតុដែលបញ្ហាបែបនេះកំពុងកើតឡើង និងរបៀបដែលវាប៉ះពាល់ដល់បរិស្ថាន ជីវិត និងសុខភាពរបស់មនុស្ស (រាយការណ៍របាយការណ៍ចាត់ឱ្យធ្វើ)។

## ៧. តំណភ្ជាប់

Vietnam
៧.១

Cambodia
៧.២

Healthcare
៧.៣

Water
៧.៤

Economic
៧.៥

Japanese
៧.៦

Cleanliness
៧.៧

Classroom
៧.៨

I Care
៧.៩

foodsafe
៧.១០

RuralWater
៧.១១

# មេរៀនទី ៨ ៩

# ជំពូកទី ៥៖ របៀបរស់នៅ និងសុខភាព

## ១. ទិដ្ឋភាពទូទៅ

អាយុរបស់គរុនិស្សិតសាលាបឋមសិក្សាគឺជាពេលវេលាដ៏សំខាន់សម្រាប់ពួកគេក្នុងការទទួលបានទម្លាប់របៀបរស់នៅជាមូលដ្ឋាន។ សំខាន់ជាងនេះទៅទៀត យើងត្រូវយល់ពីរបៀបដែលទម្លាប់របៀបរស់នៅជាមូលដ្ឋានប៉ះពាល់ដល់ការអភិវឌ្ឍសុខភាពរបស់កុមារដែលយើងនឹងសិក្សានៅក្នុងជំពូកទី ៣។ ដូច្នេះហើយ នៅក្នុងជំពូកទី ៥ យើងនឹងសិក្សាពីទំនាក់ទំនងរវាងការលូតលាស់ ការអភិវឌ្ឍ និងទម្លាប់របៀបរស់នៅទាក់ទងនឹងចង្វាក់ជីវិតប្រចាំថ្ងៃ ការហាត់ប្រាណ អាហារ/អាហារូបត្ថម្ភ និងការទទួលទានដំណេក។ គួរកត់សម្គាល់ថា តាមរយៈការពិតរបស់កុមារកម្ពុជា វាមានបញ្ហាទាក់ទងនឹងការអនុវត្តសកម្មភាពកាយសម្បទាដែលមានសុខភាពល្អ របបអាហារ និងអាហារូបត្ថម្ភដែលមានសុខភាពល្អ ហើយចំណុចទាំងនេះគួរតែយល់ច្បាស់អំពីខ្លឹមសារនៃជំពូកនេះ។

## ២. សេចក្ដីផ្ដើម

រយៈពេល៖ ៥នាទី

(១) ប្រើប្រាស់ស្ថិតិប្រទេសកម្ពុជា។

- Global School-based Student Health Survey Cambodia 2013 Fact Sheet,

  តំណភ្ជាប់ ៨-៩.១៖ https://cdn.who.int/media/docs/default-source/ncds/ncd-surveillance/data-reporting/cambodia/gshs/2013_cambodia_gshs_fact_sheet.pdf?sfvrsn=3fde50db_3&download=true

(២) ប្រើប្រាស់ករណី និងយកអ្វីដែលមាននៅក្នុងសារព័ត៌មាន។

- Healthy diet is key goal for Cambodia to achieve by 2030, Khmer Times 15 Apr 2022.

  តំណភ្ជាប់ ៨-៩.១៖ https://www.khmertimeskh.com/501058110/healthy-diet-is-key-goal-for-cambodia-to-achieve-by-2030/

- Unstandardised snacks are leading to malnutrition in young children, Khmer Times 9 Feb 2022.

  តំណភ្ជាប់ ៨-៩.៖ https://www.khmertimeskh.com/501021386/unstandardised-snacks-are-leading-to-malnutrition-in-young-children/

- Sustainable food systems by 2030, pledge gov't and UN, Khmer Times 16 Sep 2021.

  តំណភ្ជាប់ ៨-៩.៤៖ https://www.khmertimeskh.com/50935941/sustainable-food-systems-by-2030-pledge-govt-and-un/

(3) សុំឱ្យគរុនិស្សិតចែករំលែកបទពិសោធន៍របស់ពួកគេ និងសង្ខេបការពិភាក្សាជាក្រុមនៅក្នុងបទបង្ហាញមួយ។ សួរគរុនិស្សិតថា តើពួកគេមានការព្រួយបារម្ភអំពីផលប៉ះពាល់នៃរបៀបរស់នៅចំពោះសុខភាពរបស់ពួកគេដែរឬទេ។

(4) ណែនាំបទពិសោធន៍របស់គ្រូឧទ្ទេស។

## ៣. បញ្ជាក់បំភ្លឺ កំណត់គោលបំណងសិក្សា និងបង្រៀន

### រយៈពេល៖ ៦០នាទី

ការបង្រៀននៅក្នុងជំពូកទី ៥ គ្របដណ្តប់លើប្រធានបទដូចខាងក្រោម៖

- អ្វីដែលធ្វើឱ្យមានទម្លាប់រស់នៅដែលមានសុខភាពល្អ
  - ❖ ១. ទម្លាប់របៀបរស់នៅ និងសុខភាពរបស់កុមារ
    - ➢ ១.១. ការលូតលាស់/ការអភិវឌ្ឍនិងទម្លាប់របៀបរស់នៅ (**រូបទី ៥.១៖** លំនាំនៃការលូតលាស់ការអភិវឌ្ឍរបស់កុមារ)
    - ➢ ១.២. ការបង្កើតទម្លាប់របៀបរស់នៅជាមូលដ្ឋាន (**រូបទី ៥.២៖** ឧទាហរណ៍នៃចង្វាក់ជីវិតល្អនិងមិនល្អក្នុងជីវិតប្រចាំថ្ងៃ)
  - ❖ ២. របបអាហារ/អាហារូបត្ថម្ភ និងសុខភាព ប្រព័ន្ធអេកូឡូស៊ី និងសុខភាពមនុស្ស
    - ➢ ២.១. តើការទទួលទានមានន័យដូចម្តេចចំពោះសុខភាពមនុស្ស
    - ➢ ២.២. លក្ខណៈនៃឥទ្ធិពលរបបអាហារ
    - ➢ ២.៣. របបអាហារដែលល្អសម្រាប់សុខភាព (**រូបទី ៥.៤៖** សារជាតុចិញ្ចឹម និងតួនាទីសំខាន់ៗព្រមទាំងប្រភពចំណីអាហារចម្បង)

## ៤. ឧទាហរណ៍នៃកិច្ចការពិភាក្សាជាក្រុម និងសំណួរឆ្លើយឆ្លង

### រយៈពេល៖ ៣៥នាទី

- គរុនិស្សិតក្នុងក្រុមនីមួយៗពន្យល់៖
  - **រូបទី ៥.៥៖** ពីរ៉ាមីតអាហារនៅប្រទេសកម្ពុជា
  - **តារាងទី ៥.២៖** និយមន័យអាហារទាំង ៦ប្រភេទ និងស្តង់ដាបរិមាណទទួលទាន
- គរុនិស្សិតម្នាក់ៗនឹងអនុវត្តប្រភេទ បរិមាណនៃអាហារ និងអាហារសម្រន់ដែលពួកគេបរិភោគជារៀងរាល់ថ្ងៃទៅតាមពីរ៉ាមីតអាហារក្នុង **រូបទី ៥.៥** ហើយប្រៀបធៀបវាទៅនឹង **តារាងទី ៥.២**។ លទ្ធផលនឹងត្រូវបានសង្ខេប និងបង្ហាញនៅក្នុងស្លាយ PowerPoint។ ស្តាប់ការធ្វើបទបង្ហាញរបស់អ្នកដទៃផ្តោតលើបញ្ហា និងចំណុចល្អ

ព្រមទាំងផ្តល់ដំបូន្មានដើម្បីកែលម្អទម្លាប់នៃការញ៉ាំរបស់ពួកគេ។ (សូមមើល «**លំហាត់សម្រាប់ការគិត និងការស្រាវជ្រាវបន្ថែម [៥-៣]**»)

- គរុនិស្សិតម្នាក់ៗប្រើ «តារាងត្រួតពិនិត្យទម្លាប់របៀបរស់នៅ» ដើម្បីកំណត់និងបង្ហាញចំណុចល្អ និងបញ្ហានៃរបៀបរស់នៅរបស់ពួកគេ។ ស្តាប់ការធ្វើបទបង្ហាញរបស់អ្នកដទៃ ចង្អុលបញ្ហា ចំណុចល្អ និងផ្តល់ដំបូន្មានដើម្បីកែលម្អជីវិតរបស់ពួកគេ។ (សូមមើល «**លំហាត់សម្រាប់ការគិត និងការស្រាវជ្រាវបន្ថែម [៥-៦]**»)

កិច្ចការដែលគរុនិស្សិតគួរអាននិងស្វែងយល់ពីសៀវភៅសិក្សា

- ❖ សារៈសំខាន់នៃសារធាតុចិញ្ចឹម
  - ➢ ២.៣. របបអាហារដែលល្អសម្រាប់មានសុខភាព
    - (១) កាបូអ៊ីដ្រាត (២) លីពីត ខ្លាញ់ (៣) ប្រូតេអ៊ីន (៤) សារធាតុរ៉ែ (៥) វីតាមីន
    - (៦) អាហារមានជាតិសរសៃ (ជាតិស្ករដែលមិនអាចរំលាយបាន (saccharides))
  - ➢ ២.៤. ទម្លាប់ជ្រើសរើសអាហារប្រកបដោយសុវត្ថិភាព និងសន្តិសុខ
- ❖ ៣. លំហាត់ប្រាណ និងសុខភាព

## ៥. ឯកសារ


- Federation for International Development Relief. Development of recommended dietary allowance and food-based dietary guidelines for school-aged children in Cambodia. 2017.
  **តំណភ្ជាប់ ៨-៩.៥៖** http://www.fao.org/3/I9704EN/i9704en.pdf
- Fred Hutchinson Cancer Research Center: Physical Activity What do Cambodians need to know,
  **តំណភ្ជាប់ ៨-៩.៦៖** https://ethnomed.org/wp-content/uploads/2020/03/Cambodian-Phys-Act-flip-chart-2010.pdf
- Sok S, et al.: Health Behaviors among Male and Female University Students in Cambodia: A Cross-Sectional Survey, Journal of Environmental and Public Health ss-6:1-10, 2020.
  **តំណភ្ជាប់ ៨-៩.៧៖** https://www.ncbi.nlm.nih.gov/pmc/articles/PMC7086439/

**វីដេអូ៖**

- Healthy Eating for Kids - Compilation វីដេអូ: Carbohydrates, Proteins, Vitamins, Mineral Salts, Fats, **តំណភ្ជាប់ ៨-៩.៨៖** https://www.youtube.com/watch?v=EhfOZMOF9W4

## ៦. ការវាយតម្លៃ

- **ចំណេះដឹងនិងជំនាញ៖** ឧទាហរណ៍ អ្វីទៅជាសារធាតុចិញ្ចឹមសំខាន់ៗ ៥ យ៉ាង? (ការធ្វើតេស្តចំណេះដឹង) ពន្យល់អំពី «ចង្វាក់ល្អនៃជីវិតប្រចាំថ្ងៃ» និង «ចង្វាក់មិនល្អនៃជីវិតប្រចាំថ្ងៃ» (ការធ្វើតេស្តចំណេះដឹង)។ តើអាហារទាំង ៦ប្រភេទ មានអ្វីខ្លះ?
- **ឥរិយាបថសិក្សានិងការចូលរួម៖** ឧទាហរណ៍ សង្កេតមើលអាកប្បកិរិយារបស់គរុនិស្សិតនិងការចូលរួមក្នុងការងារជាក្រុម។ ចាត់ឱ្យធ្វើរបាយការណ៍អំពីអ្វីដែលអ្នកបានរៀនពីការធ្វើការងារជាក្រុម អ្វីដែលអ្នកបានរៀនពីការស្តាប់បទបង្ហាញរបស់ក្រុមផ្សេងៗ និងបញ្ហាប្រឈមដែលអ្នកមានតាមរយៈការងារជាក្រុម។ តើគរុនិស្សិតយល់ដឹងកាន់តែច្រើនអំពីបញ្ហាប្រឈមនៃការរស់នៅរបស់ពួកគេ ហើយតើចេតនារបស់ពួកគេក្នុងការកែលម្អបញ្ហាទាំងនោះត្រូវបានពង្រឹងដែរឬទេ? វាយតម្លៃសំណួរនិងចម្លើយឆ្លើយឆ្លង។
- **សមត្ថភាពក្នុងការគិត វិនិច្ឆ័យ និងបញ្ចេញមតិ៖** ឧទាហរណ៍ ផ្តល់របាយការណ៍អំពីអ្វីដែលអ្នកបានរៀនពីការធ្វើការងារជាក្រុម អ្វីដែលអ្នកបានរៀនពីការស្តាប់បទបង្ហាញរបស់ក្រុមផ្សេងៗ និងបញ្ហាប្រឈមដែលអ្នកមានតាមរយៈការងារជាក្រុម។ វាយតម្លៃសមត្ថភាពក្នុងការពន្យល់កិច្ចការមួយយ៉ាងត្រឹមត្រូវ និងបញ្ចុះបញ្ចូលក្នុងបទបង្ហាញការងារជាក្រុម។ វាយតម្លៃសំណួរនិងចម្លើយឆ្លើយឆ្លង។ ស្រាវជ្រាវពីទម្លាប់មិនល្អរបស់អ្នកដែលនៅជុំវិញអ្នក ពិចារណាអំពីអ្វីដែលអ្នកអាចធ្វើបានដើម្បីផ្លាស់ប្តូរអាកប្បកិរិយារបស់ពួកគេ និងសរសេររបាយការណ៍មួយ (រាយការណ៍របាយការណ៍ចាត់ឱ្យធ្វើ)។

## ៧. តំណភ្ជាប់

| | | | |
|---|---|---|---|
| ៨-៩.១ | ៨-៩.២ | ៨-៩.៣ | ៨-៩.៤ |
| ៨-៩.៥ | ៨-៩.៦ | ៨-៩.៧ | ៨-៩.៨ |

# មេរៀនទី ១០ ១១

# ជំពូកទី ៦៖ ការបង្ការជំងឺ បណ្តាលមកពីរបៀបរស់នៅ

## ១. ទិដ្ឋភាពទូទៅ

បញ្ហាប្រឈមក្នុងអំឡុងឆ្នាំនៃការអភិវឌ្ឍគឺ ការស្វែងយល់ និងទទួលបានទម្លាប់របៀបរស់នៅដែលមានសុខភាពល្អ ដូចដែលយើងបានរៀននៅក្នុងជំពូកទី៥។ ទោះជាយ៉ាងណាក៏ដោយ វាមិនមែនតែងតែងាយស្រួលក្នុងការថែរក្សារបៀបរស់នៅដែលមានសុខភាពល្អនោះទេ។ នៅពេលដែលមនុស្សចាប់ផ្តើមជីវិតរបស់ពួកគេនៅក្នុងសង្គម មនុស្សពេញវ័យពួកគេច្រើនតែបង្កើតទម្លាប់របៀបរស់នៅដែលមានផលប៉ះពាល់មិនចង់បានដល់សុខភាពរបស់ពួកគេទាក់ទងនឹងការជក់បារី ការផឹកគ្រឿងស្រវឹង និងទម្លាប់ទទួលទានអាហារ។ រហូតមកដល់ពេលថ្មីៗនេះ ជំងឺឆ្លងនៅប្រទេសកម្ពុជាដូចជា គ្រុនចាញ់ គ្រុនឈាម និងរាកគឺជាមូលហេតុចម្បងនៃការស្លាប់ ខណៈដែលជំងឺទាក់ទងនឹងរបៀបរស់នៅដូចជា ជំងឺដាច់សរសៃឈាមខួរក្បាល និងជំងឺក្រិនថ្លើមបានបណ្តាលឱ្យមានអ្នកស្លាប់យ៉ាងច្រើន។ ដូច្នេះហើយ នៅក្នុងជំពូកទី ៦ យើងនឹងពន្យល់ពីការផ្លាស់ប្តូរនៃមូលហេតុនៃការស្លាប់នៅប្រទេសកម្ពុជា និងលក្ខណៈនៃជំងឺសំខាន់ៗទាក់ទងនឹងរបៀបរស់នៅ។ ជាពិសេសទំនាក់ទំនងរវាងសន្ទស្សន៍ម៉ាសរាងកាយ (BMI) និងអត្រាមរណៈបង្ហាញពីសារៈសំខាន់នៃការគ្រប់គ្រងទម្ងន់រាងកាយឱ្យបានត្រឹមត្រូវ។ ភាពធាត់ក៏កំពុងកើនឡើងដែរ ប៉ុន្តែការយល់ដឹងនិងដំណោះស្រាយសម្រាប់បញ្ហាអាហារ និងអាហារូបត្ថម្ភបញ្ហានៃកង្វះអាហារូបត្ថម្ភ និងភាពស្លេកស្លាំងនៅតែជាបញ្ហាសុខភាពសិក្សាដ៏សំខាន់ដែលត្រូវស្វែងយល់ផងដែរ។ សន្ទស្សន៍ម៉ាសរាងកាយ(BMI) ត្រូវបានគណនា វាយតម្លៃដោយការរៀនពីរបៀបវាស់កម្ពស់ និងទម្ងន់នៅក្នុងជំពូកទី ៩ សារៈសំខាន់និងវិធីសាស្ត្រនៃការពិនិត្យរាងកាយ។

## ២. សេចក្តីផ្តើម

រយៈពេល៖ ៥នាទី

(១) ប្រើប្រាស់ស្ថិតិប្រទេសកម្ពុជា។

- Institute for Health Metrics and Evaluation Cambodia: What causes the most deaths?

  តំណភ្ជាប់ ១០.១៖ http://www.healthdata.org/cambodia

- Institute for Health Metrics and Evaluation Cambodia: What risk factors drive the most death and disability combined?

  តំណភ្ជាប់ ១០.២៖ http://www.healthdata.org/cambodia

- Kobashi Y. et al.: Health disparity toward noncommunicable diseases among residents in rural Cambodia: a descriptive study,

  **តំណភ្ជាប់ ១០.៣៖** https://www.jstage.jst.go.jp/article/jrm/15/4/15_2020-028/_pdf/-char/ja
- Kulikov A. et al.: Prevention and control of noncommunicable diseases in Cambodia The case for investment,

  **តំណភ្ជាប់ ១០.៤៖** https://www.undp.org/sites/g/files/zskgke326/files/migration/kh/UNDP_KH_Cambodia_NCD_Investment_Case.pdf

(២) ប្រើប្រាស់ករណី និងយកអ្វីដែលមាននៅក្នុងសារព័ត៌មាន។

- Deaths due to “lifestyle” diseases rise in Kingdom, The Phnom Penh Post 18 Sep 2022.

  **តំណភ្ជាប់ ១០.៥៖** https://www.phnompenhpost.com/national/deaths-due-lifestyle-diseases-rise-kingdom
- WHO: Addressing noncommunicable diseases in Cambodia can save lives and sustain economic growth, 17 Oct 2019

  **តំណភ្ជាប់ ១០.៦៖** https://www.who.int/news/item/17-10-2019-addressing-noncommunicable-diseases-in-cambodia-can-save-lives-and-sustain-economic-growth

(៣) សុំឱ្យគរុនិស្សិតចែករំលែកបទពិសោធន៍របស់ពួកគេ និងសង្ខេបការពិភាក្សាជាក្រុមនៅក្នុងបទបង្ហាញមួយ។ សំណួរចាប់ផ្ដើម«តើមានមនុស្សនៅជុំវិញអ្នកមានជំងឺបេះដូងជំងឺថ្លើមមហារីកជំងឺដាច់សរសៃឈាមខួរក្បាល ឬជំងឺមិនឆ្លងផ្សេងទៀតទេ? តើអ្នកគិតថាអ្វីជាមូលហេតុនៃជំងឺរបស់មនុស្សទាំងនោះ?»។

(៤) ណែនាំអំពីបទពិសោធន៍របស់គ្រូឧទ្ទេស។

## ៣. បញ្ជាក់បំភ្លឺ កំណត់គោលបំណងសិក្សា និងបង្រៀន

### រយៈពេល៖ ៦០នាទី

ការបង្រៀនក្នុងជំពូកទី ៦ គ្របដណ្ដប់លើប្រធានបទដូចខាងក្រោម៖

- ❖ ១. ជំងឺបណ្ដាលមកពីរបៀបរស់នៅទូទៅក្នុងចំណោមប្រជាជនកម្ពុជា
  - ➢ ការប្រែប្រួលនៃមូលហេតុនៃការស្លាប់កន្លងមកនៅប្រទេសកម្ពុជា **(រូបទី ៦.១, ៦.២)**
  - ➢ ការប្រែប្រួលនៃកត្តាហានិភ័យនៃការស្លាប់ និងពិការភាពនាពេលកន្លងមកនៅប្រទេសកម្ពុជា **(រូបទី ៦.៣)**
- ❖ ២. ជំងឺបណ្ដាលមកពីរបៀបរស់នៅ និងលក្ខខណ្ឌផ្សេងៗទៀតទាក់ទងនឹងទម្លាប់របៀបរស់នៅ
  - ➢ ២.១. ជំងឺបណ្ដាលមកពីរបៀបរស់នៅ

- ប្រភេទទូទៅនៃជំងឺបណ្តាលមកពីរបៀបរស់នៅ និងរោគសញ្ញានៃជំងឺ **(តារាងទី ៦.១)** ជំងឺដាច់សរសៃឈាមខួរក្បាល ជំងឺថ្លើម ជំងឺបេះដូង (ischemic) ការរលាកដាលនៃសាច់កាច (មហារីក) ជំងឺទឹកនោមផ្អែម។
  - ២.២. បញ្ហាសុខភាពផ្សេងទៀតទាក់ទងនឹងទម្លាប់របៀបរស់នៅ
    - ២.២.១. ទំនាក់ទំនងរវាង BMI-ការស្លាប់
    - ២.២.២ ភាពធាត់ខ្លាំង និងកង្វះទម្ងន់
    - ២.២.៣ ជំងឺកង្វះឈាមក្រហម

## ៤. ឧទាហរណ៍នៃកិច្ចការពិភាក្សាជាក្រុម និងសំណួរឆ្លើយឆ្លង

រយៈពេល៖ ៣៥នាទី

- គរុនិស្សិតម្នាក់ៗបំពេញក្នុង «តារាងត្រួតពិនិត្យទម្លាប់របៀបរស់នៅ» ជាមុន ហើយបង្ហាញចំណុចល្អ និងបញ្ហានៃទម្លាប់រស់នៅរបស់ពួកគេ។ ខណៈពេលកំពុងស្តាប់បទបង្ហាញរបស់អ្នកដទៃ គរុនិស្សិតនឹងចង្អុលបង្ហាញពីកត្តាហានិភ័យពីទស្សនៈនៃការបង្ការជំងឺបណ្តាលមកពីរបៀបរស់នៅ និងផ្តល់ដំបូន្មានលើការកែលម្អរបៀបរស់នៅ។ (សូមមើល «**លំហាត់សម្រាប់ការគិត និងការស្រាវជ្រាវបន្ថែម [៥-៦]**»)។
- ដោយផ្អែកលើ «តារាងត្រួតពិនិត្យទម្លាប់របៀបរស់នៅ» ដែលបានបំពេញជាមុន ធ្វើការងារជាក្រុមមានពីរនាក់សរសេរចំណុចល្អរបស់គ្នាទៅវិញទៅមកដូចជា របបអាហារ ការធ្វើលំហាត់ប្រាណ ការសម្រាក ការគេងជាដើម និងផ្តល់ដំបូន្មានលើចំណុចដែលត្រូវកែលម្អ។

កិច្ចការដែលគរុនិស្សិតគួរអាន និងស្វែងយល់ពីសៀវភៅសិក្សាគោល ៖

- ៤. ការអនុវត្តល្អប្រសើរក្នុងចង្វាក់នៃជីវិតប្រចាំថ្ងៃល្អប្រសើរជាងមុន
- ៥. របបអាហារមិនសមស្របនិងបញ្ហាសុខភាព

**អត្ថបទដកស្រង់ ៦.៦៖** ទម្លាប់នៃរបបអាហារដែលបង្ការជំងឺបណ្តាលមកពីរបៀបរស់នៅក៏នឹងជួយបង្ការជំងឺឆ្លងផងដែរ (តារាងទី ៦.៥)។

## ៥. ឯកសារ


- WHO: Nutrition advice for adults during the COVID-19 outbreak
- **តំណភ្ជាប់ ១០.៧៖** https://www.emro.who.int/nutrition/covid-19/nutrition-advice-for-adults-during-the-covid-19-outbreak.html#:~:text=Daily%2C%20eat%3A%202%20cups%20of,in%20sugar%2C%20fat%20or%20salt
- FAO and WHO: COVID-19 and food safety: guidance for food businesses, interim guidance, 7 April 2020
  **តំណភ្ជាប់ ១០.៨៖** https://www.who.int/publications/i/item/covid-19-and-food-safety-guidance-for-food-businesses

**វីដេអូ៖**

- WHO: Health Promotion

  តំណភ្ជាប់ ១០.៩៖ https://www.who.int/westernpacific/about/how-we-work/programmes/health-promotion

- WHO: Oral diseases are preventable with good oral hygiene

  តំណភ្ជាប់ ១០.១០៖ http://www.emro.who.int/nutrition/nutrition-infocus/nutrition-advice-foradults-during-the-covid-19-outbreak.htmlhttps://www.who.int/westernpacific/news-room/multimedia/overview/item/oral-diseases-are-preventable-with-good-oral-hygiene

- WHO: Childhood obesity: Avoca

  តំណភ្ជាប់ ១០.១១៖ http://www.emro.who.int/nutrition/nutrition-infocus/nutrition-advice-foradults-during-the-covid-19-outbreak.htmlhttps://www.who.int/westernpacific/health-topics/obesity#

- Marco A. Sotomayor: How does your body know what time it is?

  តំណភ្ជាប់ ១០.១២៖ http://www.emro.who.int/nutrition/nutrition-infocus/nutrition-advice-foradults-during-the-covid-19-outbreak.htmlhttps://ed.ted.com/lessons/how-does-your-body-know-what-time-it-is-marco-a-sotomayor

- Florida PASS Program: Is it Communicable or Non-communicable?

  តំណភ្ជាប់ ១០.១៣៖ http://www.emro.who.int/nutrition/nutrition-infocus/nutrition-advice-foradults-during-the-covid-19-outbreak.htmlhttps://www.youtube.com/watch?v=vpEAos0blyw&list=PLLb6XezxyhLm2ZSudd-uNWQrmK6sLEeTu&index=8

## ៦. ការវាយតម្លៃ

- **ចំណេះដឹងនិងជំនាញ៖** ឧទាហរណ៍ ចំណេះដឹងអំពីរបៀបគណនា BMI (ការធ្វើតេស្តចំណេះដឹង)។ ចំណេះដឹងអំពីរោគសញ្ញាសំខាន់ៗនៃភាពស្លេកស្លាំង(ការធ្វើតេស្តចំណេះដឹង)។ តើមូលហេតុនៃការស្លាប់របស់ប្រជាជនកម្ពុជាបានផ្លាស់ប្តូរយ៉ាងដូចម្តេចក្នុងរយៈពេល ៣០ឆ្នាំកន្លងមកនេះ? សូមពន្យល់ពីការផ្លាស់ប្តូរភាគរយនៃការស្លាប់ដោយសារជំងឺឆ្លង និងជំងឺទាក់ទងនឹងរបៀបរស់នៅ។ (ការធ្វើតេស្តចំណេះដឹង)។
- **អាកប្បកិរិយានិងការចូលរួមក្នុងការរៀនសូត្រ៖** ឧទាហរណ៍ សង្កេតមើលអាកប្បកិរិយារបស់គរុនិស្សិតនិងការចូលរួមក្នុងការងារជាក្រុម។ ចាត់ឱ្យធ្វើរបាយការណ៍អំពីអ្វីដែលអ្នកបានរៀនពីការធ្វើការងារជាក្រុម អ្វីដែលអ្នកបានរៀនពីការស្តាប់បទបង្ហាញរបស់ក្រុមផ្សេងៗ និងបញ្ហាប្រឈមដែលអ្នកមានតាមរយៈការងារជាក្រុម។ វាយតម្លៃសំណួរ និងចម្លើយឆ្លើយឆ្លង។

- **សមត្ថភាពក្នុងការគិត វិនិច្ឆ័យ និងបញ្ចេញមតិ៖** ឧទាហរណ៍ ចាត់ឱ្យធ្វើរបាយការណ៍អំពីអ្វីដែលអ្នកបានរៀន ពីការធ្វើការងារជាក្រុម អ្វីដែលអ្នកបានរៀនពីការស្តាប់បទបង្ហាញរបស់ក្រុមផ្សេងៗ និងបញ្ហាប្រឈមដែលអ្នកមានតាមរយៈការងារជាក្រុម។ វាយតម្លៃសមត្ថភាពក្នុងការពន្យល់កិច្ចការមួយយ៉ាងត្រឹមត្រូវ និងបញ្ចុះបញ្ចូលក្នុងបទបង្ហាញការងារជាក្រុម។ វាយតម្លៃសំណួរ និងចម្លើយឆ្លើយឆ្លង។

តើជំងឺអ្វីដែលទាក់ទងនឹងរបៀបរស់នៅ ហើយអ្នកទំនងជាអាចកើតមានវានៅពេលអនាគត? តើអាកប្បកិរិយាសុខភាពបែបណាដែលអ្នកគិតថា អ្នកគួរតែអនុវត្តដើម្បីកាត់បន្ថយឱកាសនៃការទទួលរងពីជំងឺបណ្តាលមកពីរបៀបរស់នៅទាំងនេះ? (វាយការណ៍របាយការណ៍ចាត់ឱ្យធ្វើ)។

## ៧. តំណភ្ជាប់

១០.១ ១០.២ ១០.៣

១០.៤ ១០.៥ ១០.៦

១០.៧ ១០.៨ ១០.៩

Oral

១០.១០

obesity

១០.១១

TedEd

១០.១២

Communicable

១០.១៣

# មេរៀនទី ១២ ១៣

## ជំពូកទី ៧៖ ជំងឺឆ្លង វិធីបង្ការ និងការពារ

### ១. ទិដ្ឋភាពទូទៅ

ជំពូកទី ៧ គ្របដណ្ដប់លើការបង្ការជំងឺឆ្លង។ ដើម្បីស្វែងយល់ពីជំងឺឆ្លង និងវិធីបង្ការវា ដំបូងយើងត្រូវសិក្សាពីយន្តការមូលដ្ឋានពីការឆ្លងមេរោគរហូតដល់ការចាប់ផ្ដើមនៃជំងឺ ហើយសិក្សាអំពីយន្តការរបាំងការពាររាងកាយរបស់មនុស្សប្រឆាំងនឹងមេរោគ។ គរុនិស្សិតនឹងរៀនពីអ្វីដែលពួកគេអាចធ្វើបានជាបុគ្គល សាលារៀន និងសហគមន៍ដើម្បីការពារជំងឺឆ្លង។ ដើម្បីទប់ស្កាត់ការឆ្លងនីមួយៗ ជំងឺឆ្លងសំខាន់ៗនៅប្រទេសកម្ពុជាត្រូវបានពិពណ៌នាដើម្បីឱ្យគរុនិស្សិតមានចំណេះដឹងអំពីមូលហេតុ រោគសញ្ញា និងការឆ្លើយតបទៅនឹងជំងឺទាំងនេះ។

### ២. សេចក្ដីផ្ដើម

រយៈពេល៖ ៥នាទី

(១) ប្រើប្រាស់ស្ថិតិប្រទេសកម្ពុជា។

- Srean Chhim, et al.: Malaria in Cambodia: A Retrospective Analysis of a Changing Epidemiology 2006-2019. Int J Environ Res Public Health. 2021 Feb; 18(4): 1960.

  តំណភ្ជាប់ ១២-១៣.១៖ https://www.ncbi.nlm.nih.gov/pmc/articles/PMC7922556/

- WHO: Update on the Dengue situation in the Western Pacific Region. 22 Sep 2022

  តំណភ្ជាប់ ១២-១៣.២៖ https://www.who.int/docs/default-source/wpro---documents/emergency/surveillance/dengue/dengue-20221103.pdf?sfvrsn=5160e027_109#:~:text=As%20of%20epidemiological%20week%2030,945%20cases%3B%202%20death

«កម្ពុជាគឺជាប្រទេសមួយក្នុងចំណោមប្រទេសទាំង 30 ដែលមានបន្ទុកជំងឺរបេងខ្ពស់ជាងគេលើពិភពលោកជាមួយនឹងការប៉ាន់ស្មាននៃជំងឺរបេងសកម្មចំនួន 302 (95% CI: 169-473) ក្នុង 100.000នាក់ក្នុងឆ្នាំ 2018»។ (អង្គការសុខភាពពិភពលោក (WHO)។ របាយការណ៍ជំងឺរបេងសកលឆ្នាំ 2019។ ទីក្រុងហ្សឺណែវ៖ អង្គការសុខភាពពិភពលោកឆ្នាំ 2019។)

- The World Bank: Prevalence of HIV, total (% of population ages 15-49) -Cambodia.

  តំណភ្ជាប់ ១២-១៣.៣៖ https://data.worldbank.org/indicator/SH.DYN.AIDS.ZS?locations=KH

(២) ប្រើប្រាស់ករណី និងយកអ្វីដែលមាននៅក្នុងសារព័ត៌មាន។

- Cambodia winning the fight against malaria, Phnom Penh Post 3 Nov 2020.

  តំណភ្ជាប់ ១២-១៣.៤៖ https://www.phnompenhpost.com/national/cambodia-winning-fight-against-malaria

- Dengue fever cases up threefold. The Phnom Penh Post 11 Jul 2022

  តំណភ្ជាប់ ១២-១៣.៥៖ https://www.phnompenhpost.com/national/dengue-fever-cases-threefold

(៣) សុំឱ្យគរុនិស្សិតចែករំលែកបទពិសោធន៍របស់ពួកគេ និងសង្ខេបការពិភាក្សាជាក្រុមនៅក្នុងបទបង្ហាញមួយ។ គិតអំពីជំងឺឆ្លងប្រភេទណាដែលអ្នកគិតថាគួរតែត្រូវបានអប់រំនៅក្នុងសាលារៀន? ហើយហេតុអ្វីបានជាអ្នកគិតដូច្នេះ? តើអ្នកគួរប្រើវិធីសាស្រ្តបែបណាខ្លះដើម្បីអប់រំកុមារនៅសាលារៀន?

(៤) ណែនាំអំពីបទពិសោធន៍របស់គ្រូឧទ្ទេស។ គ្រូឧទ្ទេសនឹងនិយាយអំពីបទពិសោធន៍របស់គាត់ជាមួយជំងឺឆ្លង។

## ៣. បញ្ជាក់បំភ្លឺ កំណត់គោលបំណងសិក្សា និងបង្រៀន

**រយៈពេល៖ ២៥នាទី**

ការបង្រៀនក្នុងជំពូកទី ៦ គ្របដណ្តប់លើប្រធានបទដូចខាងក្រោម៖

- ១. និយមន័យនៃការបង្ករោគ និងកត្តាចម្បងទាំងបីនៃការបង្ករោគ
  - ១.១. និយមន័យនៃជំងឺឆ្លង
  - ១.២. មេរោគ
  - ១.៣. ផ្លូវបង្ករោគ
  - ១.៤. ភាពងាយឆ្លងជំងឺរបស់ផ្ទួល (**រូបទី ៧.១៖** កត្តាចម្បងបីក្នុងការធ្វើឱ្យមានការបង្ករោគ៖ មេរោគ ផ្លូវបង្ករោគ និងភាពងាយឆ្លងជំងឺរបស់ផ្ទួល **តារាងទី ៧.១៖** ប្រភេទភ្នាក់ងារបង្កមេរោគសំខាន់ៗ និងលក្ខណៈរបស់វា)
- ២. យន្តការរបាំងការពារបែបជីវសាស្រ្ត (**រូបទី ៧.២៖** យន្តការរបាំងការពារទាំងបីដើម្បីការពាររាងកាយ )
  - ២.១. របាំងការពារបែបរូបសាស្រ្ត
  - ២.២. របាំងការពារបែបគីមីសាស្រ្ត
  - ២.៣. ប្រព័ន្ធភាពស៊ាំ

ព័ត៌មានលម្អិតនៃប្រធានបទទាំងបីខាងលើ នឹងត្រូវបានពន្យល់យ៉ាងខ្លីដោយអនុញ្ញាតឱ្យគរុនិស្សិតពិនិត្យមើលជំពូកទី ២ ជាមុនក្នុងថ្នាក់។

❖ ៣. ការបង្ការជំងឺឆ្លង

➢ ៤. (រូបទី ៧.៤៖ គន្លឹះទៅកាន់វិធានការបង្ការពីកត្តាចម្បងទាំងបី)

៣.១. តើបុគ្គលម្នាក់ៗអាចធ្វើអ្វីបានខ្លះ?

៣.២. តើសាលារៀនអាចធ្វើអ្វីបានខ្លះ?

៣.៣. តើសង្គមអាចធ្វើអ្វីបានខ្លះ?

## ៤. ឧទាហរណ៍នៃកិច្ចការពិភាក្សាជាក្រុម និងសំណួរឆ្លើយឆ្លង

### រយៈពេល៖ ៣៥នាទី

គរុនិស្សិតនឹងពិភាក្សាអំពីអ្វីដែលបុគ្គលអាចធ្វើបាន អ្វីដែលសាលារៀនរំពឹងថានឹងត្រូវធ្វើ និងអ្វីដែលសង្គមត្រូវធ្វើដើម្បីការពារជំងឺឆ្លង។ ក្រុមគរុនិស្សិតនឹងត្រូវបែងចែកទៅជាទំនួលខុសត្រូវផ្ទាល់ខ្លួន សាលារៀន និងសង្គម ហើយនឹងបង្ហាញការរកឃើញរបស់ពួកគេជាសមូហភាពដោយយោងទៅលើស្ថិតិប្រទេសកម្ពុជា អត្ថបទ និងអត្ថបទដកស្រង់ស្តីពីជំងឺឆ្លងដែលពួកគេបានសិក្សា។

កិច្ចការដែលគរុនិស្សិតគួរអាន និងស្វែងយល់ពីសៀវភៅសិក្សាគោល៖

❖ ៤. ជំងឺឆ្លងទូទៅនៅប្រទេសកម្ពុជា

ការសិក្សាបឋម ទទួលបានស្ថិតិ និងព័ត៌មានផ្សេងទៀតអំពីស្ថានភាពបច្ចុប្បន្ននៃជំងឺឆ្លងនៅប្រទេសកម្ពុជា។

## ៥. ឯកសារ


- Health Sector Information Collection and Verification Study -Kingdom of Cambodia Health Sector Analysis Report- JICA, Oct 2012 (Japanese)

  តំណភ្ជាប់ ១២-១៣.៦៖ https://openjicareport.jica.go.jp/pdf/12085213.pdf
- U.S. PRESIDENT'S MALARIA INITIATIVE CAMBODIA: Malaria Operational Plan FY 2020,

  តំណភ្ជាប់ ១២-១៣.៧៖ https://d1u4sg1s9ptc4z.cloudfront.net/uploads/2021/03/fy-2020-cambodia-malaria-operational-plan.pdf (Figure 3 below)

**Figure 3. Number of malaria cases and deaths by year, 1997-2019 (January through August)**




Source: National Center for Parasitology, Entomology and Malaria Control (CNM)

- WHO: Dengue Situation Update 655, 22 Sep 2022

តំណភ្ជាប់ ១២-១៣.៨៖ https://www.who.int/docs/default-source/wpro---documents/emergency/surveillance/dengue/dengue-20220922.pdf?sfvrsn=5160e027_108#:~:text=As%20of%20epidemiological%20week%2030,945%20cases%3B%202%20death

**Cambodia**

As of epidemiological week 36 of 2022, a total of 7,229 dengue cases and 13 deaths (case fatality rate (CFR) 0.2%) were reported in Cambodia. The number of cases reported weekly is lower than mean cases during 2015-2020 (Figure 1). The number of cases is expected to increase as dengue usually occurs duing the rainy season between June and October.




Figure 1: Dengue cases reported weekly in 2022 vs Mean and Mean+2SD during 2015-2020, *excluding 2019 in Cambodia

*Source: National Dengue Surveillance System( NDCP/CNM/MOH)*

**វីដេអូ៖**

- National Institute for Communicable Diseases (South Africa): COMMUNICABLE DISEASES | What? Why? How?

  **តំណភ្ជាប់ ១២-១៣.៩៖** https://www.youtube.com/watch?v=LBkXQ_mBO3Q

- Macmillan Education India: Transmission of Communicable Diseases.

  **តំណភ្ជាប់ ១២-១៣.១០៖** https://www.youtube.com/watch?v=R9_mdJHbcFk

- Florida PASS Program: Is it Communicable or Non-communicable?

  **តំណភ្ជាប់ ១២-១៣.១១៖** https://www.youtube.com/watch?v=vpEAos0blyw&list=PLLb6XezxyhLm2ZSudd-uNWQrmK6sLEeTu&index=8

- Florida PASS Program: Preventing Communicable Diseases.

  **តំណភ្ជាប់ ១២-១៣.១២៖** https://www.youtube.com/watch?v=EgJcflR_Dic

## ៦. ការវាយតម្លៃ

- **ចំណេះដឹងនិងជំនាញ៖** ឧទាហរណ៍ ពន្យល់ពីវដ្តនៃការចម្លងមេរោគគ្រុនឈាម(ការធ្វើតេស្តចំណេះដឹង)។ ចំណេះដឹងអំពីឈ្មោះមេរោគសំខាន់ៗ (ការធ្វើតេស្តចំណេះដឹង)។ ចំណេះដឹងអំពីកត្តាបីសម្រាប់ការបង្កើតការឆ្លងមេរោគ (ការធ្វើតេស្តចំណេះដឹង)។ ពន្យល់អំពីយន្តការរបាំងការពារបែបជីវសាស្ត្របីប្រភេទ (ការធ្វើតេស្តចំណេះដឹង)។
- **ឥរិយាបថសិក្សានិងការចូលរួម៖** ឧទាហរណ៍ សង្កេតមើលអាកប្បកិរិយារបស់គរុនិស្សិតនិងការចូលរួមក្នុងការងារជាក្រុម។ ចាត់ឱ្យធ្វើរបាយការណ៍អំពីអ្វីដែលអ្នកបានរៀនពីការធ្វើការងារជាក្រុម អ្វីដែលអ្នកបានរៀនពីការស្តាប់បទបង្ហាញរបស់ក្រុមផ្សេងៗ និងបញ្ហាប្រឈមដែលអ្នកមានអារតាមរយៈការងារជាក្រុម។ វាយតម្លៃសំណួរនិងចម្លើយឆ្លើយឆ្លង។
- **សមត្ថភាពក្នុងការគិត វិនិច្ឆ័យ និងបញ្ចេញមតិ៖** ឧទាហរណ៍ ផ្តល់របាយការណ៍អំពីអ្វីដែលអ្នកបានរៀនពីការធ្វើការងារជាក្រុម អ្វីដែលអ្នកបានរៀនពីការស្តាប់បទបង្ហាញរបស់ក្រុមផ្សេងៗ និងបញ្ហាប្រឈមដែលអ្នកមានតាមរយៈការងារជាក្រុម។ វាយតម្លៃសមត្ថភាពក្នុងការពន្យល់កិច្ចការមួយយ៉ាងត្រឹមត្រូវ និងបញ្ចុះបញ្ចូលក្នុងបទបង្ហាញការងារជាក្រុម។ វាយតម្លៃសំណួរនិងចម្លើយឆ្លើយឆ្លង។

គរុនិស្សិតនឹងសរសេរអត្ថបទអំពីអ្វីដែលបុគ្គលអាចធ្វើបាន អ្វីដែលសាលារៀនរំពឹងថានឹងធ្វើ និងអ្វីដែលសង្គមគួរធ្វើដើម្បីការពារជំងឺឆ្លង (របាយការណ៍របាយការណ៍ចាត់ឱ្យធ្វើ)។ តើអ្នកមានជំងឺ អេដស៍ ឬជំងឺឆ្លងដូចជាកូវីដ-១៩ ទទួលរងការរើសអើងដែរឬទេនៅប្រទេសកម្ពុជា? បើគ្មាន ហេតុអ្វី? តើធ្វើដូចម្តេចទើបអាចការពារពួកគាត់ពីការរើសអើងបាន? ចូរស្រាវជ្រាវនិងសរសេររបាយការណ៍ (របាយការណ៍របាយការណ៍ចាត់ឱ្យធ្វើ)។

## ៧. តំណភ្ជាប់

| | | |
|---|---|---|
| Malaria<br>១២-១៣.១ | Dengue<br>១២-១៣.២ | HIV<br>១២-១៣.៣ |
| 3, Nov.<br>១២-១៣.៤ | 11, July<br>១២-១៣.៥ | JICA<br>១២-១៣.៦ |
| PMI<br>១២-១៣.៧ | Dengue<br>១២-១៣.៨ | S.Africa<br>១២-១៣.៩ |
| India<br>១២-១៣.១០ | Is it<br>១២-១៣.១១ | Preventing<br>១២-១៣.១២ |

# មេរៀនទី ១៤

# ជំពូកទី៨៖ សុខភាពភ្នែក និងសុខភាពមាត់ធ្មេញ

## ១. ទិដ្ឋភាពទូទៅ

ជំពូកទី ៨ ផ្តោតលើសុខភាពភ្នែកនិងសុខភាពមាត់ធ្មេញ ដែលមានសារៈសំខាន់ក្នុងវ័យកុមារភាព។ នៅក្នុងសុខភាពភ្នែក បន្ទាប់ពីស្វែងយល់ពីរចនាសម្ព័ន្ធមូលដ្ឋាននៃភ្នែកនិងរបៀបដែលយើងមើលឃើញ យើងរៀនអំពីជំងឺភ្នែកនិងជំងឺផ្សេងៗ។ ទោះបីជាជំពូកនេះមានការពិភាក្សាអំពីជំងឺភ្នែកពេញវ័យដែលអាចប៉ះពាល់ដល់គរុនិស្សិតមហាវិទ្យាល័យ និងក្រុមគ្រួសាររបស់ពួកគេក៏ដោយ ក៏បញ្ហាសុខភាពភ្នែកសំខាន់ៗនៅក្នុងសុខភាពសិក្សាគឺជំងឺភ្នែកឡើងបាយ និងកំហុសកំណុំ។ ការប្រើប្រាស់វ៉ែនតានិងកញ្ចក់ភ្នែកសិប្បនិម្មិតដើម្បីកែតម្រូវចំពោះកំហុសកំណុំ ឥរិយាបថ ពន្លឺ និងរបៀបសម្រាកភ្នែកដើម្បីការពារភ្នែកពួកគេគួរតែត្រូវបានយល់ឱ្យកាន់ច្បាស់។ ការធ្វើតេស្តភាពច្បាស់ដែលមើលឃើញដើម្បីកំណត់កំហុសកំណុំត្រូវបានរៀនអនុវត្តនៅក្នុងជំពូកទី៩ សារៈសំខាន់និងវិធីសាស្ត្រនៃការពិនិត្យរាងកាយ។

## ២. សេចក្តីផ្តើម

**រយៈពេល៖ ៥នាទី**

(១) ប្រើប្រាស់ស្ថិតិនៅប្រទេសកម្ពុជា។

ជាមធ្យម ទូទាំងពិភពលោកជាង ៣០% នៃកុមារក្នុងចុងវ័យជំទង់ត្រូវបានគេប៉ាន់ប្រមាណថាមានកំហុសកំណុំ (Holden BA, Fricke TR, Wilson DA, et al. Global prevalence of myopia and high myopia and temporal trends from 2000 through 2050. Ophthalmology 2016;123:1036-42)។

យោងតាមការសិក្សាមួយក្នុងឆ្នាំ ២០១០ អត្រាប្រេវ៉ាឡង់នៃកំហុសកំណុំចំពោះកុមាររៀននៅទីក្រុង និងជនបទមកពីរាជធានីភ្នំពេញ និងខេត្តកណ្តាល ត្រូវបានគេប៉ាន់ប្រមាណថាមាន ១៣,៧% និង ២,៥% រៀងគ្នា (Gao Z, Meng N, Muecke J, et al. Refractive error in school children in an urban and rural setting in Cambodia. Ophthalmic Epidemiol 2012; 19:16-22)។

- Asao Y et al.: Three-year survey of oral hygiene conditions of Cambodian public primary school children, Journal of Oral Science

  **តំណភ្ជាប់ ១៤.១៖** https://www.jstage.jst.go.jp/article/josnusd/advpub/0/advpub_21-0464/_pdf/-char/ja

(២) ប្រើប្រាស់ករណី និងយកអ្វីដែលមាននៅក្នុងសារព័ត៌មាន។

Burnett A, Paudel P, Massie J, et al. Parents' willingness to pay for children's spectacles in Cambodia. BMJ Open Ophthalmology 2021;6:e000654. doi:10.1136/bmjophth-2020-000654.

យោងតាមការស្រាវជ្រាវនេះ ឧបសគ្គទូទៅបំផុតនៃការពាក់វ៉ែនតាគឺការភ័យខ្លាចថា វ៉ែនតាធ្វើឱ្យភ្នែករបស់កុមារចុះខ្សោយ។

(៣) សុំឱ្យគរុនិស្សិតចែករំលែកបទពិសោធន៍របស់ពួកគេ និងសង្ខេបការពិភាក្សាជាក្រុមនៅក្នុងបទបង្ហាញមួយ។

- សួរគរុនិស្សិតអំពីបញ្ហាសុខភាពភ្នែករបស់ពួកគេ និងបញ្ហាសុខភាពមាត់ធ្មេញ។
- លើកទឹកចិត្តពួកគេឱ្យគិតអំពីទំនាក់ទំនងរវាងបញ្ហាទាំងនោះ និងទម្លាប់នៃរបៀបរស់នៅដែលមានស្រាប់របស់ពួកគេ ឧទាហរណ៍ ភ្នែកខ្សោយដោយសារតែការលេងហ្គេមអនឡាញ និងហ្គេមកុំព្យូទ័រច្រើនពេកទាំងនៅលើស្មាតហ្វូន និងលើឧបករណ៍ផ្សេងទៀត។
- សួរថា ហេតុអ្វីបានជាសុខភាពភ្នែកនិងសុខភាពមាត់ធ្មេញត្រូវបានលើកឡើងនៅក្នុងថ្នាក់រៀន។ (សុខភាពភ្នែក និងសុខភាពមាត់ធ្មេញគឺជាបញ្ហាសុខភាពរបស់កុមារដែលគេស្គាល់យ៉ាងទូលំទូលាយ ហើយជាសម្ភារៈអប់រំរបស់កុមារដែលទាក់ទាញភ្នែកនិងងាយយល់។ វាងាយស្រួលសម្រាប់កុមារក្នុងការយល់ថាសុខភាពភ្នែក និងសុខភាពមាត់ធ្មេញមានទំនាក់ទំនងទៅនឹងរបៀបរស់នៅ។)

(៤) ណែនាំអំពីបទពិសោធន៍របស់គ្រូឧទ្ទេស។

## ៣. បញ្ជាក់បំភ្លឺ កំណត់គោលបំណងសិក្សា និងបង្រៀន

**រយៈពេល៖ ៣០នាទី**

បទឧទ្ទេសស្តីពីសុខភាពភ្នែកនឹងគ្របដណ្តប់លើប្រធានបទខាងក្រោម៖

- ១. សុខភាពភ្នែក
  - ១.១. សារៈសំខាន់នៃសុខភាពភ្នែក
  - ១.៣. ជំងឺភ្នែកដែលអាចបណ្តាលឱ្យកម្សោយគំហើញ (រួមទាំងការការពារ)
    - ១.៣.៤. ជំងឺត្រាកូម
    - ១.៣.៦. កំហុសកំណុំរូបភាព
  - ១.៥. ដើម្បីការពារភ្នែករបស់អ្នក

បទឧទ្ទេសស្តីពីសុខភាពមាត់ធ្មេញនឹងគ្របដណ្តប់លើប្រធានបទដូចខាងក្រោម៖

- ២. សុខភាពមាត់ធ្មេញ
  - ២.១. តួនាទី និងការអភិវឌ្ឍរបស់ធ្មេញ
  - ២.២. ជំងឺពុកធ្មេញ / ជង្គុះស៊ីធ្មេញ
    - ២.២.១. យន្តការនៃការអភិវឌ្ឍ និងការវិវឌ្ឍនៃជំងឺពុកធ្មេញ

➢ ២.៤. ការបង្ការជំងឺពុកធ្មេញ និងជំងឺរាក់ស៊ីធ្មេញ

២.៤.១. ការដុសធ្មេញ

## ៤. ឧទាហរណ៍នៃកិច្ចការពិភាក្សាជាក្រុម និងសំណួរឆ្លើយឆ្លង

**រយៈពេល៖ ១៥នាទី**

- ប្រទេសកម្ពុជាត្រូវបានគេនិយាយថាមានអត្រាកើតជំងឺមើលឆ្ងាយមិនច្បាស់ (មីញ៉ូប) ទាបក្នុងចំណោមកុមារចូលរៀនបើធៀបនឹងប្រទេសអាស៊ីផ្សេងទៀត។ ចូរយើងពិចារណាអំពីហេតុផលសម្រាប់រឿងនេះ។ ដូចគ្នានេះដែរ សូមឱ្យពិភាក្សា និងទស្សន៍ទាយថា តើជំងឺភ្នែកមីញ៉ូប (myopia) ក្នុងចំណោមកុមារនឹងកើនឡើងឬទេនាពេលអនាគត។
- ចូរយើងគិតពីរបៀបបង្រៀនដុសធ្មេញឱ្យមានប្រសិទ្ធភាពដោយគិតដល់អាយុជុះធ្មេញថ្មីមកជំនួស។
- ចូរយើងគិតពីអ្វីដែលសាលារៀនអាចធ្វើដើម្បីលើកកម្ពស់សុខភាពភ្នែក និងសុខភាពមាត់ធ្មេញរបស់កុមារ។
- សកម្មភាព៖ ការរកឃើញបន្ទះធ្មេញជាមួយថ្នាំងារបង្ហាញ (សូមមើលការពិសោធន៍)
- សកម្មភាព៖ លំហាត់ភ្នែក

  **តំណភ្ជាប់ ១៤.២៖** https://www.youtube.com/watch?v=v8TJXRoaGzc

កិច្ចការដែលគរុនិស្សិតគួរអាន និងស្វែងយល់ពីសៀវភៅសិក្សាគោល៖

- របៀបដែលយើងអាចមើលឃើញវត្ថុមួយ (កាយវិភាគវិទ្យា និងសរីរវិទ្យានៃភ្នែក)
- ការកែតម្រូវកំហុសកំណុំរូបភាព (វ៉ែនតា និងកញ្ចក់ភ្នែកសិប្បនិម្មិត)
- ជំងឺរលាកអញ្ចាញធ្មេញ និងជំងឺរាក់ស៊ីធ្មេញ និងវិធានការបង្ការ
- អ្វីទៅជាខ្សែអំបោះសម្អាតធ្មេញ និងរបៀបប្រើប្រាស់វា
- ទម្លាប់ទទួលទានអាហារដើម្បីថែរក្សាសុខភាពមាត់ធ្មេញ។

## ៥. ធនធាន


- Report of eye care activities in Cambodia 2011

  **តំណភ្ជាប់ ១៤.៣៖** https://www.youtube.com/watch?v=v8TJXRoaGzc

- Sogbesab E, Yutho U. Cambodia's National Eye Care Programme and VISION 2020: The Right to Sight. Community Eye Health 13(36):57-59,2000

  **តំណភ្ជាប់ ១៤.៤៖** https://www.ncbi.nlm.nih.gov/pmc/articles/PMC1705982/

- Global School Based Student Health Survey Cambodia 2013

  **តំណភ្ជាប់ ១៤.៥៖** https://extranet.who.int/ncdsmicrodata/index.php/catalog/220/related_materials

## ៦. ការវាយតម្លៃ

- **ចំណេះដឹងនិងជំនាញ៖** ឧទាហរណ៍ ចំណេះដឹងអំពីកំហុសកំណុំដូចជា មើលជិតមិនច្បាស់ (hyperopia) ការមើលឆ្ងាយមិនច្បាស់ (មីញ៉ូប) និង អាស្ទិចម៉ាត (astigmatism) (ការធ្វើតេស្តចំណេះដឹង)។ ពន្យល់ពីរបៀបដែលយើងអាចមើលឃើញវត្ថុមួយ។ (ការធ្វើតេស្តចំណេះដឹង) ។ ពន្យល់អំពីជំងឺភ្នែកឡើងបាយ និងការបង្ការវា។ ពន្យល់ពីយន្តការនៃការលូតលាស់ និងការវិវឌ្ឍនៃជំងឺពុកធ្មេញ។
- **អាកប្បកិរិយានិងការចូលរួមក្នុងការរៀនសូត្រ៖** ឧទាហរណ៍ សង្កេតមើលអាកប្បកិរិយារបស់គរុនិស្សិតនិងការចូលរួមក្នុងការងារជាក្រុម។ ចាត់ឱ្យធ្វើរបាយការណ៍អំពីអ្វីដែលអ្នកបានរៀនពីការធ្វើការងារជាក្រុម អ្វីដែលអ្នកបានរៀនពីការស្តាប់បទបង្ហាញរបស់ក្រុមផ្សេងៗ និងបញ្ហាប្រឈមដែលអ្នកមានតាមរយៈការងារជាក្រុម។ វាយតម្លៃសំណួរ និងចម្លើយឆ្លើយឆ្លង។
- **សមត្ថភាពក្នុងការគិត វិនិច្ឆ័យ និងបញ្ចេញមតិ៖** ឧទាហរណ៍ ចាត់ឱ្យធ្វើរបាយការណ៍អំពីអ្វីដែលអ្នកបានរៀនពីការធ្វើការងារជាក្រុម អ្វីដែលអ្នកបានរៀនពីការស្តាប់បទបង្ហាញរបស់ក្រុមផ្សេងៗ និងបញ្ហាប្រឈមដែលអ្នកមានអារម្មណ៍តាមរយៈការងារជាក្រុម។ វាយតម្លៃសមត្ថភាពក្នុងការពន្យល់កិច្ចការមួយយ៉ាងត្រឹមត្រូវ និងបញ្ចុះបញ្ចូលក្នុងបទបង្ហាញការងារជាក្រុម។ វាយតម្លៃសំណួរ និងចម្លើយឆ្លើយឆ្លង។

## ៧. តំណភ្ជាប់

OralHygiene
១៤.១

EyesExercise
១៤.២

EyeCare
១៤.៣

EyeHealth
១៤.៤

GSHSpdf
១៤.៥

# មេរៀនទី ១៥ ១៩

# ជំពូកទី ៩៖ សារៈសំខាន់ និងវិធីសាស្ត្រនៃការពិនិត្យសុខភាព

## ១. ទិដ្ឋភាពទូទៅ

នៅក្នុងជំពូកទី ៩ អ្នកនឹងរៀនអំពីវិធីសាស្ត្រនៃការពិនិត្យសុខភាពដែលអាចអនុវត្តបានយ៉ាងងាយស្រួលនៅតាមសាលារៀនក្នុងប្រទេសកម្ពុជាដែលមានឧបករណ៍មិនគ្រប់គ្រាន់។ ជាតុរង្វាស់គឺ កម្ពស់ ទម្ងន់ ភ្នែក និងសមត្ថភាពការស្ដាប់ឮ។ គរុនិស្សិតនឹងរៀនអំពីឧបករណ៍ ការប្រើប្រាស់របស់វា ការរៀបចំ លំហូរនៃការពិនិត្យសុខភាព វិធីសាស្ត្រកត់ត្រា និងរបៀបប្រើប្រាស់កំណត់ត្រាដើម្បីពួកគេអាចធ្វើការពិនិត្យសុខភាពនៅតាមសាលារៀនដែលពួកគេនឹងធ្វើការបន្ទាប់ពីបញ្ចប់ការសិក្សា។ លើសពីនេះទៅទៀត គរុនិស្សិតនឹងរៀនពីរបៀបប្រើប្រាស់ផ្ទាំងរូបភាព និងសម្ភារៈផ្សេងទៀតដែលពន្យល់ពីសារៈសំខាន់នៃការពិនិត្យសុខភាពដើម្បីជូនដំណឹងដល់គរុនិស្សិត លោកគ្រូអ្នកគ្រូ ឪពុកម្ដាយ និងសហគមន៍។

ចាំបាច់ពិនិត្យឡើងវិញនូវជំពូកទី ៣, ៦ និង ៨ សម្រាប់គរុនិស្សិតដើម្បីកំណត់ថា តើកុមារមានស្ថានភាពស្របតាមការលូតលាស់ និងការអភិវឌ្ឍដែលមានសុខភាពល្អដោយផ្អែកលើការយល់ដឹងអំពីការលូតលាស់ និងការអភិវឌ្ឍរាងកាយដែរឬទេ?

ថ្នាក់នេះនឹងត្រូវបែងចែកជាបីវគ្គនៃមាតិកាអប់រំ ៩ម៉ោង។

**វគ្គទី១ (មេរៀនទី ១៥) ៖ រយៈពេល ៥០នាទី**

## ២. សេចក្ដីផ្ដើម

**រយៈពេល៖ ១០ នាទី**

(១) ប្រើប្រាស់ស្ថិតិប្រទេសកម្ពុជា។

- Mam C. et al., Physical Growth of Primary School Children in Cambodia, Int. J. School. Health. 2021; 8(1)

  **តំណភ្ជាប់ ១៥-១៩.១៖** https://intjsh.sums.ac.ir/article_47290.html

- Kubota Y. et al., Underweight and early childhood caries among young children in rural Cambodia: a pilot study, BDJ Open (2021) 7:33.

  **តំណភ្ជាប់ ១៥-១៩.២៖** https://doi.org/10.1038/s41405-021-00089-y

- Global School Based Student Health Survey Cambodia 2013

  តំណភ្ជាប់ ១៥-១៩.៣៖ https://extranet.who.int/ncdsmicrodata/index.php/catalog/220/related_materials

(២) ប្រើប្រាស់ករណី និងយកអ្វីដែលមាននៅក្នុងសារព័ត៌មាន។

(៣) សុំឱ្យគរុនិស្សិតចែករំលែកបទពិសោធន៍របស់ពួកគេ និងសង្ខេបការពិភាក្សាជាក្រុមនៅក្នុងបទបង្ហាញមួយ។ បង្ហាញទិន្នន័យនៅស្រុកកណ្តាលស្ទឹងនៃប្រទេសកម្ពុជា **(រូបទី ៩.១៧)** សូមឱ្យគរុនិស្សិតរំលឹកពីកម្ពស់និងទម្ងន់របស់ពួកគេនៅពេលពួកគេរៀននៅសាលាបឋមសិក្សា ហើយប្រៀបធៀបទិន្នន័យរបស់ពួកគេទៅនឹង **(រូបទី ៩.១៧)**។ ពិចារណាពីរបៀបពិនិត្យមើលការលូតលាស់រាងកាយរបស់កុមារ។

(៤) ណែនាំអំពីបទពិសោធន៍របស់គ្រូឧទ្ទេស។

## ៣. បញ្ជាក់បំភ្លឺ កំណត់គោលបំណងសិក្សា និងបង្រៀន

**រយៈពេល៖ ២៥នាទី**

មេរៀននេះនឹងក្តោបលើប្រធានបទដូចខាងក្រោម៖

- ❖ ១. សារៈសំខាន់នៃការពិនិត្យសុខភាព

ការរៀបចំសម្រាប់ការពិនិត្យសុខភាព

- ❖ ៣. ការអនុវត្ត
  - ➢ ៣.១. លំហូរនៃការពិនិត្យសុខភាព
- ❖ ៥. ការអនុវត្តនៅតាមសាលារៀន
- ❖ ៤. ការប្រើប្រាស់កំណត់ត្រា

## ៤. ឧទាហរណ៍នៃសកម្មភាព

**រយៈពេល៖ ១៥នាទី**

បង្កើតផ្ទាំងរូបភាពនិងសម្ភារៈផ្សេងទៀតដើម្បីជូនដំណឹងដល់កុមារ គ្រូឧទ្ទេស ឪពុកម្តាយ និងសមាជិកសហគមន៍អំពីសារៈសំខាន់នៃការពិនិត្យសុខភាព និងខ្លឹមសារនៃការពិនិត្យសុខភាពរៀងៗខ្លួន។

## វគ្គទី២ (មេរៀនទី១៦-១៧)៖ ១០០នាទី

### ១). បញ្ជាក់បំភ្លឺ កំណត់គោលបំណងសិក្សា និងបង្រៀន

**រយៈពេល៖ ២០នាទី**

ការបង្រៀននឹងក្តោបលើប្រធានបទដូចខាងក្រោម៖

- ២. វិធីសាស្ត្រពិនិត្យសុខភាព
  - ២.១. ការវាស់កម្ពស់ និងថ្លឹងទម្ងន់
- ៤. ការប្រើប្រាស់កំណត់ត្រា (**សម្ភារៈជំនួយទី ៩.២ និង ៩.៥**)

### ២). ការអនុវត្ត

**រយៈពេល៖ ៨០នាទី**

(១) រៀបចំសម្រាប់ការវាស់កម្ពស់ និងទម្ងន់។

(២) គរុនិស្សិតដើរតួនាទីជាគ្រូឧទ្ទេសនិងកុមារ ហើយសាកល្បងវាស់កម្ពស់និងថ្លឹងទម្ងន់។ គរុនិស្សិតដើរតួជាគ្រូវាស់វែង និងកត់ត្រាកម្ពស់និងទម្ងន់របស់គរុនិស្សិតដែលដើរតួជាកុមារ។ បន្ទាប់មកគរុនិស្សិតផ្លាស់ប្តូរតួអង្គគ្នាទៅវិញទៅមក។

(៣) គណនា BMI ដោយប្រើរង្វាស់ផ្ទាល់ខ្លួនរបស់អ្នកដើម្បីវាយតម្លៃរាងកាយរបស់អ្នក។

(៤) វាយតម្លៃ BMI របស់អ្នក។ ពិចារណាការណែនាំអំពីសុខភាពសម្រាប់ខ្លួនអ្នកដោយផ្អែកលើលទ្ធផលរបស់ BMI នោះ ហើយសូមសរសេរមតិយោបល់។

## វគ្គទី ៣ (មេរៀនទី ១៨-១៩) ១០០នាទី

### ១). បញ្ជាក់បំភ្លឺ កំណត់គោលបំណងសិក្សា និងបង្រៀន

**រយៈពេល៖ ២០នាទី**

ការបង្រៀននឹងក្តោបលើប្រធានបទដូចខាងក្រោម៖

- ២. វិធីសាស្ត្រពិនិត្យសុខភាព
  - ២.២. ការធ្វើតេស្តភ្នែក
    - ២.២.១. វិធីសាស្ត្រធ្វើតេស្តភ្នែក (ការវាយតម្លៃគំហើញ (**សម្ភារៈជំនួយទី ៩.១**))
  - ២.៣. ការធ្វើតេស្តសមត្ថភាពស្តាប់ឮ
    - ២.៣.១. វិធីសាស្ត្រនៃការធ្វើតេស្តសមត្ថភាពស្តាប់ឮ

២.៣.២. ការវាយតម្លៃសមត្ថភាពស្ដាប់ឮ

➢ ២.៤. ការកត់ត្រា (**សម្ភារៈជំនួយទី ៩.២, ៩.៣, ៩.៥**)

❖ ៥. ការអនុវត្តនៅតាមសាលារៀន

➢ ៥.២. ឧទាហរណ៍នៃការអនុវត្ត (**តារាងទី ៩.៣៖** ដំណើរការនៃការអនុវត្តការពិនិត្យសុខភាពចាប់ពីផែនការរហូតដល់ការវាយតម្លៃ)

### ២). ការអនុវត្ត

**រយៈពេល៖ ៨០នាទី**

(១) រៀបចំសម្រាប់ការធ្វើតេស្តភ្នែក និងសមត្ថភាពស្ដាប់ឮ។

(២) គរុនិស្សិតដើរតួនាទីជាគ្រូឧទ្ទេសនិងកុមារ និងសាកល្បងធ្វើតេស្តភ្នែកនិងសមត្ថភាពស្ដាប់ឮ។ គរុនិស្សិតដើរតួជាគ្រូវាស់វែង និងកត់ត្រាកម្ពស់ និងទម្ងន់របស់គរុនិស្សិតដែលដើរតួជាកុមារ។ បន្ទាប់មក គរុនិស្សិតផ្លាស់ប្ដូរតួអង្គគ្នាទៅវិញទៅមក។

(៣) គរុនិស្សិតវាយតម្លៃលទ្ធផលនៃការវាស់វែង។

(៤) ពិចារណាលើការណែនាំអំពីសុខភាពសម្រាប់ខ្លួនអ្នកដោយផ្អែកលើការវាយតម្លៃ ហើយសូមសរសេរមតិយោបល់។

## ៥. ធនធាន


- Report of eye care activities in Cambodia 2011

  **តំណភ្ជាប់ ១៥-១៩.៤៖** http://www.npehcambodia.com/filelibrary/Report_of_PBL_Activities_in_2011.pdf

- Sogbesab E, Yutho U. Cambodia's National Eye Care Programme and VISION 2020: The Right to Sight. Community Eye Health 13(36):57-59,2000

  **តំណភ្ជាប់ ១៥-១៩.៥៖** https://www.ncbi.nlm.nih.gov/pmc/articles/PMC1705982/

- Global School Based Student Health Survey Cambodia 2013

  **តំណភ្ជាប់ ១៥-១៩.៦៖** https://extranet.who.int/ncdsmicrodata/index.php/catalog/220/related_materials

- Samphors Sim, W. Laohasiriwong. Fast Food Consumption, Overweight and Obesity among Working Age Persons in Cambodia, Journal of Clinical and Diagnostic Research 13(7):LC01-LC06, 2019

  **តំណភ្ជាប់ ១៥-១៩.៧៖** https://www.jcdr.net/ReadXMLFile.aspx?id=12965

## ៦. ការវាយតម្លៃ

- **ចំណេះដឹងនិងជំនាញ៖** ឧទាហរណ៍ ពន្យល់ពីគោលបំណងនៃការពិនិត្យសុខភាព (ហេតុអ្វីការពិនិត្យសុខភាពមានសារៈសំខាន់សម្រាប់សុខភាពកុមារ?) (ការធ្វើតេស្តចំណេះដឹង)។ ចំណេះដឹងអំពី BMI (របៀបដែលវាត្រូវបានគណនា និងអត្ថន័យសម្រាប់សុខភាពរបស់អ្នក។ល។) (ការធ្វើតេស្តចំណេះដឹង)។ ពន្យល់ពីការប្រើប្រាស់កំណត់ត្រាពិនិត្យសុខភាព (ការធ្វើតេស្តចំណេះដឹង)។ ពន្យល់ពីនីតិវិធីនៃការវាស់កម្ពស់ (ការធ្វើតេស្តចំណេះដឹង)។
- ចាត់ទុកថា អ្នកកំពុងបង្រៀនអំពីសុខភាពភ្នែកទៅសិស្សកម្រិតបឋមសិក្សា ចូរគិតពីមាតិកា និងវិធីសាស្ត្របង្រៀន និងធ្វើកិច្ចតែងការសម្រាប់ថ្នាក់និទ្សេន៍ (របាយការណ៍របាយការណ៍ចាត់ឱ្យធ្វើ)។
- ចូលមើលវីដេអូនៅក្នុងយូធូបដែលបង្រៀនសិស្សពីរបៀបដុះធ្មេញ និងបង្កើតចំរៀងពីការដុសធ្មេញសម្រាប់កុមារកម្ពុជា (កិច្ចការជាក្រុម)។

  តំណភ្ជាប់ ១៥-១៩.៨៖ https://www.youtube.com/watch?v=wCio_xVIgQ0
- **ឥរិយាបថសិក្សានិងការចូលរួម៖** ឧទាហរណ៍ សង្កេតមើលអាកប្បកិរិយារបស់គរុនិស្សិត និងការចូលរួមក្នុងសកម្មភាពពិនិត្យសុខភាព។ កិច្ចការនេះគឺដើម្បីសង្ខេបនៅក្នុងរបាយការណ៍អ្វីដែលអ្នកបានរៀនពីសកម្មភាពពិនិត្យសុខភាព អ្វីដែលអ្នកបានរៀនពីសកម្មភាពរបស់គរុនិស្សិតផ្សេងទៀត និងបញ្ហាប្រឈមដែលអ្នកមានតាមរយៈសកម្មភាព។ វាយតម្លៃសំណួរនិងចម្លើយបែបឆ្លើយឆ្លង។
- **សមត្ថភាពក្នុងការគិត វិនិច្ឆ័យ និងបញ្ចេញមតិ៖** ឧទាហរណ៍ សង្កេតមើលអាកប្បកិរិយារបស់គរុនិស្សិត និងការចូលរួមក្នុងសកម្មភាពពិនិត្យសុខភាព។ កិច្ចការនេះគឺដើម្បីសង្ខេបនៅក្នុងរបាយការណ៍ពីអ្វីដែលអ្នកបានរៀនពីសកម្មភាពពិនិត្យសុខភាព អ្វីដែលអ្នកបានរៀនពីសកម្មភាពរបស់គរុនិស្សិតផ្សេងទៀត និងបញ្ហាប្រឈមដែលអ្នកមានតាមរយៈសកម្មភាព។ វាយតម្លៃសមត្ថភាពក្នុងការគិត និងបញ្ចេញមតិតាមរយៈការបង្កើតផ្ទាំងរូបភាព និងសម្ភារៈផ្សេងទៀតដែលមានគោលបំណងជូនដំណឹងដល់កុមារ គ្រូឧទ្ទេស ឪពុកម្តាយ និងសមាជិកសហគមន៍អំពីសារៈសំខាន់ និងខ្លឹមសារនៃការពិនិត្យសុខភាព។ វាយតម្លៃសំណួរ និងចម្លើយឆ្លើយឆ្លង។

## ៧. តំណភ្ជាប់

១៥-១៩.១

១៥-១៩.២

១៥-១៩.៣, ១៥-១៩.៦

១៥-១៩.៤

១៥-១៩.៥

១៥-១៩.៧

១៥-១៩.៨

# មេរៀនទី ២០ ២១

# ជំពូកទី ១៥៖ ការសង្គ្រោះបឋមនៅសាលារៀន

## ១. ទិដ្ឋភាពទូទៅ

ជំពូកទី ១៥ និយាយអំពីការសង្គ្រោះបឋមនៅសាលារៀន។ ដោយសន្មតថា បុគ្គលិកវិទ្យាស្ថានគរុកោសល្យមិនមែនជាអ្នកជំនាញផ្នែកវេជ្ជសាស្ត្រ ហើយនឹងមិនអនុវត្តនីតិវិធីវេជ្ជសាស្ត្រ គរុនិស្សិតនឹងរៀនអំពីរបៀបយកសញ្ញាជីវិត មូលដ្ឋានគ្រឹះនៃការសង្គ្រោះបឋម និងការព្យាបាលរបួសស្នាមរបួស និងការត្អូញត្អែរបែបវេជ្ជសាស្ត្រដែលទំនងនឹងក្លាយទៅជារឿងធម្មតានៅប្រទេសកម្ពុជា។ ជាពិសេសក្នុងការដោះស្រាយបញ្ហាប៉ះទង្គិច គរុនិស្សិតគួរមានការយល់ដឹងល្អអំពីកាយវិភាគវិទ្យានៃប្រភេទរបួស ព្រមទាំងការយល់ដឹងល្អអំពីវិធីសាស្ត្រ RICE ។

ការដឹងខ្លួន ការដកដង្ហើម ជីពចរ សម្ពាធឈាម និងសីតុណ្ហភាពរាងកាយនឹងត្រូវបានវាស់វែងជាក់ស្តែង។

## ២. សេចក្តីផ្តើម

**រយៈពេល៖ ៥នាទី**

(១) ប្រើប្រាស់ស្ថិតិប្រទេសកម្ពុជា។

- Utilization of Health Services for Accident, Illness, or Injury. In Cambodia Demographic and Health Survey 2014

  **តំណភ្ជាប់ ២០-២១.១៖** https://dhsprogram.com/pubs/pdf/FR312/FR312.pdf

(២) ប្រើប្រាស់ករណី និងយកអ្វីដែលមាននៅក្នុងព័ត៌មាន។

- Red Cross and USAID providing first aid training to community and staff, The Phnom Penh Post 17 Jan 2022

  **តំណភ្ជាប់ ២០-២១.២៖** https://www.phnompenhpost.com/national/red-cross-and-usaid-providing-first-aid-training-community-and-staff

- Pre-teen girl another victim to drowning, Khmer Times 24 Aug 2022

  **តំណភ្ជាប់ ២០-២១.៣៖** https://www.khmertimeskh.com/501138126/pre-teen-girl-another-victim-to-drowning/

- Two young people dead due to drowning after being swept into river, another rescued. Khmer Times 17 Apr 2022

  **តំណភ្ជាប់ ២០-២១.៤៖** https://www.khmertimeskh.com/501059053/two-young-people-dead-due-to-drowning-after-being-swept-into-river-another-rescued/

(៣) សុំឱ្យគរុនិស្សិតចែករំលែកបទពិសោធន៍របស់ពួកគេ និងសង្ខេបការពិភាក្សាជាក្រុមនៅក្នុងបទបង្ហាញមួយ។ សួរគរុនិស្សិតអំពីបទពិសោធន៍ផ្ទាល់ខ្លួនរបស់ពួកគេទាក់ទងនឹងការរងរបួស និងគ្រោះថ្នាក់។

ជ្រើសរើសយកស្នាមប្រេះ និងស្នាមជាំ ហើយសួរអំពីបទពិសោធន៍របស់ពួកគេក្នុងរបៀបដែលពួកគេអនុវត្តការសង្គ្រោះបឋមប្រចាំថ្ងៃ (មានវិធីជាច្រើនក្នុងការព្យាបាល)។ សួរថា ហេតុអ្វីបានជាគរុនិស្សិតធ្វើការព្យាបាលតាមបែបសង្គ្រោះបឋម ហើយនរណាជាអ្នកបង្រៀនគាត់?

(៤) ណែនាំអំពីបទពិសោធន៍របស់គ្រូឧទ្ទេស។

## ៣. បញ្ជាក់បំភ្លឺ កំណត់គោលបំណងសិក្សា និងបង្រៀន

រយៈពេល៖ ២៥នាទី

មេរៀននៅជំពូកទី ១៥ ក្តោបលើខ្លឹមសារដូចតទៅ៖

- ១. ភាពចាំបាច់ក្នុងការរៀនជួយសង្គ្រោះបឋម
- ២. សញ្ញាជីវិត
- ៤. ការសង្គ្រោះបឋមសមស្របចំពោះស្ថានភាពផ្សេងៗ
  - ៤.១. ការសង្គ្រោះបឋមចំពោះអ្នកមានរបួស

    ៤.១.៤. របួសអវយវៈ

    ខ) ជាំ គ្រេច បាក់ឆ្អឹង និងភ្លាត់ឆ្អឹង **(រូបទី ១៥.៨)**

    គ) វិធីសាស្ត្រ RICE សម្រាប់ការព្យាបាលរបួស

    ៤.១.៥. ការរលាក

តម្រូវការសម្រាប់មេរៀននេះ៖

គរុនិស្សិតត្រូវមើលវីដេអូអំពីរបៀបវាស់សញ្ញាជីវិត របៀបបញ្ឈប់ការហូរឈាម របៀបព្យាបាលស្នាមរបួស មុត និង រលាក និងរបៀបអនុវត្តនីតិវិធី RICE ដោយរៀបចំមុនពេលចាប់ផ្តើមថ្នាក់រៀន។ គរុនិស្សិតមើលវីដេអូអំឡុងពេលកត់ចំណាំលើចំណុចគន្លឹះទាំងនេះ។

## ៤. ការអនុវត្ត

រយៈពេល៖ ៧០នាទី

- គរុនិស្សិតពីរនាក់ចាប់ដៃគូគ្នាដើម្បីវាស់សីតុណ្ហភាព ជីពចរ សម្ពាធឈាម និងដង្ហើមរបស់គ្នាទៅវិញទៅមក។
- នីតិវិធីបែបប្រព័ន្ធថេរលំនឹង (hemostatic) (អត្ថបទដកស្រង់ ១៥.៤៖ ការគ្រប់គ្រងការហូរឈាមតាមច្រមុះ)
- ព្យាបាលរបួស ស្នាម របួស ការរលាក
- វិធីសាស្ត្រ RICE សម្រាប់ព្យាបាលរបួស

កិច្ចការដែលគរុនិស្សិតគួរអាន និងស្វែងយល់ពីសៀវភៅសិក្សាគោល៖

គរុនិស្សិតត្រូវមើលវីដេអូអំពីរបៀបវាស់សញ្ញាជីវិត របៀបបញ្ឈប់ការហូរឈាម របៀបព្យាបាលរបួស មុត និងរលាក និងរបៀបអនុវត្តនីតិវិធី RICE ជាការរៀបចំជាមុន មុនពេលថ្នាក់រៀនចាប់ផ្តើម។ គរុនិស្សិតមើលវីដេអូអំឡុងពេលកត់ចំណាំលើចំណុចគន្លឹះទាំងនេះ។

- ៣. ជំហាននៃការសង្គ្រោះបឋម
- ៤. ការសង្គ្រោះបឋមសមស្របចំពោះស្ថានភាពផ្សេងៗ
  - ៤.១. ការសង្គ្រោះបឋមចំពោះអ្នកមានរបួស
    - ៤.១.១. របួសក្បាល
    - ៤.១.២. របួសលើមុខ
    - ៤.១.៣. របួសទ្រូង ឬពោះ
  - ៤.២. ការសង្គ្រោះបឋមសម្រាប់ជំងឺនានា

## ៥. ឯកសារយោង


- The International Federation of Red Cross and Red Crescent Societies. International first aid and resuscitation guidelines 2020

  តំណភ្ជាប់ ២០-២១.៥៖ https://www.ifrc.org/sites/default/files/2022-02/EN_GFARC_GUIDELINES_2020.pdf
- WHO. Hypertension

  តំណភ្ជាប់ ២០-២១.៦៖ https://www.who.int/news-room/fact-sheets/detail/hypertension
- Pasteur Institute in Cambodia. Rabies Prevention Centers - Pasteur Institute in Cambodia (pasteur-kh.org)

  តំណភ្ជាប់ ២០-២១.៧៖ https://www.pasteur-kh.org/rabies-prevention-centers/
- Yashoda Hospitals. First aid & emergencies Tips for high altitude fall.

  តំណភ្ជាប់ ២០-២១.៨៖ https://www.youtube.com/watch?v=Vs1NWcW-r7M


## ៦. ការវាយតម្លៃ

- **ចំណេះដឹងនិងជំនាញ៖** ឧទាហរណ៍ ចំណេះដឹងអំពីសញ្ញាជីវិត (បញ្ជីសញ្ញាជីវិតទាំងប្រាំ) (ការធ្វើតេស្តចំណេះដឹង)។ ពន្យល់ពីភាពចាំបាច់នៃការរៀនចំណេះដឹង និងជំនាញសង្គ្រោះបឋម (ការធ្វើតេស្តចំណេះដឹង)។ តើវិធីណាដែលត្រឹមត្រូវដើម្បីបញ្ឈប់ការហូរឈាមច្រមុះ? (ការធ្វើតេស្តចំណេះដឹង)។ ចំណេះដឹងអំពីវិធីសាស្ត្រ RICE (ការធ្វើតេស្តចំណេះដឹង)។ សូមក្រឡេកមើលតួលេខនៃរបួសទាំងបួន ហើយឆ្លើយអំពីមូលហេតុនៃមុខរបួសនីមួយៗ (ការធ្វើតេស្តចំណេះដឹង)។

- **អាកប្បកិរិយានិងការចូលរួមក្នុងការរៀនសូត្រ៖** ឧទាហរណ៍ សង្កេតមើលអាកប្បកិរិយារបស់គរុនិស្សិត និងការចូលរួមក្នុងការអនុវត្តជំនួយដំបូង។ កិច្ចការនេះគឺដើម្បីសង្ខេបនៅក្នុងរបាយការណ៍អ្វីដែលអ្នកបានរៀនអំពីការអនុវត្តជំនួយដំបូង អ្វីដែលអ្នកបានរៀនពីសកម្មភាពរបស់គរុនិស្សិតផ្សេងទៀត និងបញ្ហាប្រឈមដែលអ្នកមានតាមរយៈការអនុវត្ត។ វាយតម្លៃសំណួរ និងចម្លើយឆ្លើយឆ្លង។
- **សមត្ថភាពក្នុងការគិត វិនិច្ឆ័យ និងបញ្ចេញមតិ៖** ឧទាហរណ៍ ផ្តល់របាយការណ៍អំពីអ្វីដែលអ្នកបានរៀនពីការអនុវត្តការសង្គ្រោះបឋម អ្វីដែលអ្នកបានរៀនពីសកម្មភាពរបស់គរុនិស្សិតផ្សេងទៀត និងបញ្ហាប្រឈមដែលអ្នកមានតាមរយៈការអនុវត្ត។ វាយតម្លៃថា តើគរុនិស្សិតអាចអនុវត្តជំនួយដំបូងបានត្រឹមត្រូវតាមការពន្យល់របស់គ្រូដែរឬទេ។ វាយតម្លៃសំណួរនិងចម្លើយឆ្លើយឆ្លង។

## ៧. តំណភ្ជាប់

២០-២១.១ ២០-២១.២ ២០-២១.៣ ២០-២១.៤

២០-២១.៥ ២០-២១.៦ ២០-២១.៧ ២០-២១.៨

# មេរៀនទី ២២ ២៣

# ជំពូកទី ១០៖ ផលប៉ះពាល់សុខភាពនៃការប្រើប្រាស់ថ្នាំជក់ គ្រឿងស្រវឹង និងគ្រឿងញៀន

## ១. ទិដ្ឋភាពទូទៅ

ដូចនៅក្នុងជំពូកទី ៥ ដែរ យើងបានរៀនអំពីសារៈសំខាន់នៃការបង្កើតទម្លាប់រស់នៅឱ្យមានសុខភាពល្អ។ ម្យ៉ាងវិញទៀត នៅក្នុងជំពូកទី ៦ យើងបានរៀនអំពី «ជំងឺទាក់ទងនឹងរបៀបរស់នៅ» ដែលបង្ហាញថា វាពិបាកក្នុងការរក្សារបៀបរស់នៅដែលមានសុខភាពល្អពីវ័យជំទង់រហូតដល់ពេញវ័យណាស់ ហើយទម្លាប់របៀបរស់នៅគឺជាកត្តារួមចំណែកមួយ។

នៅក្នុងជំពូកទី ១០ គរុនិស្សិតនឹងរៀនអំពីការប្រើប្រាស់គ្រឿងស្រវឹង ថ្នាំជក់ និងការញៀនគ្រឿងញៀនផ្សេងៗទៀត។ ទម្លាប់ទាំងអស់នេះគឺជាទម្លាប់ដែលចាប់ផ្តើមក្នុងវ័យជំទង់ និងមានឥទ្ធិពលមិនគួរឱ្យចង់បានដល់សុខភាព។ គរុនិស្សិតនឹងរៀនពីរបៀបដែលគ្រឿងស្រវឹង ថ្នាំជក់ ថ្នាំសំយោគ និងថ្នាំដទៃទៀតដែលបង្កឱ្យញៀន។ គរុនិស្សិតក៏នឹងសិក្សាអំពីឥទ្ធិពលរបស់ពួកគេទៅលើសុខភាពផ្លូវចិត្ត និងសង្គម ព្រមទាំងរាងកាយផងដែរ។ ដើម្បីយល់អំពី ការញៀនស្រា ថ្នាំជក់ និងថ្នាំសំយោគផ្សេងៗគឺជាបញ្ហាសុខភាពដ៏សំខាន់ដែលអាចជះឥទ្ធិពលអវិជ្ជមានមិនត្រឹមតែលើបុគ្គលប៉ុណ្ណោះទេ ថែមទាំងប៉ះពាល់ដល់មិត្តភក្តិ គ្រួសារ និងសង្គម និងដើម្បីចាប់យកសមត្ថភាពជាគ្រូឧទ្ទេសកក្នុងការអនុវត្តការអប់រំសុខភាពមិនត្រឹមតែសម្រាប់កុមារ ប៉ុន្តែក៏សម្រាប់មនុស្សធំនៅជុំវិញខ្លួនផងដែរ។

## ២. សេចក្តីផ្តើម

**រយៈពេល៖ ៥នាទី**

(១) ប្រើប្រាស់ស្ថិតិប្រទេសកម្ពុជា។

- Prevalence of current tobacco use (% of adults)

  **តំណភ្ជាប់ ២២-២៣.១៖** https://data.worldbank.org/indicator/SH.PRV.SMOK?end=2020&locations=KH&start=2000&view=chart

- Total alcohol consumption per capita, male (litters of pure alcohol, projected estimates, male +15 years of age) -Cambodia

  **តំណភ្ជាប់ ២២-២៣.២៖** https://data.worldbank.org/indicator/SH.ALC.PCAP.MA.LI?locations=KH

- Total alcohol consumption per capita, female (litters of pure alcohol, projected estimates, female +15 years of age) -Cambodia

  **តំណភ្ជាប់ ២២-២៣.៣៖** https://data.worldbank.org/indicator/SH.ALC.PCAP.FE.LI?locations=KH

- Global School-based Student Health Survey ( GSHS ) Cambodia Factsheet 2013

  តំណភ្ជាប់ ២២-២៣.៤៖ https://extranet.who.int/ncdsmicrodata/index.php/catalog/220/related- materials

(២) ប្រើប្រាស់ករណី និងយកអ្វីដែលមាននៅក្នុងសារព័ត៌មាន។

- Cambodia Pushed to Set Alcohol Age Limit, Cambodianess, 7 May 2022

  តំណភ្ជាប់ ២២-២៣.៥៖ https://cambodianess.com/article/cambodia-pushed-to-set-alcohol-age-limit

- Lack of Alcohol Law and Drinking Age Leaves Cambodian Youths Vulnerable, VOA Cambodia, 30 Sep 2019.

  តំណភ្ជាប់ ២២-២៣.៦៖ https://www.voacambodia.com/a/lack-of-alcohol-law-and-drinking-age-leaves-Cambodian-youths-vulnerable/5104040.html

(៣) សុំឱ្យគរុនិស្សិតចែករំលែកបទពិសោធន៍របស់ពួកគេ និងសង្ខេបការពិភាក្សាជាក្រុមនៅក្នុងបទបង្ហាញមួយ។

(៤) ណែនាំអំពីបទពិសោធន៍របស់គ្រូឧទ្ទេស។

## ៣. បញ្ជាក់បំភ្លឺ កំណត់គោលបំណងសិក្សា និងបង្រៀន

**រយៈពេល៖ ៦០នាទី**

មេរៀនក្នុងជំពូកទី១០ ផ្តោតលើចំណុចបីដូចខាងក្រោម៖

- ១. ការប្រើប្រាស់ថ្នាំជក់ និងសុខភាព
  - ១.១. ផលប៉ះពាល់សុខភាពនៃការប្រើប្រាស់ថ្នាំជក់
- ២. ការប្រើប្រាស់គ្រឿងស្រវឹង និងសុខភាព
  - ២.១. ផលប៉ះពាល់សុខភាពនៃគ្រឿងស្រវឹង
  - ២.២. ការញៀនសុរា/ប្រមឹក
- ៤. ការបំពានគ្រឿងញៀន និងសុខភាព
  - ៤.១. តើអ្វីទៅជាការបំពានគ្រឿងញៀន?
  - ៤.២. តើអ្វីទៅជាការញៀនគ្រឿងញៀន?

## ៤. ឧទាហរណ៍នៃកិច្ចការពិភាក្សាជាក្រុមនិងសំណួរឆ្លើយឆ្លង

**រយៈពេល៖ ៣៥នាទី**

- ជាការរឹតបន្តឹងលើការផ្សាយពាណិជ្ជកម្មសម្រាប់ការប្រើប្រាស់គ្រឿងស្រវឹងរួមមាន «បម្រាមលើការផ្សាយពាណិជ្ជកម្មដែលទាក់ទាញអនីតិជន» នៅក្នុងប្រទេសកាណាដា និង «បម្រាមលើការផ្សាយពាណិជ្ជកម្មតាមទូរទស្សន៍និងភាពយន្ត» នៅក្នុងប្រទេសបារាំង។ ពិចារណាថា តើវិធានការសង្គមបែបណាដែលអាចត្រូវបាន

អនុវត្តនៅក្នុងប្រទេសកម្ពុជាដើម្បីបង្កើតបរិយាកាសសម្រាប់ការទប់ស្កាត់ការប្រើប្រាស់ថ្នាំជក់ និងការប្រើប្រាស់គ្រឿងស្រវឹងក្នុងចំណោមកុមារ។

- ប្រទេសខ្លះអនុញ្ញាតឱ្យប្រើប្រាស់កញ្ឆាសម្រាប់តែការកម្សាន្តផ្ទាល់ខ្លួនប៉ុណ្ណោះ ចំណែកប្រទេសខ្លះទៀតមានច្បាប់ហាមឃាត់ការប្រើប្រាស់វាតែម្តង។ សូមស្រាវជ្រាវអំពីកញ្ឆា ហើយពិចារណាថា តើគួរអនុញ្ញាតឬហាមឃាត់ក្នុងប្រទេសកម្ពុជា?
- សូមធ្វើផ្ទាំងរូបភាពសម្រាប់កុមារ លោកគ្រូអ្នកគ្រូ មាតាបិតា និងសហគមន៍ដើម្បីជូនដំណឹងដល់ពួកគេអំពីគ្រោះថ្នាក់នៃថ្នាំជក់។

កិច្ចការដែលគរុនិស្សិតគួរអាន និងស្វែងយល់ពីសៀវភៅសិក្សាគោល៖

❖ ៥. ការរីករាលដាលនៃការប្រើប្រាស់ថ្នាំជក់ ការប្រើប្រាស់គ្រឿងស្រវឹង និងគ្រឿងញៀននៅប្រទេសកម្ពុជា
  ➢ ៥.១. ការប្រើប្រាស់ថ្នាំជក់នៅប្រទេសកម្ពុជា
  ➢ ៥.២. ការប្រើប្រាស់គ្រឿងស្រវឹងនៅប្រទេសកម្ពុជា
  ➢ ៥.៣. ការប្រើប្រាស់គ្រឿងញៀននៅប្រទេសកម្ពុជា
  ➢ ៥.៤. កត្តាចិត្តសាស្ត្រ/សង្គមទាក់ទងនឹងការប្រើប្រាស់ថ្នាំជក់ គ្រឿងស្រវឹង និងគ្រឿងញៀន

(**អត្ថបទដកស្រង់ ១០.៧៖** យុទ្ធសាស្ត្រសកលលើថ្នាំជក់ និងគ្រឿងស្រវឹង ។)

# ៥. ធនធាន


- WHO. Tobacco,
  តំណភ្ជាប់ ២២-២៣.៧៖ https://www.who.int/news-room/fact-sheets/detail/tobacco
- Cambodianess. Student Smokers Defy Health Dangers, 22 June 2022.
  តំណភ្ជាប់ ២២-២៣.៨៖ https://cambodianess.com/article/student-smokers-defy-health-dangers
- Yuthea N., Drug Use Among Cambodian In-School Youth,
  តំណភ្ជាប់ ២២-២៣.៩៖ https://nida.nih.gov/international/abstracts/drug-use-among-cambodian-in-school-youth
- GNC: Youths “forced” into drugs, The Phnom Pehn Post, 03 Sep 2019.
  តំណភ្ជាប់ ២២-២៣.១០៖ https://www.phnompenhpost.com/national/gnc-youths-forced-drugs
- Are Cambodia's Kids Hooked On Drugs? The ASEAN Post, 10 Oct 2020.
  តំណភ្ជាប់ ២២-២៣.១១៖ https://theaseanpost.com/article/are-cambodias-kids-hooked-drugs


# ៦. ការវាយតម្លៃ

- **ចំណេះដឹងនិងជំនាញ៖** ឧទាហរណ៍ ចំណេះដឹងអំពីផលប៉ះពាល់សុខភាពនៃការប្រើប្រាស់ថ្នាំជក់ គ្រឿងស្រវឹង និងគ្រឿងញៀនខុសច្បាប់(ការធ្វើតេស្តចំណេះដឹង)។ ពន្យល់អំពីការញៀនថ្នាំអ្វី (ការធ្វើតេស្តចំណេះដឹង)។ ពន្យល់អំពីការពឹងផ្អែកខាងផ្លូវចិត្ត ការពឹងផ្អែកលើរាងកាយ និងការអត់ធ្មត់(ការធ្វើតេស្តចំណេះដឹង)។ស្រាវជ្រាវ

សកម្មភាពរបស់អង្គការដែលគាំទ្រការស្តារឡើងវិញពីការញៀនគ្រឿងញៀននៅប្រទេសកម្ពុជា និងរាយការណ៍អំពីប្រសិទ្ធភាពនៃការស្តារឡើងវិញ។ (រាយការណ៍របាយការណ៍ចាត់ឱ្យធ្វើ)។

- **អាកប្បកិរិយានិងការចូលរួមក្នុងការរៀនសូត្រ៖** ឧទាហរណ៍ សង្កេតមើលអាកប្បកិរិយារបស់គរុនិស្សិត និងការចូលរួមក្នុងការងារជាក្រុម។ ចាត់ឱ្យធ្វើរបាយការណ៍អំពីអ្វីដែលអ្នកបានរៀនពីការធ្វើការងារជាក្រុម អ្វីដែលអ្នកបានរៀនពីការស្តាប់បទបង្ហាញរបស់ក្រុមផ្សេងៗ និងបញ្ហាប្រឈមដែលអ្នកមានតាមរយៈការងារជាក្រុម។ វាយតម្លៃសំណួរនិងចម្លើយឆ្លើយឆ្លង។
- **សមត្ថភាពក្នុងការគិត វិនិច្ឆ័យ និងបញ្ចេញមតិ៖** ឧទាហរណ៍ ចាត់ឱ្យធ្វើរបាយការណ៍អំពីអ្វីដែលអ្នកបានរៀនពីការធ្វើការងារជាក្រុម អ្វីដែលអ្នកបានរៀនពីការស្តាប់បទបង្ហាញរបស់ក្រុមផ្សេងៗ និងបញ្ហាប្រឈមដែលអ្នកមានតាមរយៈការងារជាក្រុម។ វាយតម្លៃសមត្ថភាពក្នុងការពន្យល់កិច្ចការមួយលើភាពសុក្រឹត និងភាពជឿជាក់ក្នុងបទបង្ហាញការងារជាក្រុម។ វាយតម្លៃសំណួរនិងចម្លើយឆ្លើយឆ្លង។

## ៧. តំណភ្ជាប់

២២-២៣.១

២២-២៣.២

២២-២៣.៣

២២-២៣.៤

២២-២៣.៥

២២-២៣.៦

២២-២៣.៧

២២-២៣.៨

២២-២៣.៩

២២-២៣.១០

២២-២៣.១១

# មេរៀនទី ២៤ ២៥

# ជំពូកទី ១១៖ ការប្រែប្រួលផ្លូវចិត្ត និងរាងកាយអំឡុងពេលយុវវ័យ (ការអប់រំផ្លូវភេទលក្ខណៈទូលំទូលាយ)

## ១. ទិដ្ឋភាពទូទៅ

នៅក្នុងជំពូកទី ៣ យើងបានសិក្សាពីការលូតលាស់ និងការអភិវឌ្ឍចាប់តាំងពីទារកហូតដល់អាយុចូលរៀនបឋមសិក្សា។ ជំពូកទី១១ ផ្តោតលើការផ្លាស់ប្តូររាងកាយ ផ្លូវចិត្ត និងសង្គមក្នុងអំឡុងពេលយុវវ័យ។ ជាពិសេសគរុនិស្សិតនឹងសិក្សាពីការផ្លាស់ប្តូរដែលកើតឡើងក្នុងដំណើរការចាប់តាំងពីការចាប់ផ្តើមនៃលក្ខណៈផ្លូវភេទបន្ទាប់បន្សំរហូតដល់ភាពចាស់ទុំខាងផ្លូវភេទ។

ទោះបីមិនរាប់បញ្ចូលទាំងអស់ក៏ដោយ ជំពូកនេះក្តោបនូវអ្វីដែលបញ្ចូលនៅក្នុងការអប់រំផ្លូវភេទលក្ខណៈទូលំទូលាយដូចដែលបានណែនាំដោយអង្គការអន្តរជាតិដូចជា UNESCO ជាដើម។ ទាំងនេះគឺជាការផ្លាស់ប្តូរការអភិវឌ្ឍនៃរាងកាយដែលទាក់ទងនឹងភាពចាស់ទុំខាងផ្លូវភេទ ការបន្តពូជនិងសុខភាព រាប់ចាប់ពីការបញ្ចេញពងអូវុលរហូតដល់មានផ្ទៃពោះ និងការសម្រាលកូន ជំងឺកាមរោគ អាកប្បកិរិយាផ្លូវភេទ បទដ្ឋានផ្លូវភេទនៅប្រទេសកម្ពុជា ភាពចម្រុះខាងផ្លូវភេទ និងអំពើហិង្សាផ្លូវភេទ។ លើសពីនេះទៅទៀត ការអប់រំពេលមករដូវនៅតាមសាលារៀននិងនៅផ្ទះគឺជាបញ្ហាបន្ទាន់ក្នុងសុខភាពសិក្សា។

## ២. សេចក្តីផ្តើម

**រយៈពេល៖ ៥ នាទី**

(១) ប្រើប្រាស់ស្ថិតិប្រទេសកម្ពុជា។

- A Statistical Profile of Child Protection in Cambodia, 2018.

  **តំណភ្ជាប់ ២៤-២៥.១៖** https://www.unicef.org/cambodia/media/716/file/Cambodia_Report_Final_Khmer.pdf%20.pdf

(២) ប្រើប្រាស់ករណី និងយកអ្វីដែលមាននៅក្នុងសារព័ត៌មាន។

«សុខភាពផ្លូវភេទនិងសុខភាពបន្តពូជគឺជាបញ្ហាដ៏ធំបំផុតមួយដែលយុវវ័យកំពុងប្រឈមមុខ ជាពិសេសនៅតាមបណ្តាខេត្ត»។ «ប្រហែល ៣០% នៃយុវជនគ្មានការយល់ដឹងអំពីបញ្ហាជាមូលដ្ឋានដូចជា ការមករដូវ ការឆ្លងជំងឺកាមរោគ និងការពន្យារកំណើត ទោះបីជាពួកគេសកម្មខាងផ្លូវភេទក៏ដោយ។» (ការយកចិត្តទុកដាក់លើសុខភាពយុវជន កាសែតភ្នំពេញប៉ុស្តិ៍ ថ្ងៃទី ៩ ខែតុលា ឆ្នាំ ២០១៥ ។)

**តំណភ្ជាប់ ២៤-២៥.២៖** https://www.phnompenhpost.com/national/youth-health-care-focus

«សៀវភៅភាគច្រើនជាភាសាអង់គ្លេស ហើយមានធនធានតិចតួចអំពីការអប់រំផ្លូវភេទជាភាសាខ្មែរដែលធ្វើឱ្យវាក្លាយជាបញ្ហាប្រឈមសម្រាប់គ្រូឧទ្ទេសក្នុងការដោះស្រាយបញ្ហានេះដល់គរុនិស្សិតរបស់ពួកគេ»។

( It's OK to talk about sex, The Phnom Penh Post 03 Aug 2012 )

**តំណភ្ជាប់ ២៤-២៥.៣៖** https://www.phnompenhpost.com/columns/it%E2%80%99s-ok-talk-about-sex

- WHO: Cambodia Contraception within the context of adolescents' sexual and reproductive lives: Country profile.

  **តំណភ្ជាប់ ២៤-២៥.៤៖** https://apps.who.int/iris/bitstream/handle/10665/339327/WHO-SRH-20.76-eng.pdf

( ៣ ) សុំឱ្យគរុនិស្សិតចែករំលែកបទពិសោធន៍របស់ពួកគេ និងសង្ខេបការពិភាក្សាជាក្រុមនៅក្នុងបទបង្ហាញមួយ។ តើអ្នកបានទទួលការអប់រំផ្លូវភេទតាំងពីបឋមសិក្សាដល់វិទ្យាល័យដែរឬទេ? តើអ្នកបានរៀនអ្វីខ្លះ?

( ៤ ) ណែនាំបទពិសោធន៍របស់គ្រូឧទ្ទេស។

ប្រសិនបើគ្រូឧទ្ទេសមានបទពិសោធន៍ក្នុងការបង្រៀនផ្លូវភេទ សូមនិយាយអំពីការបង្រៀននោះ។

## ៣. បញ្ជាក់បំភ្លឺ កំណត់គោលបំណងសិក្សា និងបង្រៀន

**រយៈពេល៖ ៤៥នាទី**

នៅក្នុងជំពូកទី ១១ ការបង្រៀននឹងផ្តោតលើបីចំណុចដូចខាងក្រោម៖

- ១. លក្ខណៈនៃការលូតលាស់ និងការអភិវឌ្ឍផ្នែកផ្លូវចិត្ត និងផ្លូវកាយអំឡុងពេលយុវវ័យ **(តារាងទី ១១.១)**
  - ១.១. ការប្រែប្រួលរាងកាយ
- ២. ដំណើរនៃការមានផ្ទៃពោះ និងសម្រាលកូន ព្រមទាំងស្ថានភាពបច្ចុប្បន្នជុំវិញដំណើរការនេះ
  - ២.៥. សុខភាពផ្លូវភេទរបស់យុវជន និងបញ្ហាប្រឈមនៅក្នុងប្រទេសកម្ពុជានាពេលបច្ចុប្បន្ន
- ៤. បញ្ហាប្រឈមសង្គម និងដំណោះស្រាយសង្គមពាក់ព័ន្ធនឹងសុខភាពផ្លូវភេទ

## ៤. ឧទាហរណ៍នៃកិច្ចការពិភាក្សាជាក្រុម និងសំណួរឆ្លើយឆ្លង

**រយៈពេល៖ ៥០នាទី**

- ក្រុមនីមួយៗនឹងលើកយកករណីសិក្សាមួយលើបញ្ហាជុំវិញការរួមភេទនៅប្រទេសកម្ពុជា ពិចារណាលើកត្តាសាវតារ ភាពខុសគ្នាក្នុងតំបន់ និងវិធានការកែលម្អ ហើយបង្ហាញលទ្ធផលដោយប្រើ PowerPoint (PPT) (លំហាត់សម្រាប់ការគិតនិងការស្រាវជ្រាវបន្ថែម [១១-៥])។
- តើការបង្រៀនកុមារអំពីផ្លូវភេទមានបញ្ហាប្រឈមអ្វីខ្លះ? ក្រុមនីមួយៗគិតពីឧទាហរណ៍ជាក់លាក់ ហើយបង្ហាញពួកគេដោយប្រើស្លាយ (PPT) (សូមមើល «**លំហាត់សម្រាប់ការគិត និងការស្រាវជ្រាវបន្ថែម [១១-៦]**»)។

កិច្ចការដែលគរុនិស្សិតត្រូវអាន និងស្វែងយល់ពីសៀវភៅសិក្សាគោល៖

- ពិនិត្យមើលជំពូកទី ៣ ស្តីពីលក្ខណៈនៃការអភិវឌ្ឍកុមារមុនពេលសិក្សាជំពូកនេះ។
  - ❖ ១. លក្ខណៈនៃការលូតលាស់ និងអភិវឌ្ឍផ្នែកផ្លូវចិត្ត និងផ្លូវកាយ និងអំឡុងពេលយុវវ័យ
    - ➢ ១.២. ការប្រែប្រួលផ្នែកផ្លូវចិត្ត និងផ្នែកសង្គម
  - ❖ ២. ដំណើរនៃការមានផ្ទៃពោះ និងសម្រាលកូន ព្រមទាំងស្ថានភាពបច្ចុប្បន្នជុំវិញដំណើរការនេះ
    - ➢ ២.១. ការមានផ្ទៃពោះ
    - ➢ ២.២. ការសម្រាលកូន
    - ➢ ២.៣. ស្ថានភាពបច្ចុប្បន្នជុំវិញម្តាយមានផ្ទៃពោះ និងម្តាយដែលបំបៅដោះកូន
    - ➢ ២.៤. ការពន្យារកំណើត
  - ❖ ៣. ជំងឺឆ្លងកាមរោគ
  - ❖ ៥. ភាពចម្រុះខាងផ្លូវភេទ

## ៥. ធនធាន

- UNICEF: A Statistical Profile of Child Protection in Cambodia 2018.

  **តំណភ្ជាប់ ២៤-២៥.៥៖** https://www.unicef.org/cambodia/media/716/file/Cambodia_Report_Final_Khmer.pdf%20.pdf
- UNESCO: International technical guidance on sexuality education: an evidence-informed approach, 2020.

  **តំណភ្ជាប់ ២៤-២៥.៦៖** https://unesdoc.unesco.org/ark:/48223/pf0000374167/

### វីដេអូ៖

- Module 2.1s Adolescent development: The art of growing up.

  **តំណភ្ជាប់ ២៤-២៥.៧៖** https://www.youtube.com/watch?v=0BJFoGK5GlY
- HHS Office of Population Affairs: Adolescent Development Explained: Becoming an Adult,

  **តំណភ្ជាប់ ២៤-២៥.៨៖** https://www.youtube.com/watch?v=xY6I20LNuqI
- SDSU Extension: Adolescent Development - Late Adolescence (Ages 18-22).

  **តំណភ្ជាប់ ២៤-២៥.៩៖** https://www.youtube.com/watch?v=wcXBQxmbjFY

## ៦. ការវាយតម្លៃ

- **ចំណេះដឹងនិងជំនាញ៖** ពន្យល់ពីលក្ខណៈនៃបញ្ហាសុខភាពផ្លូវចិត្តនិងផ្លូវកាយរបស់យុវវ័យនៅប្រទេសកម្ពុជា (ការធ្វើតេស្តចំណេះដឹង)។

- **ឥរិយាបថសិក្សានិងការចូលរួម៖** សង្កេតមើលអាកប្បកិរិយារបស់គរុនិស្សិតនិងការចូលរួមក្នុងការងារជាក្រុម។ ផ្តល់របាយការណ៍អំពីអ្វីដែលអ្នកបានរៀនពីការធ្វើការងារជាក្រុម អ្វីដែលអ្នកបានរៀនពីការស្តាប់បទបង្ហាញរបស់ក្រុមផ្សេងៗ និងបញ្ហាប្រឈមដែលអ្នកមានតាមរយៈការងារជាក្រុម។ វាយតម្លៃសំណួរនិងចម្លើយឆ្លើយឆ្លង។
- **សមត្ថភាពក្នុងការគិត វិនិច្ឆ័យ និងការបញ្ចេញមតិ៖** គរុនិស្សិតនឹងស៊ើបអង្កេតបញ្ហាទាក់ទងនឹងផ្លូវភេទក្នុងចំណោមយុវជនក្នុងប្រទេសកម្ពុជា ហើយរាយការណ៍អំពីស្ថានភាពបច្ចុប្បន្ន និងវិធានការប្រឆាំង(រាយការណ៍របាយការណ៍ចាត់ឱ្យធ្វើ)។ ស្រាវជ្រាវអំពីសិទ្ធិសុខភាពបន្តពូជ និងផ្តល់គំនិតរបស់អ្នកអំពីមូលហេតុដែលវាត្រូវបានចាត់ទុកថាមានសារៈសំខាន់នៅក្នុងប្រទេសកម្ពុជា(រាយការណ៍របាយការណ៍ចាត់ឱ្យធ្វើ)។ សូមពិចារណាតើបញ្ហាប្រឈមអ្វីខ្លះក្នុងការបង្រៀនកុមារអំពីការរួមភេទ និងវិធីយកឈ្នះលើបញ្ហាទាំងនោះ ហើយធ្វើរបាយការណ៍(រាយការណ៍របាយការណ៍ចាត់ឱ្យធ្វើ)។ វាយតម្លៃសមត្ថភាពក្នុងការពន្យល់កិច្ចការមួយយ៉ាងត្រឹមត្រូវ និងគួរឱ្យជឿជាក់ក្នុងបទបង្ហាញការងារជាក្រុម។ វាយតម្លៃសំណួរនិងចម្លើយឆ្លើយឆ្លង។

## ៧. តំណភ្ជាប់

| | | |
|---|---|---|
| ២៤-២៥.១ | ២៤-២៥.២ | ២៤-២៥.៣ |
| ២៤-២៥.៤ | ២៤-២៥.៥ | ២៤-២៥.៦ |
| ២៤-២៥.៧ | ២៤-២៥.៨ | ២៤-២៥.៩ |

# មេរៀនទី ២៦ ២៧

## ជំពូកទី ១២៖ សុខភាពផ្លូវចិត្ត

### ១. ទិដ្ឋភាពទូទៅ

នៅក្នុងជំពូកទី ៣ និង ១១ ការអភិវឌ្ឍនៃចិត្តគំនិតពីទារកហូតដល់វ័យជំទង់ត្រូវបានលើកមកនិយាយ។ នៅក្នុងជំពូកទី១២ ដោយផ្តោតជាពិសេសលើចិត្តគំនិតមនុស្ស គរុនិស្សិតនឹងរៀនអំពីទ្រឹស្តីនៃការអភិវឌ្ឍភាពតានតឹងក្នុងជីវិតប្រចាំថ្ងៃដែលប៉ះពាល់ដល់សុខភាពផ្លូវចិត្ត និងវិធីដោះស្រាយជាមួយបញ្ហាទាំងនោះ បញ្ហាសុខភាពផ្លូវចិត្តនៅប្រទេសកម្ពុជា ជំងឺផ្លូវចិត្តទូទៅ វិធីស្វែងរកជំនួយ និងរបៀបគាំទ្រ។

ទ្រឹស្តីនៃការអភិវឌ្ឍផ្លូវចិត្តគឺជាទ្រឹស្តីដ៏សំខាន់មួយសម្រាប់ការយល់ដឹងពីចិត្តគំនិតរបស់កុមារ ហើយគួរតែត្រូវបានដឹងដោយលោកគ្រូអ្នកគ្រូ។ ក្នុងការពិនិត្យមើលសុខភាពផ្លូវចិត្តក៏សំខាន់ផងដែរក្នុងការដឹងថា ចិត្តក៏មានមូលដ្ឋានជីវសាស្រ្ត ចិត្តសាស្រ្ត និងសង្គមស៊ីជម្រៅផងដែរ។ វាមានសារៈសំខាន់ក្នុងការយល់ដឹងអំពីការតានតឹងចិត្តនៃជីវិតប្រចាំថ្ងៃទាក់ទងនឹងបទពិសោធន៍ជីវិតផ្ទាល់ខ្លួនរបស់មនុស្សម្នាក់។ វាក៏មានសារៈសំខាន់ណាស់ផងដែរក្នុងការពិភាក្សាអំពីបញ្ហាចិត្តគំនិតរបស់ប្រជាជនកម្ពុជាដែលជាបញ្ហាដែលធ្លាប់មានពីបទពិសោធន៍ផ្ទាល់ខ្លួន ករណីសិក្សា និងព័ត៌មានប្រព័ន្ធផ្សព្វផ្សាយ ពីព្រោះវាជាបញ្ហាមិនទាន់មើលឃើញច្បាស់នៅក្នុងបរិបទសង្គម-វប្បធម៌របស់យើង។ ការរៀបចំខ្លួនជាគ្រូឧទ្ទេសដើម្បីប្រឹក្សាដល់កុមារ និងឪពុកម្តាយរបស់ពួកគេគឺជាផ្នែកនៃការសិក្សាដែលអាចរៀនបានតាមរយៈការសម្តែងដើរតួ។

### ២. សេចក្តីផ្តើម

រយៈពេល៖ ៥នាទី

(១) ប្រើប្រាស់ស្ថិតិប្រទេសកម្ពុជា។

(២) ប្រើប្រាស់ករណី និងយកអ្វីដែលមាននៅក្នុងសារព័ត៌មាន។

- សុខភាពផ្លូវចិត្តនៅប្រទេសកម្ពុជា៖ ការពិត និងតួលេខមួយចំនួន កាសែតភ្នំពេញប៉ុស្តិ៍ ថ្ងៃទី២៦ ខែសីហា ឆ្នាំ២០០៨

  តំណភ្ជាប់ ២៦-២៧.១៖ https://www.phnompenhpost.com/national/mental-health-cambodia-some-facts-and-figures

(៣) សុំឱ្យគរុនិស្សិតចែករំលែកបទពិសោធន៍របស់ពួកគេនិងសង្ខេបការពិភាក្សាជាក្រុមនៅក្នុងបទបង្ហាញមួយ។ (**សំណួរចាប់ផ្តើមគំរូ៖** តើវាមានន័យយ៉ាងណាសម្រាប់អ្នកចំពោះការមានសុខភាពផ្លូវចិត្តល្អ? តើអ្នកគិតថាសត្វមានចិត្តដែរឬទេ? មនុស្សយន្តបញ្ញាសិប្បនិម្មិត AI នឹងមានចិត្តដូចមនុស្សនៅពេលអនាគតដែរឬទេ?)

(៤) ណែនាំអំពីបទពិសោធន៍របស់គ្រូឧទ្ទេស។

## ៣. បញ្ជាក់បំភ្លឺ កំណត់គោលបំណងសិក្សា និងបង្រៀន

### រយៈពេល៖ ៥៥នាទី

ជាដំបូង ការសង្ខេបខ្លីៗនៃអ្វីដែលអ្នកនឹងរៀនត្រូវបានផ្តល់ឱ្យនៅក្នុងជំពូកនេះ។

នៅក្នុងជំពូកទី ១២ ការបង្រៀននឹងផ្តោតលើបីចំណុចដូចខាងក្រោម៖

- គំនិត និងការអភិវឌ្ឍនៃចិត្តពីជីវសាស្ត្រ ផ្លូវចិត្ត និងទិដ្ឋភាពសង្គម។
  - ❖ ១. បញ្ញត្តិ និងការលូតលាស់នៃផ្នែកចិត្ត និងសុខភាពផ្លូវចិត្ត
    - ➢ ១.១. ទស្សនៈទាំងបីអំពីចិត្ត
    - ➢ ១.២. ការអភិវឌ្ឍនៃចិត្ត
      - ក. ទ្រឹស្តីនៃការអភិវឌ្ឍការយល់ដឹងរបស់ព្យាជេត (Piaget) **(រូបទី ១២.២)**
      - ខ. ទ្រឹស្តីនៃការអភិវឌ្ឍជីវិតរបស់អេរីកសាន់ (Erickson)
    - ➢ ១.៣. តើសុខភាពផ្លូវចិត្តគឺជាអ្វី?
    - ➢ ១.៤. មនុស្សពេញវ័យក្នុងពិភពលោក និងសុខភាពផ្លូវចិត្ត
- ទំនាក់ទំនងផ្លូវចិត្តនិងរាងកាយ ទ្រឹស្តីនៃការតានតឹងចិត្ត និងព្រឹត្តិការណ៍នៃការតានតឹងចិត្ត
    - ➢ ២.២. ទំនាក់ទំនងរវាងចិត្តនិងរាងកាយ និងព្រមទាំងការតានតឹងចិត្តផ្នែកចិត្តសង្គម
      - ២.២.១. ទ្រឹស្តីនៃការតានតឹងចិត្តរបស់ ហាន សេលី (Hans Selye) **(តារាងទី ១២.១)**
      - ២.២.២. យន្តការនៃការផ្សារភ្ជាប់រាងកាយ និងចិត្ត
      - ២.២.៣. ឥរិយាបទជំនះ ការគាំទ្រផ្នែកសង្គម និងញាណក្នុងការគ្រប់គ្រងការតានតឹងចិត្ត
        - ក. ឥរិយាបថជំនះ
        - ខ. ការគាំទ្រផ្នែកសង្គម
- បញ្ហាប្រឈមរបស់ប្រទេសកម្ពុជាក្នុងវិស័យសុខភាពផ្លូវចិត្ត និងពិចារណាលើវិធីដោះស្រាយបញ្ហាប្រឈមទាំងនោះ
  - ❖ ៣. បញ្ហាប្រឈមសុខភាពផ្លូវចិត្តនៅប្រទេសកម្ពុជា
    - ➢ ៣.៣. ការសម្លុតគំរាម អំពើហិង្សា និងការបៀតបៀនកេរខ្មាស
    - ➢ ៣.៤. ភាពឯកា ការថប់បារម្ភ និងការធ្លាក់ទឹកចិត្ត

## ៤. ឧទាហរណ៍នៃកិច្ចការពិភាក្សាជាក្រុម និងសំណួរឆ្លើយឆ្លង

### រយៈពេល៖ ៤០នាទី

ដើម្បីយល់កាន់តែច្បាស់អំពី ១១ចំណុច នៃ «ការប្រឹក្សាសេវាសុខភាពផ្លូវចិត្ត» និងដើម្បីរៀនពីរបៀបស្តាប់អ្នកដទៃ បង្កើតក្រុមដែលមានគ្នា ៦នាក់ ធ្វើការសម្តែងដោយឡើងម្តងមួយគូៗ ហើយមនុស្ស ៤នាក់ទៀត ផ្តល់មតិត្រឡប់ថា តើពួកគេអាចទទួលស្តាប់បានដែរឬទេ។ សួរកុមារអំពីកង្វល់របស់ពួកគេជាមុនឬម៉្យាងទៀតដោយផ្អែកលើបទពិសោធន៍ផ្ទាល់ខ្លួនរបស់អ្នក សម្រេចចិត្តថាអ្នកចង់ប្រឹក្សាពួកគេអំពីអ្វី។

ពិភាក្សាអំពីមូលហេតុ និងសារតានៅពីក្រោយការប្រើប្រាស់ការដាក់ទណ្ឌកម្មរាងកាយរបស់គ្រូបង្រៀនក្នុងការអប់រំកុមារ។ តើអ្នកអាចណែនាំកុមារដោយរបៀបណាដោយមិនពឹងលើការដាក់ទណ្ឌកម្មរាងកាយ? ឆ្លាស់គ្នាផ្លាស់ប្តូរគំនិត។

កិច្ចការដែលគរុនិស្សិតគួរអាន និងស្វែងយល់ពីសៀវភៅសិក្សាគោល៖

- ការអភិវឌ្ឍផ្លូវចិត្តក្នុងទិដ្ឋភាពជីវសាស្ត្រ
- យន្តការសម្រាប់ការពារចិត្ត
- **អត្ថបទដកស្រង់ ១២.២៖** អារម្មណ៍ផ្សេងៗ និងការគ្រប់គ្រងអារម្មណ៍
- ជំងឺផ្លូវចិត្តទូទៅ (ជំងឺវិកលចរិត និងជំងឺឆ្កួតជ្រូក)
- អាកប្បកិរិយាស្វែងរកការជួយ

## ៥. ធនធាន

- WHO. Mental Health ATLAS 2017 Member State Profile Cambodia,
  **តំណភ្ជាប់ ២៦-២៧.២៖** https://cdn.who.int/media/docs/default-source/mental-health/mental-health-atlas-2017-country-profiles/khm.pdf?sfvrsn=c5bb150c_1&download=true
- RUPP Department of Psychology, Cambodia Mental Health Survey 2012.
  **តំណភ្ជាប់ ២៦-២៧.៣៖** https://data.opendevelopmentmekong.net/library_record/cambodian-mental-health-survey

"School Health Project for all Cambodian Children" TEC Student Health's Survey 2022

How would you rate your overall mental health?







- Alexandria Pan, THE MENTAL HEALTH AND WELL-BEING OF COLLEGE STUDENTS IN CAMBODIA, Master Thesis of California State University, Long Beach.
  **តំណភ្ជាប់ ២៦-២៧.៤៖** https://www.proquest.com/openview/dec6788a19ed493d167d41f6095934fa/1?pq-origsite=gscholar&cbl=18750&diss=y
- The Need to Promote Mental Health Awareness among Cambodian University Students, Cambodians,
  **តំណភ្ជាប់ ២៦-២៧.៥៖** https://cambodianess.com/article/the-need-to-promote-mental-health-awareness-among-cambodian-university-students
- TPO Cambodia, Mental Health Tips (Khmer & English)
  **តំណភ្ជាប់ ២៦-២៧.៦៖** https://tpocambodia.org/tips-for-good-mental-health/

**វីដេអូ៖**

- Ontario College of Teachers, SUPPORTING STUDENTS' MENTAL HEALTH - PROFESSIONAL ADVISORY,
  តំណភ្ជាប់ ២៦-២៧.៧៖ https://www.oct.ca/resources/advisories/mental-health?sc_lang=en&
- Western Ontario University, How to Do Basic Counseling Skills: Role Play,
  តំណភ្ជាប់ ២៦-២៧.៨៖ https://www.youtube.com/watch?v=OwW8x_0YGLI

## ៦. ការវាយតម្លៃ

- **ចំណេះដឹងនិងជំនាញ៖** ឧទាហរណ៍ ចំណេះដឹងអំពីការតានតឹងចិត្តផ្នែករូបវិទ្យា និងកត្តាការតានតឹងផ្នែកផ្លូវចិត្ត និងឧទាហរណ៍ទាំងនេះ(ការធ្វើតេស្តចំណេះដឹង)។ ចំណេះដឹងអំពីអាកប្បកិរិយាទប់ទល់ និងការគាំទ្រសង្គម និងឧទាហរណ៍ទាំងនេះ(ការធ្វើតេស្តចំណេះដឹង)។ ពន្យល់អំពីយន្តការការពារផ្លូវចិត្ត និងឧទាហរណ៍ទាំងនេះ (ការធ្វើតេស្តចំណេះដឹង)។ ស្រាវជ្រាវនិងសរសេររបាយការណ៍ស្តីពីការប្រកាន់ ការរើសអើង និងការមាក់ងាយប្រឆាំងនឹងមនុស្សដែលមានជំងឺវិកលចរិត និងជំងឺផ្លូវចិត្តផ្សេងៗទៀត (វាយការណ៍របាយការណ៍ចាត់ឱ្យធ្វើ)។
- វាយការណ៍អំពីអ្វីដែលអ្នកឱ្យតម្លៃនៅក្នុងជីវិតប្រចាំថ្ងៃរបស់អ្នក និងអ្វីដែលអ្នកចង់អនុវត្តនាពេលខាងមុខដើម្បីថែរក្សាខ្លួនអ្នក និងមនុស្សជុំវិញអ្នកឱ្យមានសុខភាពផ្លូវចិត្តល្អ (វាយការណ៍របាយការណ៍ចាត់ឱ្យធ្វើ)។
- **អាកប្បកិរិយានិងការចូលរួមក្នុងការរៀនសូត្រ៖** ឧទាហរណ៍ សង្កេតមើលអាកប្បកិរិយារបស់គរុនិស្សិត និងការចូលរួមក្នុងការងារជាក្រុម។ ចាត់ឱ្យធ្វើរបាយការណ៍អំពីអ្វីដែលអ្នកបានរៀនពីការធ្វើការងារជាក្រុម អ្វីដែលអ្នកបានរៀនពីការស្តាប់បទបង្ហាញរបស់ក្រុមផ្សេងៗ និងបញ្ហាប្រឈមដែលអ្នកមានតាមរយៈការងារជាក្រុម។ វាយតម្លៃសំណួរ និងចម្លើយឆ្លើយឆ្លង។
- **សមត្ថភាពក្នុងការគិត វិនិច្ឆ័យ និងបញ្ចេញមតិ៖** ឧទាហរណ៍ ចាត់ឱ្យធ្វើរបាយការណ៍អំពីអ្វីដែលអ្នកបានរៀនពីការធ្វើការងារជាក្រុម អ្វីដែលអ្នកបានរៀនពីការស្តាប់បទបង្ហាញរបស់ក្រុមផ្សេងៗ និងបញ្ហាប្រឈមដែលអ្នកមានតាមរយៈការងារជាក្រុម។ វាយតម្លៃសមត្ថភាពក្នុងការពន្យល់កិច្ចការមួយយ៉ាងត្រឹមត្រូវ និងគួរឱ្យជឿជាក់ក្នុងបទបង្ហាញការងារជាក្រុម។ វាយតម្លៃសំណួរនិងចម្លើយឆ្លើយឆ្លង។ ពន្យល់ពីទ្រឹស្តីនៃការអភិវឌ្ឍជីវិតរបស់អេរីកសាន់ (Erikson) ដោយរៀបចំវាទៅក្នុងដ្យាក្រាម។

## ៧. តំណភ្ជាប់

| | | | |
|---|---|---|---|
| ២៦-២៧.១ | ២៦-២៧.២ | ២៦-២៧.៣ | ២៦-២៧.៤ |
| ២៦-២៧.៥ | ២៦-២៧.៦ | ២៦-២៧.៧ | ២៦-២៧.៨ |

# មេរៀនទី ២៨ ២៩

## ជំពូកទី ១៣៖ បរិស្ថាន និងសុខភាព / អេកូសុខភាព

### ១. ទិដ្ឋភាពទូទៅ

